

សៀវភៅហ្វឹកហាត់

# សរសេរតាមអាន និង តែងសេចក្តី

៥

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា**

www.elibraryofcambodia.org

សៀវភៅហ្វឹកហាត់

# សរសេរតាមអាន និង តែងសេចក្តី

ថ្នាក់ទី ៥

បោះពុម្ពផ្សាយដោយ

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

www.elibraryofcambodia.org

| | | |
|---|---|---|
| **អ្នកនិពន្ធនិងរៀបរៀង** | លោក | យិន ជី |
| **អ្នកវាយអត្ថបទ** | លោកស្រី | ហាក់ ផាន្នី |
| **អ្នកពិនិត្យអក្ខរាវិរុទ្ធ** | លោកស្រី | ឈឹម សក្តិវៃឡែត |
| | លោក | អ៊ុំ បុប្ផា |
| **វិចិត្រករ** | លោក | ហ៊ុយ វណ្ណថេន |
| **អ្នករចនាទំព័រ** | លោក | គង់ ចិត្រា |
| **គណៈកម្មការពិនិត្យ** | បណ្ឌិត | នៅ ស៊ុន |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ១៤១៦ អយក.ប្រក. ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០១៤ ដើម្បីប្រើប្រាស់នៅតាមសាលារៀន។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ២០១៦

ISBN 9-789-995-002-176

www.elibraryofcambodia.org

# អារម្ភកថា

សួស្តី ! លោកគ្រូអ្នកគ្រូ ប្អូនៗសិស្សានុសិស្ស និងប្រិយមិត្តអ្នកសិក្សាទាំងអស់ជាទីមេត្រី ! សៀវភៅសរសេរតាមអាននិងតែងសេចក្តីថ្នាក់ទី៥នេះបានរៀបចំឡើងស្របតាមសៀវភៅសិក្សាថ្មីមុខវិជ្ជាភាសាខ្មែរថ្នាក់ទី៥ របស់ **ក្រសួងអប់រំ យុវជន និងកីឡា**។

សៀវភៅនេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងជួយដល់ការបង្រៀន និងរៀនរបស់លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងមិត្តអ្នកសិក្សាទាំងអស់លើផ្នែកសរសេរតាមអាននិងតែងសេចក្តី ដើម្បីឱ្យទទួលបានលទ្ធផលល្អនិងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងសៀវភៅសរសេរតាមអាន និងតែងសេចក្តីថ្នាក់ទី៥នេះ មានអត្ថបទខ្លីៗសម្រាប់សរសេរតាមអាន អំណានពាក្យពិបាក ពន្យល់ពាក្យ បដិសព្ទ សទិសសព្ទ វេវចនសព្ទ សំណួរចម្លើយគម្រោងតែងសេចក្តី និងមានសេចក្តីអធិប្បាយតែងសេចក្តីសំខាន់ៗមួយចំនួនថែមទៀត។ ចំណុចទាំងអស់នេះ ជាការចូលរួមលើកកម្ពស់ ការរៀន និងបង្រៀនសរសេរតាមអាន និងតែងសេចក្តី ឱ្យទទួលបានលទ្ធផលល្អថែមទៀត។

យើងខ្ញុំសង្ឃឹមថា សៀវភៅសរសេរតាមអាននិងតែងសេចក្តីថ្នាក់ទី៥នេះនឹងក្លាយជាជំនួយដ៏ល្អ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រិយមិត្តអ្នកសិក្សាទាំងអស់ពុំខាន។

យើងខ្ញុំរង់ចាំទទួលមតិស្ថាបនាពីប្រិយមិត្តអ្នកអាន អ្នកសិក្សាគ្រប់ពេលវេលា ដើម្បីធ្វើឱ្យសៀវភៅនេះកាន់តែល្អថែមទៀត។

**អ្នកនិពន្ធ**

**យិន ធី**

www.elibraryofcambodia.org

# មាតិកា

## វិញ្ញាសា
## សរសេរតាមអាន

ទំព័រ


១. ការគោរព បម្រើមាតាបិតា និងជីដូនជីតា ........ ០១
២. វីរបុរសក្រឡាហោមគង់ ........ ០៤
៣. អ្នកតាឃ្លាំងមឿង ........ ០៨
៤. ការគោរពលោកគ្រូ អ្នកគ្រូ ........ ១២
៥. ស្នាដៃកវី និងអ្នកនិពន្ធខ្មែរ ........ ១៦
៦. កំណាព្យខ្មែរ ........ ២១
៧. បំណងរបស់ខ្ញុំ ........ ២៥
៨. ប្រាសាទព្រះវិហារ ........ ៣០
៩. ផលិតផលនៅប្រទេសកម្ពុជា ........ ៣៤
១០. ផលិតផលត្បូងខ្មែរ ........ ៣៨
១១. ផលប្រយោជន៍នៃការអានសៀវភៅ ........ ៤៤
១២. កូនល្អ ........ ៤៧
១៣. មាតុភូមិជាទីស្នេហា ........ ៥១
១៤. ចម្លាក់ប្រាសាទអង្គរវត្ត ........ ៥៥
១៥. សុភមង្គលរបស់ខ្ញុំ ........ ៥៩
១៦. នឿយមុនស្រណុកក្រោយ ........ ៦៤
១៧. ព្រះពុទ្ធសាសនា ........ ៦៨
១៨. ពិធីហៅព្រលឹងស្រូវ ........ ៧៣
១៩. មរតកបញ្ញា ........ ៧៧
២០. ចៅទៃយ៉ាំ ........ ៨១
២១. ផលប្រយោជន៍វិទ្យាសាស្ត្រ ........ ៨៦


## វិញ្ញាសា
## តែងសេចក្តីបែបពិពណ៌នា


១. អំពីមនុស្ស ........ ៩១
២. អំពីសត្វ ........ ៩៤
៣. អំពីទីកន្លែង ........ ៩៥
៤. អំពីបាតុភូតធម្មជាតិ ........ ៩៨
៥. អំពីសកម្មភាព ........ ១០១
៦. អំពីពិធីបុណ្យផ្សេងៗ ........ ១០៤


www.elibraryofcambodia.org

# លំនាំបង្រៀន

**I. សរសេរតាមអានត្រួតពិនិត្យ**

ក. ការសរសេរតាមអាន

១. គ្រូឱ្យសិស្សម្នាក់ឡើងសរសេរនៅក្តារខៀនដោយបិទវាំងននជិត។

២. គ្រូអានអត្ថបទមួយចប់ឱ្យសិស្សស្តាប់។

៣. គ្រូហៅកន្សោមពាក្យ ឬឃ្លាខ្លីចំនួនបីដង ឱ្យសិស្សសរសេរតាមរហូតដល់ចប់។

> *បញ្ជាក់ ៖* គ្រូអាចឱ្យសិស្សពីរនាក់ ចាំតាមគ្រូ។ សិស្សម្នាក់ចាំមុនពេលសរសេរ ហើយសិស្សម្នាក់ទៀតចាំបន្ទាប់ពីសរសេររួច។

៤. គ្រូអានអត្ថបទឱ្យសិស្សស្តាប់ឡើងវិញដោយយឺតៗ និងច្បាស់ៗ ដើម្បីឱ្យសិស្សផ្ទៀងផ្ទាត់ឡើងវិញ និងទុកពេលឱ្យសិស្សកែកំហុស។

ខ. លំហាត់

១. គ្រូណែនាំសិស្សហ្វឹកហាត់អានពាក្យមួយម្តងៗ ដោយធ្វើអក្ខរាវិរុទ្ធ។ បន្ទាប់មកឱ្យសិស្សហ្វឹកហាត់អានពាក្យនីមួយៗ ដោយមិនប្រកប។ គ្រូហៅសំណួរឱ្យសិស្សសរសេរ ឬចម្លងសំណួរនិងលំហាត់ដាក់លើក្តារខៀន ឬចម្លងសំណួរ និងលំហាត់ដាក់ក្រដាសផ្ទាំងធំយកមកបិទ។

២. គ្រូណែនាំសិស្សឱ្យពន្យល់ពាក្យដោយប្រើវិធីផ្សេងៗដូចជា ប្រើរូបភាព រកន័យដូច រកន័យផ្ទុយ ឬពន្យល់ន័យតែម្តង។ល។

៣. គ្រូណែនាំសិស្សឱ្យរកបដិសព្ទ វេវចនសព្ទ និងសទិសសព្ទ។

គ. សំណួរ

១. គ្រូហៅសំណួរឱ្យសិស្សសរសេរ ឬចម្លងសំណួរនិងលំហាត់ដាក់លើក្តារខៀន ឬចម្លងសំណួរដាក់ក្រដាសផ្ទាំងធំយកមកបិទ។

២. គ្រូណែនាំសិស្សឱ្យឆ្លើយសំណួរមួយម្តងៗ រហូតដល់ចប់។

ឃ. ការកែលម្អ

១. គ្រូបើកវាំងននធ្វើការកែលម្អការសរសេរតាមអាន រួមលើក្តារខៀន។

www.elibraryofcambodia.org

២. គ្រូឱ្យសិស្សប្ដូរកិច្ចការគ្នាកែ ដោយគូសចំនួនកំហុសនៅដើមបន្ទាត់ខាងឆ្វេងពាក្យខុសនោះ។
៣. គ្រូធ្វើការកែលម្អសំណួរ និងលំហាត់រួមលើក្ដារខៀនម្ដងៗរហូតដល់ចប់។
៤. គ្រូឱ្យសិស្សធ្វើការកែលម្អកិច្ចការខ្លួន។

## II. តែងសេចក្ដី

### ក. ការបង្ហាញ

១. រំឭកមេរៀនដោយសួរសំណួរទាក់ទងនឹងតែងសេចក្ដីបែបពណ៌នា។
២. អានគម្រោងតែងសេចក្ដីបែបពណ៌នាគំរូ។
៣. សួរសំណួរទាក់ទងនឹងខ្លឹមសារគម្រោងតែងសេចក្ដីបែបពណ៌នាគំរូ។
៤. អានអត្ថបទតែងសេចក្ដីគំរូ ដោយសង្កេតមើលចំណុចសំខាន់ៗនៃតែងសេចក្ដីបែបពណ៌នា។
៥. សួរសំណួរទាក់ទងនឹងខ្លឹមសារអត្ថបទតែងសេចក្ដីគំរូ។
៦. សួរសំណួររកឱ្យឃើញប្លង់ និងគម្រោងរបស់តែងសេចក្ដី។

### ខ. ការអនុវត្ត

១. បំផុសសំណួរ ឱ្យឃើញគម្រោងតែងសេចក្ដីលម្អិតទាក់ទងនឹងប្រធានតែងសេចក្ដី
២. ការប្រមូលគំនិត ៖ ប្រមូលគំនិតលម្អិតទាក់ទងនឹងគម្រោងតែងសេចក្ដី។
៣. ការសរសេរព្រាង ៖ យកគំនិតដែលប្រមូលបានមកសរសេរព្រាងជាល្បះពេញលេញឱ្យបានត្រឹមត្រូវតាមគម្រោងតែងសេចក្ដី។
៤. ការកែលម្អ ៖ គ្រូឱ្យសិស្សប្ដូរកិច្ចការគ្នាកែ (ក្នុងការកែមិនត្រូវឱ្យសិស្សគូសវាស ឬសរសេរលើកិច្ចការគេទេ បើពិនិត្យឃើញមានកំហុសត្រូវមកពិភាក្សាកែលម្អជាមួយម្ចាស់ដើមវិញ) ពេលកែរួចត្រូវប្រគល់កិច្ចការឱ្យម្ចាស់ដើមវិញ។
៥. ការសរសេរសម្រេច ៖ ឱ្យសិស្សយកកិច្ចការរបស់ខ្លួនមកសរសេរសម្រេចឱ្យបានស្អាតត្រឹមត្រូវ។

### គ.ការវាយតម្លៃ

១. សួរសំណួរទាក់ទងនឹងបញ្ញត្តិតែងសេចក្ដីបែបពណ៌នា។
២. សួរសំណួរពង្រឹងចំណេះដឹងអំពីគម្រោងតែងសេចក្ដីខាងលើ។
៣. ដាក់ប្រធានតែងសេចក្ដីថ្មីឱ្យសិស្សធ្វើនៅផ្ទះដោយផ្អែកលើគម្រោងខាងលើ។

www.elibraryofcambodia.org

វិញ្ញាសាទី

# ១ ការគោរព បម្រើមាតាបិតា និងជីដូនជីតា



ការគោរព បម្រើមាតាបិតា និងជីដូនជីតា ជាតម្លៃដ៏សំខាន់សម្រាប់កូនចៅ។ ឥរិយាបថដ៏ប្រពៃនេះ បង្ហាញពីភាពស្មោះត្រង់ និងកិច្ចតបស្នងចំពោះអ្នកមានគុណ ដែលជាអ្នកផ្ដល់កំណើត និងជាអ្នកស្រឡាញ់បីបាច់ថែរក្សា និងប្រោសប្រណីដល់យើង។ កូនចៅត្រូវគោរព ស្ដាប់ដំបូន្មានល្អៗ ឬជួយសម្រាលការងាររបស់លោក។

មុនពេលចេញទៅសាលារៀន កូនចៅត្រូវជម្រាបលា ឬសុំអនុញ្ញាតពីលោកជាមុន ដោយលើកដៃសំពះលា រួចធ្វើដំណើរទៅសាលារៀន ដោយមិនគេចវេះសាលាឡើយ។ ពេលកូនត្រឡប់មកពីសាលារៀនវិញ កូនត្រូវលើកដៃសំពះជម្រាបជាដំណឹងដល់លោក។

ការគោរព បម្រើមាតាបិតា និងជីដូនជីតារបស់យើង ធ្វើឱ្យគ្រួសារសប្បាយរីករាយ និងមានសុភមង្គល ។ ដូច្នេះ ការគោរពនិងបម្រើមាតាបិតា ជាទង្វើមួយដែលយើងត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួន ទើបយើងក្លាយជាកូនល្អ សិស្សល្អ ។

*(ដកស្រង់និងកែសម្រួលពីសៀវភៅ សិក្សាសង្គម ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១)*


www.elibraryofcambodia.org

## សិក្សាលើវិញ្ញាសាទី ១

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖
" ឥរិយាបថ ប្រោសប្រណី គេចវេះ ខ្ជាប់ខ្ជួន " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖
" សំខាន់ ស្មោះត្រង់ សុភមង្គល ខ្ជាប់ខ្ជួន "។

៣.ចូររកវេវចនសព្ទនឹងពាក្យ ៖ " ប្រពៃ "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " លា "។

### ខ. សំណួរ

១. តើការគោរព បម្រើមាតាបិតា និងជីដូនជីតាជាឥរិយាបថបែបណា?

២. តើកូនចៅត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីគោរពបម្រើលោកអ្នកមានគុណ?

៣.មុនពេលចេញទៅសាលារៀន និងពេលត្រឡប់មកពីសាលាវិញ តើកូនចៅត្រូវធ្វើដូចម្ដេច ?

៤. ការគោរព បម្រើមាតាបិតា និងជីដូនជីតារបស់យើង ធ្វើឱ្យគ្រួសារក្លាយទៅជាយ៉ាងណា ?

## គំរូណែវិញ្ញាសាទី ១

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ឥរិយាបថ (ន.) ៖ ឫកពាខាងក្រៅ ។
- ប្រោសប្រណី (គុ.) ៖ លើកលែង យោគយល់ ។
- គេចវេះ (កិ.) ៖ មិនចូល គេចចេញ ...។
- ខ្ជាប់ខ្ជួន (គុ.) ៖ ហ្មត់ចត់ ទៀងទាត់ ។


www.elibraryofcambodia.org

២.បដិសព្ទ

- សំខាន់ ≠ បន្ទាប់បន្សំ រាយរង
- ស្មោះត្រង់ ≠ វៀចវេរ
- សុភមង្គល ≠ ទុក្ខព្រួយ អពមង្គល ទុញ្ញមង្គល
- ខ្ជាប់ខ្ជួន ≠ ធ្វេសប្រហែស

៣.វេវចនសព្ទ

ប្រពៃ ប្រសើរ ថ្លៃថ្លា ឧត្តុង្គឧត្ដម ខ្ពង់ខ្ពស់ ... ។

៤.សទិសសព្ទ

- លា (កិ.) ៖ លាតឬត្រដាងអ្វីៗដែលម្ងរ បត់ ឬក្ដោប
  ឧ. លាដៃ ។
- លា (ន.) ៖ សត្វមួយប្រភេទរូបរាងដូចសេះ តែស្លឹកត្រចៀក
  វែង កន្ទុយដូចគោ ។

## ខ.ចម្លើយ

១. ការគោរពមាតាបិតាជីដូនជីតាជាឥរិយាបថដ៏ប្រពៃនេះ បង្ហាញពីភាពស្មោះត្រង់ និងកិច្ចតបស្នងចំពោះអ្នកមានគុណ ដែលជាអ្នកផ្ដល់កំណើត និងជាអ្នកស្រឡាញ់បីបាច់ថែរក្សា និងប្រោសប្រណីដល់យើង។

២. កូនចៅត្រូវគោរព ស្ដាប់ដំបូន្មានល្អៗ ឬជួយសម្រាលការងាររបស់លោក ទើបចាត់ទុកជាអ្នកគោរពបម្រើអ្នកមានគុណ។

៣. មុនពេលចេញទៅសាលារៀន កូនចៅត្រូវជម្រាបលា ឬសុំអនុញ្ញាតពីលោកជាមុន ដោយលើកដៃសំពះលា រួចធ្វើដំណើរទៅសាលារៀន ដោយមិនគេចវេះសាលាឡើយ។ ពេលត្រឡប់មកពីសាលារៀនវិញ កូនត្រូវលើកដៃសំពះជម្រាបជាដំណឹងដល់លោក ។

៤. ការគោរពបម្រើមាតាបិតា និងជីដូនជីតារបស់យើង ធ្វើឱ្យគ្រួសារសប្បាយរីករាយ និងមានសុភមង្គល ។


www.elibraryofcambodia.org

វិញ្ញាសាទី

# ២ វីរបុរសក្រឡាហោមគង់



ក្រឡាហោមគង់ជាមន្ត្រីខ្មែរស្នេហាជាតិម្នាក់ ដែលបានតស៊ូប្រឆាំងនឹងការជិះជាន់ កៀបសង្កត់របស់អាណានិគមនិយមបារាំង។ លោកបានធ្វើពលិកម្មយ៉ាងធំធេង ដើម្បីរំដោះចេញពីនឹមត្រួតត្រារបស់បារាំង។ លោកមានទឹកចិត្តអង់អាចក្លាហានតស៊ូប្រឆាំងនឹងបរទេសឈ្លានពាន។ បារាំងបានដឹងពីគំនិត និងគោលជំហររបស់លោក ក៏បានរកមធ្យោបាយចាប់លោក។ ក្រឡាហោមគង់ត្រូវបារាំងចាប់បាន និងយកទៅធ្វើទារុណកម្មយ៉ាងសម្ងាត់ ។

ព្រះទិនករលិចស្រឹមបាត់ទៅ ពេលព្រលប់ក៏ខិតចូលមកដល់ ធ្វើឱ្យស្រអាប់គ្រប់ទិសទី។ កប៉ាល់បារាំងបាននាំលោកចេញពីមាត់ទន្លេមុខវត្តឧណ្ណាលោម ឆ្ពោះទៅកាន់ទិសឧត្តរ។ នៅលើនាវា ដៃទាំងពីររបស់


www.elibraryofcambodia.org

លោកត្រូវជាប់ខ្នោះ ខ្លួនលោកត្រូវគេចងផ្អោបនឹងបំពង់ផ្សែង។ ក្រឡាហោមគង់ត្រមង់ត្រមោចម្នាក់ឯង ទឹកមុខក្រៀមក្រំពន់ពេក។ ប៉ុន្តែស្មារតីស្នេហាជាតិមាតុភូមិ ពុំបានធ្វើឱ្យលោកតក់ស្លុតឡើយ ទោះបីជាលោកដឹងច្បាស់ថាត្រូវទទួលមរណភាពដោយសារដៃឃាតករបារាំងក៏ដោយ។ នៅដង្ហើមចុងក្រោយ លោកនឹកដល់គុណឪពុកម្ដាយ ព្រះសង្ឃ ប្រជាជនខ្មែរ និងនឹកដល់មាតុភូមិជាទីស្នេហារបស់លោក។

ការបាត់បង់វីរជនស្នេហាជាតិរូបនេះ ធ្វើឱ្យយើងសោកស្ដាយអាណិតអាសូរក្រៃលែង។ ក្រឡាហោមគង់ បានបាត់បង់ជីវិតចាកឆ្ងាយពីយើងពិតមែន ប៉ុន្តែកិត្តិនាម និងវីរភាពដ៏អង់អាចក្លាហានរបស់លោកបានសណ្ឋិតជាប់ក្នុងដួងព្រលឹងកូនខ្មែរជាប់ជានិច្ច ។

*(ដកស្រង់ពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១)*

## សិក្សាលើទិញ្ញាសាទី ២

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖ " ពលិកម្ម ទិសនត្ថរ ត្រមង់ត្រមោច មរណភាព កិត្តិនាម វីរភាព សណ្ឋិត " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖ " ស្រអាប់ ក្រៀមក្រំ ចាកឆ្ងាយ ក្លាហាន " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ព្រះទិនករ និងមរណភាព "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " គុណ " ។

### ខ. សំណួរ

១. តើក្រឡាហោមគង់ជានរណា ?

២. តើក្រឡាហោមគង់ បានធ្វើអ្វីខ្លះដើម្បីជាតិមាតុភូមិ ?


www.elibraryofcambodia.org

៣. នៅពេលបាក់ងចាប់បានតើក្រឡាហោមគង់មានស្មារតីដូចម្ដេច ?
៤. តើយើងមានទឹកចិត្តយ៉ាងណាចំពោះការបាត់បង់ក្រឡាហោមគង់ ?
៥. ចូរស្រង់ពាក្យជាគុណនាម ពីក្នុងអត្ថបទឱ្យបាន៥ពាក្យ ។

## អំណានទីពីរ សាទី ២

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ពលិកម្ម (ន.) ៖ ការលះបង់ ការបូជា ...។
- ទិសឧត្តរ (ន.) ៖ ទិសខាងជើង។
- ត្រមង់ត្រមោច (គុ.) ៖ ដែលកំសត់ ម្នាក់ឯង ...។
- មរណភាព (ន.) ៖ សេចក្ដីស្លាប់។
- កិត្តិនាម (ន.) ៖ កេរ្តិ៍ឈ្មោះ។
- វីរភាព (ន.) ៖ សេចក្ដីអង់អាចក្លាហាន ។
- សណ្ឋិត (ន.) ៖ ការតាំងនៅ ការជិតជាប់ ...។

២. បដិសព្ទ

- ស្រអាប់ ≠ ច្បាស់ក្រឡែត ច្បាស់ថែស
- ក្រៀមក្រំ ≠ សប្បាយរីករាយ
- ចាកឆ្ងាយ ≠ នៅជិតបង្កើយ
- ក្លាហាន ≠ កំសាក ខ្លាច ...

៣. ផវចនសព្ទ

- ព្រះទិនករ ថ្ងៃ ព្រះអាទិត្យ ព្រះសុរិយា ។
- មរណភាព ស្លាប់ ងាប់ សុគត សោយទិវង្គត បរិនិព្វាន ។


www.elibraryofcambodia.org

៤. សទិសសព្ទ

- គុណ (ន.គុ.) ៖ ដំណើរធ្វើឱ្យកើនឡើង។
- គុណ (ន.) ៖ សេចក្ដីចម្រើន សេចក្ដីល្អ លក្ខណៈ សភាព ...។ ឧ. គុណមាតាបិតា។
- គុន (ន.) ៖ ឈ្មោះក្បាច់ខាងគ្រឿងអាវុធសម្រាប់តយុទ្ធផ្ទាល់ខ្លួន ឬជាក្បាច់វិសេសម្យ៉ាងរបស់អ្នកចម្បាំង។ ឧ. គុនដាវ គុនដំបង ...។

## ខ. ចម្លើយ

១. ក្រឡាហោមគង់ជាមន្ត្រីខ្មែរស្នេហាជាតិមួយរូប ដែលបានតស៊ូប្រឆាំងនឹងការជិះជាន់ កៀបសង្កត់ពីអាណានិគមនិយមបារាំង។

២. ក្រឡាហោមគង់បានធ្វើពលិកម្មយ៉ាងធំធេង ដើម្បីរើបម្រះចេញពីនឹមត្រួតត្រារបស់បារាំង។ លោកមានទឹកចិត្តអង់អាចក្លាហានតស៊ូប្រឆាំងនឹងបរទេសឈ្លានពាន។ បារាំងបានដឹងពីគំនិត និងជំហររបស់លោក ក៏បានរកមធ្យោបាយចាប់លោក។

៣. នៅពេលបារាំងចាប់បាន ក្រឡាហោមគង់នៅតែមានស្មារតីស្នេហាជាតិមាតុភូមិ ពុំបានធ្វើឱ្យលោកតក់ស្លុតឡើយ ទោះបីជាលោកដឹងច្បាស់ថា ត្រូវទទួលមរណភាពដោយសារដៃឃាតករបារាំងក៏ដោយ។ នៅដង្ហើមចុងក្រោយ លោកនឹកដល់គុណឪពុកម្ដាយ ព្រះសង្ឃ ប្រជាជនខ្មែរ និងនឹកដល់មាតុភូមិជាទីស្នេហារបស់លោកជានិច្ច។

៤. ការបាត់បង់វីរជនស្នេហាជាតិរូបនេះ ធ្វើឱ្យយើងសោកស្ដាយអាណិតអាសូរក្រៃលែង។ ក្រឡាហោមគង់ បានបាត់បង់ជីវិតចាកឆ្ងាយពីយើងពិតមែន ប៉ុន្តែកិត្តិនាម និងវីរភាពអង់អាចក្លាហានរបស់លោក បានសណ្ឋិតជាប់ក្នុងដួងព្រលឹងកូនខ្មែរជាប់ជានិច្ច។

៥. ពាក្យដែលជាគុណនាមក្នុងអត្ថបទ ៖ ធំធេង ស្រអាប់ ត្រមង់ត្រមោច ក្រៀមក្រំ ក្លាហាន។


www.elibraryofcambodia.org

វិញ្ញាសាទី ៣

# អ្នកតាឃ្លាំងមឿង



សេនាមឿង ជាវីរជនដ៏អង់អាចក្លាហាន។ លោកបានធ្វើពលិកម្មដ៏ធំធេង ដើម្បីជាតិមាតុភូមិ។

នៅក្នុងគ្រាដែលនគរខ្មែរកើតចម្បាំងជាមួយពួកសៀមឈ្លានពាន សេនាមឿងសុខចិត្តពលិកម្ម ទាំងខ្លួនលោក ប្រពន្ធ និងកូនពីរនាក់ទៀត។ បេសកកម្មនេះ បង្ហាញពីវីរភាពដ៏មោះមុត ព្រោះលោកហ៊ានលោតចូលក្នុងរណ្ដៅដែលមានសុទ្ធតែចម្រូង ដើម្បីទៅកេណ្ឌទ័ពខ្មោចមកជួយច្បាំងជាមួយទ័ពសៀម។ ការលះបង់របស់សេនាមឿង បង្ហាញពីទឹកចិត្តស្នេហាជាតិមាតុភូមិយ៉ាងមុតមាំ។ បេសកកម្មរបស់សេនាមឿង ប្រពន្ធ និងកូន ពិតជាបាននាំមកនូវជ័យជម្នះជូននគរខ្មែរ ពោលគឺធ្វើឱ្យពលរដ្ឋខ្មែររំដោះជាតិរួចផុតពីការត្រួតត្រារបស់ពួកសៀម។ វីរភាពនេះ ធ្វើឱ្យកូនខ្មែរគ្រប់រូបនៅចងចាំជានិច្ច។


www.elibraryofcambodia.org

ដើម្បីសម្ដែងនូវការដឹងគុណ និងការគោរពចំពោះសេនាមៀង គេបានកសាងរូបសំណាក និងកន្លែងសម្រាប់ធ្វើសក្ការបូជាចំពោះលោក។ លើសពីនេះ ថែមទាំងបានប្រសិទ្ធនាមថា អ្នកតាឃ្លាំងមឿង ដែលមានទីតាំងនៅក្នុងខេត្តពោធិ៍សាត់។ បច្ចុប្បន្ន ប្រជាជនទូទៅតែងនាំគ្នាធ្វើការបួងសួង និងគោរពបូជានៅទីនោះតាមទម្លាប់មិនដែលអាក់ខានឡើយ ។

*(ដកស្រង់ពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១)*

## សិក្សាលើវិញ្ញាសាទី ៣

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖

" វីរជន ចម្រូង កេណ្ឌ បេសកកម្ម សក្ការបូជា ប្រសិទ្ធនាម " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖

" ធំធេង អង់អាច ជ័យជម្នះ ចងចាំ កសាង " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " មាតុភូមិ មោះមុត " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ជា " ។

### ខ. សំណួរ

១. តើសេនាមឿងជាមនុស្សដូចម្ដេច ?

២. តើសេនាមឿងធ្វើដូចម្ដេចខ្លះ នៅពេលស្រុកមានសង្គ្រាមជាមួយសៀម ?

៣. តើការលះបង់របស់សេនាមឿងទទួលបានលទ្ធផលដូចម្ដេច ?

៤. ដើម្បីសម្ដែងការដឹងគុណចំពោះសេនាមឿងតើគេធ្វើអ្វីខ្លះ ?

៥. តើអ្នកមានទឹកចិត្តដូចម្ដេចចំពោះសេនាមឿង ?


www.elibraryofcambodia.org

## កំណែវិញ្ញាសាទី ៣

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- វីរជន (ន.) ៖ អ្នកហ៊ានលះបង់ អ្នកហ៊ានប្តូរជាអាយុជីវិតដើម្បីជាតិមាតុភូមិ ...។
- ចម្រូង (ន.) ៖ ឫស្សី ឬឈើឬអ្វីៗដែលស្រួច ហើយត្រូវគេដាំដាក់ឱ្យច្រូងច្រាងឡើង។
- កេណ្ឌ (កិ.) ៖ កៀងគរ ប្រមូលគ្នា។
- បេសកកម្ម (កិ.) ៖ បំពេញការងារ ...។
- សក្ការបូជា (ន.) ៖ គ្រឿងសម្រាប់គោរព ...។
- ប្រសិទ្ធនាម (ន.) ៖ ការដាក់ឈ្មោះ ការឱ្យឈ្មោះ ...។

២. បដិសព្ទ

- ធំធេង ≠ តូចចង្អៀត
- អង់អាច ≠ កំសាក
- ជ័យជម្នះ ≠ចាញ់ បរាជ័យ
- ចងចាំ ≠ ភ្លេចភ្លាំង
- កសាង ≠ បំផ្លិចបំផ្លាញ បំផ្លិន

៣. វេវចនសព្ទ

- មាតុភូមិ ប្រទេស នគរ ទឹកដីកំណើត មាតុប្រទេស ប្រទេសជាតិ ...។
- មោះមុត ក្លៀវក្លា អង់អាច ក្លាហាន ពុះពារ ...។

៤. សមិសសព្ទ

- ជា (ន.) ៖ ឈ្មោះពស់មួយប្រភេទ មានពិសខ្លាំង គឺពស់ជា។



www.elibraryofcambodia.org

- ជា (គុ.) ៖ សះស្បើយពីជំងឺ សុខសប្បាយ។
  ឧ. ខ្ញុំទើបនឹងជា ។
- ជា (កិ.) ៖ ពាក្យប្រើសម្រាប់ចង្អុលបង្ហាញក្នុងល្បះ។
  ឧ. ខ្ញុំជាសិស្ស ។
- ចៀរ (កិ.) ៖ ចិត្ត ឬកាត់ឱ្យទៅជាចំនៀរ។ ឧ. ចៀរស្លឹកចេក។

## ខ. ចម្លើយ

១. សេនាមឿង ជាវីរជនដ៏អង់អាចក្លាហាន។ លោកបានធ្វើពលិកម្មដ៏ធំធេង ដើម្បីជាតិមាតុភូមិ។

២. នៅក្នុងគ្រាដែលនគរខ្មែរកើតចម្បាំងជាមួយពួកសៀមឈ្លានពាន សេនាមឿងសុខចិត្ត បូជាជីវិតទាំងខ្លួនលោក ប្រពន្ធ និងកូនពីរនាក់ទៀត។ បេសកកម្មនេះ បង្ហាញពីវីរភាពដ៏មោះមុត ព្រោះលោកហ៊ានលោតចូលក្នុងរណ្ដៅដែលមានសុទ្ធតែចម្រូង ដើម្បីទៅកេណ្ឌទ័ពខ្មោចមកជួយច្បាំងជាមួយទ័ពសៀម។ ការលះបង់របស់សេនាមឿង បង្ហាញពីទឹកចិត្តស្នេហាជាតិមាតុភូមិយ៉ាងមុតមាំរបស់លោក។

៣. ការលះបង់របស់សេនាមឿង ប្រពន្ធ និងកូន ពិតជាបាននាំមកនូវជ័យជម្នះជូននគរខ្មែរ ពោលគឺធ្វើឱ្យពលរដ្ឋខ្មែររំដោះជាតិរួចផុតពីការគ្រួតត្រារបស់ពួកសៀម។

៤. ដើម្បីសម្ដែងនូវការដឹងគុណ និងការគោរពចំពោះសេនាមឿង គេបានកសាងរូបសំណាក និងកន្លែងសម្រាប់ធ្វើសក្ការបូជាចំពោះលោក។ លើសពីនេះ ថែមទាំងបានប្រសិទ្ធនាមថា អ្នកតាឃ្លាំងមឿង ដែលមានទីតាំងនៅក្នុងខេត្តពោធិ៍សាត់។

៥. ខ្ញុំមានចិត្តស្រឡាញ់ និងគោរពសេនាមឿង ព្រោះលោកជាវីរបុរសជាតិខ្មែរ ដែលហ៊ានលះបង់ជីវិតខ្លួនឯង ក្រុមគ្រួសារ ដើម្បីប្រយុទ្ធការពារទឹកដី រួចផុតពីការឈ្លានពានរបស់សៀម។


www.elibraryofcambodia.org

វិញ្ញាសាទី

# ៤ ការគោរពលោកគ្រូ អ្នកគ្រូ



ខ្មែរយើងតែងពោលថា គ្រូជាឪពុកម្ដាយទីពីររបស់យើង។ លោកគ្រូ អ្នកគ្រូជាអ្នកមានគុណ ព្រោះលោកផ្ដល់ចំណេះដឹងឱ្យយើងគ្រប់ៗគ្នា។ សិស្សទាំងឡាយត្រូវគោរពស្រឡាញ់លោកគ្រូ អ្នកគ្រូដោយប្រើពាក្យសម្ដីគួរសម ទន់ភ្លន់សុភាពរាបសា ប្រកបដោយសីលធម៌។ សិស្សទាំងអស់ត្រូវមករៀនឱ្យទៀងទាត់ពេលវេលា គោរពវិន័យសាលា ស្ដាប់ដំបូន្មាន លោកគ្រូ អ្នកគ្រូ។ យើងត្រូវក្រោកឈរ ដោយរក្សាជង្គង់ខ្លួនឱ្យត្រង់សមរម្យ និងលើកដៃទាំងពីរសំពះជម្រាបសួរ នៅពេលគ្រូចូលមកក្នុងបន្ទប់រៀន។ ពេលមករៀនយឺត យើងត្រូវសុំការអនុញ្ញាតចូលរៀនពីលោកគ្រូ អ្នកគ្រូ ជាមុន។ ពេលគ្រូបង្រៀនមេរៀន យើងត្រូវខិតខំត្រងត្រាប់ស្ដាប់ដោយយកចិត្តទុកដាក់ និងកត់ត្រាចំណុចសំខាន់ៗ ព្រមទាំងសួរសំណួរដល់លោកគ្រូ អ្នកគ្រូ ប្រសិនបើយើងមានចម្ងល់ ។



www.elibraryofcambodia.org

ការសម្ដែងរាល់កាយវិការគោរព សំពះ ឥរិយាបថសមរម្យ ព្រមទាំងសម្ដីចរចាពីរោះ គឺជាតម្លៃដែលសិស្សគ្រប់រូបត្រូវមានជាចាំបាច់ចំពោះគ្រូ។ លើសពីនេះ យើងជាសិស្សត្រូវដឹងគុណលោកគ្រូ អ្នកគ្រូ។ តើសព្វថ្ងៃ អ្នកបានប្រកាន់ឥរិយាបថ និងប្រតិបត្តិបានត្រឹមត្រូវ ដូចគំនិតក្នុងអត្ថបទនេះហើយឬនៅ ។

*(ដកស្រង់និងកែសម្រួលពីសៀវភៅ សិក្សាសង្គម ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១)*

## សិក្សាឈើមិញ្ញាសាទី ៤

### ក. រៀនពាក្យ

១. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖
" សុភាពរាបសា ទៀងទាត់ ដឹងគុណ ទន់ភ្លន់ យកចិត្តទុកដាក់ "។
២. ចូររកវេវចនសព្ទនឹងពាក្យ ៖ " យកចិត្តទុកដាក់ " ។
៣. ចូររកសទិសសព្ទនឹងពាក្យ ៖ " តំ " ។

### ខ. សំណួរ

១. តើខ្មែរយើងតែងចាត់ទុកលោកគ្រូ អ្នកគ្រូជាមនុស្សដូចម្ដេច ?
២. តើសិស្សទាំងឡាយត្រូវប្រើពាក្យសម្ដីបែបណាចំពោះគ្រូ ?
៣. តើសិស្សត្រូវធ្វើដូចម្ដេចនៅពេលគ្រូចូលមកដល់ក្នុងថ្នាក់ ? ប្រសិនបើយើងមករៀនយឺតតើត្រូវធ្វើដូចម្ដេចដែរ ?
៤. ក្នុងពេលកំពុងរៀនតើយើងត្រូវប្រកាន់ឥរិយាបថបែបណាដែរ ?
៥. តើសិស្សត្រូវប្រកាន់ឥរិយាបថ និងប្រតិបត្តិដូចម្ដេចចំពោះលោកគ្រូ អ្នកគ្រូ ?


www.elibraryofcambodia.org

## កំណែវិញ្ញាសាទី ៤

### ក. រៀនពាក្យ

១. បដិសព្ទ

- សុភាពរាបសា ≠ ឈ្លើយ ព្រហើន
- ទៀងទាត់ ≠ ម្តងម្កាល
- ដឹងគុណ ≠ រមិលគុណ
- ទន់ភ្លន់ ≠ ច្រលើសបើស ព្រហើន ...
- យកចិត្តទុកដាក់ ≠ ខ្ជីខ្ជា

២. វេវចនសព្ទ

យកចិត្តទុកដាក់ ព្យាយាម ខិតខំ ស្រវាស្រទេញ អត់ធន ...។

៣. សមិសសព្ទ

- គំ (កិ.) ៖ ចាក់ទឹកគ្រាំឱ្យរបើកបាយក្តាំងដែលជាប់បាតឆ្នាំង។ បាយក្តាំងដែលត្រូវទឹករីក នោះហៅថាបាយគំទឹក ឬបាយគំ។
- គុំ (កិ.) ៖ ប៉ងដោយបំណងអាក្រក់ ចងគំនុំ ចងចិត្តព្យាបាទ... ។ ឧ. គុំវាយ។
- គុម្ព (ន.) ៖ ក្រុម ប្រជុំ ដើមរុក្ខជាតិផ្សេងៗ។ ឧ. គុម្ពស្រូវចេកមួយគុម្ព ...។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. ខ្មែរយើងតែងពោលថា គ្រូជាឪពុកម្ដាយទីពីររបស់យើង។ លោកគ្រូ អ្នកគ្រូជាអ្នកមានគុណ ព្រោះគាត់ផ្ដល់ចំណេះដឹងឱ្យយើងគ្រប់ៗគ្នា។

២. សិស្សទាំងឡាយត្រូវគោរពស្រឡាញ់លោកគ្រូ អ្នកគ្រូដោយប្រើពាក្យសម្ដីគួរសម ទន់ភ្លន់សុភាពរាបសាប្រកបដោយសីលធម៌។

៣. នៅពេលគ្រូចូលមកដល់ក្នុងថ្នាក់ យើងត្រូវក្រោកឈរ ដោយរក្សាដងខ្លួនឱ្យត្រង់សមរម្យ និងលើកដៃទាំងពីរសំពះជម្រាបសួរ នៅពេលគ្រូចូលមកក្នុងបន្ទប់រៀន។ ពេលមករៀនយឺត យើងត្រូវសុំការអនុញ្ញាតចូលរៀនពីលោកគ្រូ អ្នកគ្រូជាមុន។

៤. ពេលគ្រូកំពុងបង្រៀនមេរៀន យើងត្រូវខិតខំត្រងត្រាប់ស្ដាប់ ដោយយកចិត្តទុកដាក់ និងកត់ត្រាចំណុចសំខាន់ៗ ព្រមទាំងសួរសំណួរដល់លោកគ្រូ អ្នកគ្រូ ប្រសិនបើមានចម្ងល់។

៥. ការសម្ដែងពល់កាយវិការគោរព សំពះ ឥរិយាបថសមរម្យ ព្រមទាំងសម្ដីចរចាពីរោះ គឺជាតម្លៃដែលសិស្សគ្រប់រូបត្រូវមានជាចាំបាច់ចំពោះគ្រូ។ លើសពីនេះ យើងជាសិស្សត្រូវដឹងគុណលោកគ្រូ អ្នកគ្រូ ។


www.elibraryofcambodia.org

វិញ្ញាសាទី

# ៥ ស្នាដៃកវី និងអ្នកនិពន្ធខ្មែរ



កវី អ្នកនិពន្ធខ្មែរសម័យមុនៗ បានបន្សល់ទុកស្នាដៃអក្សរសិល្ប៍ជាច្រើន ដល់កុលបុត្រកុលធីតាជំនាន់ក្រោយ សម្រាប់អានកម្សាន្ត និងអប់រំ។ រឿងខ្លះជារឿងបែបប្រលោមលោកបុរាណ សរសេរជាពាក្យកាព្យដូចជារឿងកាកី មាយើងជាដើម។ រឿងខ្លះទៀតជាប្រលោមលោកសម័យទំនើបដូចជារឿងផ្កាស្រពោន កុលាបប៉ៃលិន សូផាត ...។ កវីនិពន្ធគាត់តែងឃ្លោងឃ្លាពីរោះរណ្ដំ ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ជក់ចិត្តតាមដំណើររឿងជួនកាល ធ្វើឱ្យអ្នកអានខឹងនឹងតួអង្គកាច ស្រឡាញ់ អាណិតតួអង្គស្លូត។ រឿងខ្លះមានដំណើររឿងវែង តែស្ដាប់ទៅជក់ចិត្ត អាចបំបាត់ការអផ្សុកបាន។ រឿងខ្លះកំប្លែងខ្លី តែមានន័យអប់រំល្អ ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ផ្ទុះសំណើច រសាយទុក្ខព្រួយបានមួយគ្រា ។


www.elibraryofcambodia.org

ក្រៅពីស្នាដៃដែលមានឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទរៀងត្រឹមត្រូវ ក៏នៅមានរឿងខ្លះទៀត ដែលគេចេះចាំតៗគ្នា ពុំមានឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទមិនច្បាស់លាស់ឡើយ។ រឿងបែបនេះ គេតែងហៅថា អក្សរសិល្ប៍ប្រជាប្រិយ។ អក្សរសិល្ប៍ទាក់ទងនិងប្រវត្តិសាស្ត្រទំនៀមទម្លាប់ ប្រពៃណី ជីវភាពរស់នៅ ហើយអប់រំមនុស្សកុំឱ្យប្រព្រឹត្តអំពើអាក្រក់ កុំឱ្យមានចិត្តឈ្នានីសគ្នា ចេះស្រឡាញ់រួមកម្លាំងគ្នា កសាងគ្រួសារ និងសង្គមជាតិឱ្យរីកចម្រើនជានិច្ច ។

(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១)

## សិក្សាឈើចិញ្ចាសានី ៥

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖ " កវី អ្នកនិពន្ធ ឈ្នានីស កុលបុត្រកុលធីតា ប្រលោមលោក អក្សរសិល្ប៍ប្រជាប្រិយ " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖
" ជក់ចិត្ត ទុក្ខព្រួយ ត្រឹមត្រូវ រីកចម្រើន " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " បុត្រកសាង " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ចិត្ត " ។

### ខ. សំណួរ

១. តើកវី អ្នកនិពន្ធខ្មែរសម័យមុនៗបានបន្សល់ទុកស្នាដៃអ្វីខ្លះ ?

២. តើកវីអ្នកនិពន្ធខ្មែរបានតាក់តែងស្នាដៃឱ្យមានលក្ខណៈខុសគ្នាដូចម្តេចខ្លះ ?


www.elibraryofcambodia.org

៣. ក្រៅពីស្នាដៃដែលមានកាលបរិច្ឆេទច្បាស់លាស់ តើអ្នកនិពន្ធខ្មែរបានបន្សល់ស្នាដៃអ្វីខ្លះទៀត ?

៤. តើរឿងទាំងនោះមានខ្លឹមសារទាក់ទងនឹងបញ្ហាអ្វីខ្លះ ?

៥. ចូរស្រង់ពាក្យជាគុណនាម ពីក្នុងអត្ថបទឱ្យបាន៥ពាក្យ ។

## កំណែវិញ្ញាសាទី ៥

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- កវី (ន.) ៖ អ្នកតាក់តែងកំណាព្យ ...។
- អ្នកនិពន្ធ (ន.) ៖ អ្នកតាក់តែង អ្នកសរសេរ ...។
- ឈ្នានីស (ន.) ៖ ការច្រណែន ការកាត់លាភកាត់ប្រយោជន៍គេ។
- កុលបុត្រកុលធីតា (ន.) ៖ កូនប្រុស កូនស្រី។
- ប្រលោមលោក (ន.) ៖ រឿងដែលមានដំណើររឿងវែង។
- អក្សរសិល្ប៍ប្រជាប្រិយ (ន.) ៖ រឿងនិទានទាំងឡាយដែលនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយគ្មានឈ្មោះអ្នកនិពន្ធ និងគ្មានកាលបរិច្ឆេទឡើយ។


www.elibraryofcambodia.org

២. បដិសព្ទ

- ជក់ចិត្ត ≠ ធុញទ្រាន់ក្នុងចិត្ត
- ទុក្ខព្រួយ ≠ សប្បាយរីករាយ
- ត្រឹមត្រូវ ≠ ខុសឆ្គង
- រីកចម្រើន ≠ ហិនហោច

៣. ពាក្យមានន័យដូចគ្នា

- បុត្រ កូន ព្រះរាជបុត្រ កុលបុត្រ កុលធីតា
- កសាង បង្កបង្កើត ស្ថាបនា សាងសង់។

៤. សទិសសព្ទ

- ចិត (កិ.) ៖ កាត់ជាចំណិតៗ។ ឧ. ចិតបន្លែ ...។
- ចិត (ន.) ៖ ពាក្យសម្រាប់រាប់ចំនួនកាត់ខ្លី(ចិតសិប)ដែលស្មើនឹងប្រាំពីរដប់ដង។
  ឧ. ដប់ ម្ភៃ...ចិត ប៉ែត ...។
- ចិត្ត (ន.) ៖ អារម្មណ៍សម្រាប់គិត គំនិត ...។ ឧ. សុភាពចិត្តទូលាយណាស់។
- ចិត្រ (ន.គុ.) ៖ សេចក្ដីល្អ ល្អ ។

## ខ. ចម្លើយ

១. កវីអ្នកនិពន្ធខ្មែរសម័យមុនៗ បានបន្សល់ទុកស្នាដៃអក្សរសិល្ប៍ជាច្រើន ដល់កុលបុត្រកុលធីតាជំនាន់ក្រោយ សម្រាប់អានកម្សាន្ត និងអប់រំ។


www.elibraryofcambodia.org

២. កវីអ្នកនិពន្ធខ្មែរ បានតាក់តែងស្នាដៃឱ្យមានលក្ខណៈខុសៗគ្នាដូចជារឿងខ្លះជារឿងបែបប្រលោមលោកបុរាណសរសេរជាពាក្យកាព្យដូចជារឿងកាកី មាយើងជាដើម។ រឿងខ្លះទៀតជាប្រលោមលោកសម័យទំនើបដូចជា រឿងផ្កាស្រពោន កុលាបប៉ៃលិន សូផាត ...។ កវីនិពន្ធតាក់តែងឃ្លាពីរោះរណ្ដំ ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ជក់ចិត្តតាមដំណើររឿង ជួនកាលធ្វើឱ្យអ្នកអានខឹងនឹងតួអង្គកាចស្រឡាញ់ អាណិតតួអង្គស្លូត។ រឿងខ្លះមានដំណើររឿងវែង តែស្ដាប់ទៅជក់ចិត្ត អាចបំបាត់ការអផ្សុកបាន។ រឿងខ្លះ កំប្លែងខ្លី តែមានន័យអប់រំល្អ ធ្វើឱ្យអ្នកអាន អ្នកស្ដាប់ធ្ងុះសំណើច រសាយទុក្ខព្រួយបានមួយគ្រា។

៣. ក្រៅពីស្នាដៃដែលមានឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទរឿងត្រឹមត្រូវ ក៏នៅមានរឿងខ្លះទៀត ដែលគេចេះចាំតៗគ្នា ពុំមានឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទមិនច្បាស់លាស់ឡើយ។ រឿងបែបនេះហៅថា អក្សរសិល្ប៍ប្រជាប្រិយ ។

៤. រឿងទាំងនោះទាក់ទងនឹងប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ ប្រពៃណីជីវភាពរស់នៅ ហើយអប់រំមនុស្សកុំឱ្យប្រព្រឹត្តអំពើអាក្រក់ កុំឱ្យមានចិត្តឈ្នានីសគ្នា ចេះស្រឡាញ់រួមកម្លាំងគ្នា កសាងគ្រួសារ និងសង្គមជាតិឱ្យរីកចម្រើនជានិច្ច ។

៥. គុណនាមក្នុងអត្ថបទ ៖ បុរាណ ទំនើប វែង អាក្រក់ ស្លូត កាច ...។


www.elibraryofcambodia.org

វិញ្ញាសាទី ៦

# កំណាព្យខ្មែរ



កំណាព្យ គឺជាអត្ថបទពាក្យចួនដែលខ្មែរយើងមានតាំងពីយូរលង់ណាស់មកហើយ។ ជាសក្ខីភាពយើងឃើញមានបុព្វកវីខ្មែរជាច្រើនរូប ដូចជា បណ្ឌិតជ័យនន្ទ សុតន្តប្រីយជាឥន្ទ្រ ក្រមង៉ុយ ព្រះរាជសម្ភារ នូកន ភិក្ខុសោម សន្ធរម៉ុកជាដើម។ អ្នកទាំងអស់សុទ្ធតែជាអ្នកមានស្នាដៃល្បីល្បាញខាងតាក់តែងកំណាព្យ។ កវីសម័យមុនខ្លះនិយមតាក់តែងរឿងដោយប្រើកំណាព្យបទផ្សេងៗ ដូចជារឿងរាមកេរ្តិ៍ ទុំទាវ មាយើង និងល្បើកផ្សេងៗមាន ល្បើកជុចនិងគ្រី ល្បើកអកៗល។ នេះសបញ្ជាក់ ឱ្យឃើញថា តាំងពីបុរាណមក ខ្មែរយើងនិយមចូលចិត្តកំណាព្យណាស់។

កំណាព្យខ្មែរមានច្រើនបទ ហើយត្រូវបានគេប្រើប្រាស់ក្នុងគោលបំណងផ្សេងគ្នា។ បទទាំងនោះមានដូចជា បទកាកគតិ បទព្រហ្មគីតិ


www.elibraryofcambodia.org

បទពំនោល បទភុជង្គលីលា បទពាក្យប្រាំពីរ ពាក្យប្រាំបី ពាក្យប្រាំបួន បទទ្វេមាត្រជាដើម។ បទនីមួយៗសុទ្ធតែពីរោះរណ្ដំលៃលងលាងប្លែកៗគ្នា គួរឱ្យចូលចិត្ត។

ដូច្នេះ យើងជាសិស្សត្រូវយកចិត្តទុកដាក់រៀនសូត្រកំណាព្យខ្មែរឱ្យចេះចាំគ្រប់ៗគ្នា។ ជាងនេះទៅទៀត ត្រូវចេះលើកតម្កើង និងថែរក្សាមរតកនេះឱ្យបានគង់វង្ស ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១)*

## សិក្សាឈើនិញ្ញាសាទី ៦

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖ " សច្ចីភាព បុព្វកវី លៃលងលាង មរតក ភិក្ខុ បទទ្វេមាត្រ ល្បើក " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖
" យូរលង់ ល្បីល្បាញ លើកតម្កើង ថែរក្សា " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ល្បីល្បាញ " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " បទ " ។

### ខ. សំណួរ

១. តើបុព្វកវីខ្មែរមាននរណាខ្លះ ?

២. តើរឿងអ្វីខ្លះដែលកវីតែងជាកំណាព្យ ?

៣. តាមរយៈអត្ថបទនេះតើកំណាព្យខ្មែរយើងមានបទអ្វីខ្លះ ?

៤. តើយើងជាសិស្សត្រូវធ្វើដូចម្ដេចខ្លះ ?


www.elibraryofcambodia.org

## អំណានវិញ្ញាសាទី ៦

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- សក្ខីភាព (ន.) ៖ ភាពជាទីសម្គាល់ តឹកតាង ...។
- បុព្វការី (ន.) ៖ អ្នកធាក់តែងស្នាដៃជំនាន់មុនៗ ។
- ណែងណង (គុ.) ៖ ដែលប្រទាក់គ្នា រណ្ដុំគ្នា ...។
- មរតក (ន.) ៖ ទ្រព្យដំណែលបន្សល់ពីបុគ្គលដែលស្លាប់ ...។
- ភិក្ខុ (ន.) ៖ អ្នកបួស ។
- បទទ្វេមាត្រ (ន.) ៖ បទរបស់កំណាព្យតាមក្បួនតែងម្យ៉ាង។
- ល្បើក (ន.) ៖ រឿងព័រខ្លីៗសម្រាប់សូត្រស្ដាប់កម្សាន្ត ...។

២. បដិសព្ទ

- យូរលង់ ≠ ថ្មីៗ
- ល្បីល្បាញ ≠ ស្ងាត់ស្ងៀម
- លើកតម្កើង ≠ បន្ទុះបង្អាប់
- ថែរក្សា ≠ បំផ្លិចបំផ្លាញ បង្ខិន

៣. វេវចនសព្ទ

- ល្បីល្បាញ ល្បីរន្ទឺ សុសសាយ ខ្ទរខ្ទារ ខ្ទរខ្ទាយ ... ។


www.elibraryofcambodia.org

៤. សទិសសព្ទ

- បទ (ន.) ៖ លំនាំ រឿងហេតុ ដំណើរទំនង ...។
  ឧ. បទចម្រៀង ។
- បត់ (កិ.) ៖ ដើរវេតាមផ្លូវវៀច។ ឧ. ដើរបត់ស្ដាំ ... ។
- បត់ (កិ.) ៖ ត្រឡប់តាមទំនង។ ឧ. បត់ខោអាវ បត់ស្លឹកចេក ...។
- បថ (ន.) ៖ កិរិយា មារយាទ ...។ ឧ. ឥរិយាបថ ។

## ខ. ចម្លើយ

១. បុព្វកវីខ្មែរមានច្រើនរូបដូចជា បណ្ឌិតជ័យនន្ទ សុតន្តប្រីយជាឥន្ទ្រ ក្រមង៉ុយ ព្រះរាជសម្ភារ នូកន ភិក្ខុសោម សន្ធរម៉ុកជាដើម ។

២. រឿងផ្សេងៗដែលកវីតែងជាកំណាព្យមានដូចជា រឿងរាមកេរ្តិ៍ ទុំទាវ មាយើង និងល្បើកផ្សេងៗមាន ល្បើកថុចនិងគ្រី ល្បើកអក។ល។

៣. តាមរយៈអត្ថបទនេះ កំណាព្យខ្មែរមានបទដូចជា បទភាគគតិ បទព្រហ្មគីតិ បទពំនោល បទភុជង្គលីលា បទពាក្យប្រាំពីរ ពាក្យប្រាំបី ពាក្យប្រាំបួន បទទ្វេមាត្រជាដើម។ បទនីមួយៗសុទ្ធតែពីរោះរណ្ដំណែងណងប្លែកៗគ្នាគួរឱ្យចូលចិត្ត។

៤. ដូច្នេះយើងជាសិស្ស ត្រូវយកចិត្តទុកដាក់រៀនសូត្រកំណាព្យខ្មែរឱ្យចេះចាំគ្រប់ៗគ្នា។ ជាងនេះទៅទៀតត្រូវចេះលើកតម្កើង និងថែរក្សាមរតកនេះឱ្យបានគង់វង្ស ។


www.elibraryofcambodia.org

វិញ្ញាសាទី ៧

# បំណងរបស់ខ្ញុំ



មនុស្សគ្រប់រូបតែងមានបំណងប្រាថ្នាផ្សេងៗគ្នា ក្នុងការជ្រើសរើសមុខរបរប្រចាំជីវិត។ អ្នកខ្លះ ចង់ធ្វើមន្ត្រីរាជការក្នុងក្រសួងមន្ទីរនានា អ្នកខ្លះចង់ក្លាយជាពាណិជ្ជករនាំចេញ នាំចូលផលិតផលផ្សេងៗ។ ចំណែកអ្នកខ្លះទៀត ចង់គ្រប់គ្រងកសិដ្ឋានធំៗ ដាំដំណាំឧស្សាហកម្ម ដើម្បីបម្រើរោងចក្រឱ្យមានដំណើរការ។ រីឯរូបខ្ញុំ តាំងពីធំដឹងក្តីមក ខ្ញុំចង់ក្លាយជាអ្នកសរសេរសារព័ត៌មានមួយរូប ដែលមានប្រយោជន៍សម្រាប់ប្រទេសជាតិ។

ប្រសិនបើសម្រេចបំណងនេះ នៅពេលខ្ញុំក្លាយជាអ្នកយកព័ត៌មាន ខ្ញុំនឹងត្រាច់ចរគ្រប់ច្រកល្ហក ធ្វើដំណើរគ្រប់តំបន់ ទោះបីជួបការលំបាក ឬប្រឈមនឹងគ្រោះថ្នាក់ក៏ដោយ។ ខ្ញុំនឹងឈ្មុសឈ្មុលតាមគ្រប់មធ្យោបាយ ដើម្បីពិនិត្យសង្កេតហេតុការណ៍ដល់ទីកន្លែងកើតហេតុដើម្បីយកព័ត៌មានចុះផ្សាយក្នុងទំព័រសារព័ត៌មានជូនមហាជន ប្រជាជនឱ្យទាន់ពេលវេលា។


www.elibraryofcambodia.org

ពេលខ្លះ ខ្ញុំត្រូវចូលក្នុងអង្គប្រជុំ សន្និសីទស្នងការនគរបាល ឬតុលាការនៅពេលមានការកាត់ទោស។ ខ្ញុំនឹងខំតស៊ូអត់ធ្មត់មិនថាយប់ ឬថ្ងៃដោយពិនិត្យ និងថតយកឲ្យបានភាពច្បាស់លាស់ ដើម្បីឱ្យសាធារណជនចាប់អារម្មណ៍ចំពោះដំណឹងថ្មីនិងទាន់ហេតុការណ៍។ ខ្ញុំនឹងសរសេរតែព័ត៌មានដែលពិតប្រាកដ មិនបំភ្លៃការពិត មិនលម្អៀង និងមានអំណះអំណាងច្បាស់លាស់ ។

ខ្ញុំសង្ឃឹមថា ខ្ញុំនឹងក្លាយជាអ្នកសារព័ត៌មានអាជីពម្នាក់ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងមានប្រយោជន៍សម្រាប់ពលរដ្ឋទូទៅ និងប្រទេសជាតិ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១ )*

## សិក្សាឈើទិញ្ញាសាទី ៧

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖ " ពាណិជ្ជករ កសិដ្ឋាន សន្និសីទ សារព័ត៌មាន វិជ្ជាជីវៈ ឈ្មុសឈ្មុល " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖
" ឈ្មុសឈ្មុល លម្អៀង អត់ធ្មត់ ច្បាស់លាស់ " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " អត់ធ្មត់ " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ការណ៍ " ។

### ខ. សំណួរ

១. តើអត្ថបទនេះនិយាយពីអ្វី?

២. តាមរយៈអត្ថបទនេះតើគេមានបំណងចង់ធ្វើអ្វីខ្លះ ?

៣. តើតួអង្គក្នុងអត្ថបទនេះចង់ធ្វើអ្វីដែរ ?

៤. ប្រសិនបើសម្រេចបំណងតើគេនឹងខិតខំដូចម្ដេចខ្លះ ?

៥. ចូរជ្រើសរើសពាក្យទាំងនេះទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ។


www.elibraryofcambodia.org

| | | | |
|---|---|---|---|
| សារព័ត៌មាន | ពាណិជ្ជករ | ជ្រើសរើស | ត្រាច់ចរ |
| ហេតុការណ៍ | មន្ត្រីរាជការ | តំបន់ | ឈ្ងុសឈ្ងុល |

- មនុស្សគ្រប់រូបតែងមានបំណងប្រាថ្នាផ្សេងៗគ្នា ក្នុងការ .......... មុខរបរប្រចាំជីវិត។
- អ្នកខ្លះចង់ធ្វើ ............ ក្នុងក្រសួងមន្ទីរនានា អ្នកខ្លះចង់ក្លាយជា..............ដឹកចេញ នាំចូលផលិតផលផ្សេងៗ។
- នៅពេលខ្ញុំក្លាយជាអ្នកយកព័ត៌មាន ខ្ញុំនឹង .......... គ្រប់ច្រកល្ហកធ្វើដំណើរគ្រប់ ............... ទោះបីជួបការលំបាក ឬប្រឈមនឹងគ្រោះថ្នាក់ក៏ដោយ ។
- ខ្ញុំនឹង ...........តាមគ្រប់មធ្យោបាយ ដើម្បីពិនិត្យសង្កេត .......... ដល់ទីកន្លែងកើតហេតុ ដើម្បីយកព័ត៌មានចុះផ្សាយក្នុងទំព័រ ............. ជូនមហាជន ប្រជាជន ឱ្យទាន់ពេលវេលា ។

## កំណែវិញ្ញាសាទី ៧

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ពាណិជ្ជករ (ន.) ៖ អ្នកជំនួញអ្នករកស៊ីជួញដូរ។
- កសិដ្ឋាន (ន.) ៖ កន្លែងចិញ្ចឹមសត្វ។
- សន្និសីទ (ន.) ៖ ការប្រជុំគ្នាបង្ហាញឬជជែកពីបញ្ហាផ្សេងៗ។
- សារព័ត៌មាន (ន.) ៖ កាសែត ទស្សនាវដ្ដី ...។
- វិជ្ជាជីវៈ (ន.) ៖ មុខរបរ ។
- ឈ្ងុសឈ្ងុល (កិ.) ៖ ខ្លុំល្ងចូល រុលចូល ពុះពារចូល ...។


www.elibraryofcambodia.org

២.បដិសព្ទ

- ឈ្មុសឈ្មុល ≠ ជកថយ
- លម្អៀង ≠ ត្រឹមត្រូវ យុត្តិធម៌
- អត់ធ្មត់ ≠ រាថយ
- ច្បាស់លាស់ ≠ ស្រពេចស្រពិល

៣.វេវចនសព្ទ

- អត់ធ្មត់ ស៊ូទ្រាំ អត់ធន់ អត់ទ្រាំ តស៊ូ ព្យាយាម ។

៤.សទិសសព្ទ

- ការណ៍ (ន.) ៖ រឿងរ៉ាវ រឿងហេតុ ដំណើរ។
  ឧ. សេចក្ដីរាយការណ៍ ។
- កា (ន.) ៖ បំពង់សម្រាប់ដាក់ទឹក។ ឧ. កាទឹក។
- កា (កិ.) ៖ សរសេរលើខ្នងសំបុត្រ ...។
- ការ (កិ.) ៖ រាំង ឃាត់ឃាំង ការពារ ...។
  ឧ. មេមាន់ការកូន ។
- ការ (កិ.) ៖ រៀបចំផ្សំផ្គុំមនុស្សប្រុសស្រីឱ្យមានគូ។
  ឧ. ពុខ្ញុំការកូន ។
- ការ (កិ.) ៖ មូរសរសៃអំបោះដោយមានឈើជាស្នូល
  សម្រាប់រុំ។ ឧ. ការអំបោះ។
- ការ (ន.) ៖ កិច្ចការ ការងារ ...។ ឧ. យើងខំធ្វើការ ... ។
- កាណ៌ា (ន.) ៖ ត្រចៀកស្ដេច។ ឧ. ព្រះកាណ៌ា ។

## ខ.ចម្លើយ

១.អត្ថបទនេះ និយាយអំពីការជ្រើសរើសមុខរបរប្រចាំជីវិតរបស់មនុស្សម្នាក់ៗ ។


www.elibraryofcambodia.org

២. តាមរយៈអត្ថបទនេះ គេមានបំណងផ្សេងៗគ្នាក្នុងការជ្រើសរើសមុខរបរប្រចាំជីវិតរបស់គេ។ អ្នកខ្លះចង់ធ្វើមន្ត្រីរាជការក្នុងក្រសួងមន្ទីរនានា អ្នកខ្លះចង់ក្លាយជាពាណិជ្ជករដឹកចេញ នាំចូលផលិតផលផ្សេងៗ។ ចំណែកអ្នកខ្លះទៀត ចង់គ្រប់គ្រងកសិដ្ឋានធំៗ ដាំដំណាំឧស្សាហកម្ម ដើម្បីបម្រើរោងចក្រ ឱ្យមានដំណើរការ។ល។

៣. តួអង្គក្នុងអត្ថបទនេះចង់ក្លាយជាអ្នកសរសេរសារព័ត៌មានមួយរូប។

៤. ប្រសិនបើសម្រេចបំណង តួអង្គក្នុងអត្ថបទនេះគេនឹងត្រាច់ចរគ្រប់ច្រកល្ហក ប្រឈមនឹងគ្រោះថ្នាក់ ឈ្មុសឈ្មុលតាមគ្រប់មធ្យោបាយ ដើម្បីពិនិត្យសង្កេតហេតុការណ៍ដល់ទីកន្លែងកើតហេតុ ខិតខំតស៊ូអត់ធ្មត់មិនថាយប់ ឬថ្ងៃ ដោយពិនិត្យ និងថតយករូបភាពច្បាស់លាស់ ដើម្បីបម្រើសាធារណជនប្រកបដោយភាពត្រឹមត្រូវ និងច្បាស់លាស់។

៥. ជ្រើសរើសពាក្យទៅបំពេញឃ្លា៖

- មនុស្សគ្រប់រូបតែងមានបំណងប្រាថ្នាផ្សេងៗគ្នា ក្នុងការជ្រើសរើសមុខរបរប្រចាំជីវិត ។
- អ្នកខ្លះចង់ធ្វើមន្ត្រីរាជការ ក្នុងក្រសួងមន្ទីរនានា អ្នកខ្លះចង់ក្លាយជាពាណិជ្ជករដឹកចេញ នាំចូលផលិតផលផ្សេងៗ។
- នៅពេលខ្ញុំក្លាយជាអ្នកយកព័ត៌មាន ខ្ញុំនឹងត្រាច់ចរគ្រប់ច្រកល្ហក ធ្វើដំណើរគ្រប់តំបន់ ទោះបីជួបការលំបាក ឬប្រឈមនឹងគ្រោះថ្នាក់ក៏ដោយ ។
- ខ្ញុំនឹងឈ្មុសឈ្មុលតាមគ្រប់មធ្យោបាយ ដើម្បីពិនិត្យសង្កេតហេតុការណ៍ដល់ទីកន្លែងកើតហេតុ ដើម្បីយកព័ត៌មានចុះផ្សាយក្នុងទំព័រសារព័ត៌មានជូនមហាជន ប្រជាជនឱ្យទាន់ពេលវេលា។


www.elibraryofcambodia.org

វិញ្ញាសាទី
៨
# ប្រាសាទព្រះវិហារ



ប្រាសាទព្រះវិហារស្ថិតនៅយ៉ាងខ្ពស់ត្រដែតលើកំពូលរាបស្មើនៃជួរភ្នំដងរែក ក្នុងខេត្តព្រះវិហារ។ ប្រាសាទនេះបានសាងសង់ឡើងនៅចុងសតវត្សទី៩ ប្រកបដោយក្បូរក្បាច់ចនាល្អប្រណីត ។

នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ ប្រជាជនទូទាំងប្រទេសមានចិត្តសប្បាយរីករាយឥតឧបមា។

ក្រោមការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រាសាទព្រះវិហារដែលជាកេរមរតករបស់ខ្មែរ ត្រូវបានអង្គការយូណេស្កូយល់ព្រមដាក់បញ្ចូលក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោក ។

ក្នុងថ្ងៃដដែលនោះ គ្រប់ក្រសួង មន្ទីរ សាលារៀនបានប្រមូលផ្ដុំគ្នានៅជងទង់ជាតិដើម្បីច្រៀងចម្រៀងជាតិនិងបង្ហូតទង់ជាតិ ព្រមទាំងស្ដាប់


www.elibraryofcambodia.org

សាររបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាល ដែលចាក់ផ្សាយជាសាធារណៈតាមវិទ្យុ និងទូរទស្សន៍។ នៅតាមទីវត្តអារាម ព្រះសង្ឃបានចូងស្គរ និងសូត្រជយន្តោ ប្រសិទ្ធពរជ័យក្នុងឱកាសនោះដែរ ។

យើងទាំងអស់គ្នាជាខ្មែរ ត្រូវសាមគ្គីគ្នាឱ្យស្អិតរមួត រួមកម្លាំងគ្នាប្តេជ្ញាថែរក្សាការពារបេតិកភណ្ឌពិភពលោកនេះ ឱ្យឋិតថេរចីរកាលជានិរន្តរ៍ ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៨ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១)*

## សិក្សាលើខ្លឹមសារទី ៨

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖

" បេតិកភណ្ឌ ជយន្តោ ចីរកាល ប្រសិទ្ធពរជ័យ និរន្តរ៍ " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖

" ខ្ពស់ត្រដែត ចីរកាល និរន្តរ៍ ប្រឹងប្រែង " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ប្រណីត " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " សារ " ។

### ខ. សំណួរ

១. តើប្រាសាទព្រះវិហារស្ថិតនៅឯណា ? ហើយមានលក្ខណៈដូចម្តេច ?

២. តើប្រាសាទព្រះវិហារត្រូវបានដាក់បញ្ចូលក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោកនៅថ្ងៃ ខែ ឆ្នាំណា ?


www.elibraryofcambodia.org

៣. តើយើងជាកូនខ្មែរ ត្រូវធ្វើដូចម្តេចដើម្បីឱ្យបេតិកភណ្ឌនេះស្ថិតស្ថេរគង់វង្ស ?

៤. ចូរបង្ហាញពីគំនិតសំខាន់របស់អត្ថបទ ។

៥. ចូរស្រង់ពាក្យជាសព្ទនាមចង្អុលពីក្នុងអត្ថបទ ឱ្យបាន២ពាក្យ ។

## កំណែវិញ្ញាសាទី ៤

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- បេតិកភណ្ឌ (ន.) ៖ ទ្រព្យសម្បត្តិឬកេរមរតកដែលបន្សល់មក ...។
- ជយន្តោ (ន.) ៖ ធម៌ប្រោះព្រំឱ្យមានជ័យជម្នះ ។
- ចិរកាល (គុ.) ៖ កាលជំយូរ ការយឺនយូរ ...។
- ប្រសិទ្ធពរជ័យ (ន.) ៖ ការឱ្យពរប្រកបដោយការឈ្នះ ។
- និរន្តរ៍ (គុ.កិ.) ៖ ឥតស្រាក ជានិច្ច ឥតឈប់។

២. បដិសព្ទ

- ខ្ពស់ត្រដែត ≠ ទាបគន្ទៀ
- ចិរកាល ≠ កាលជំជិតខាងមុខនេះ
- និរន្តរ៍ ≠ មិនជាប់លាប់ មិនយូរអង្វែង
- ប្រឹងប្រែង ≠ ខ្ជិល ទ្រមក់

៣. វេវចនសព្ទ

- ប្រណីត ឧត្តុង្គឧត្តម ថ្លៃថ្លា ឆើតឆាយ ស្រស់បញ្ចង់ ... ។



www.elibraryofcambodia.org

៤. សមិសសព្ទ

- សារ (ន.) ៖ សំបុត្រ ឬសេចក្ដីថ្លែងជំសំខាន់ដែលចង់ឱ្យគេដឹង។ ឧ. ព្រះរាជសារ ។
- សា (ន.) ៖ ពន្លកថ្មីដែលដុះចេញពីពពួកដំណាំខ្លះដូចជាស្រូវ ...។ ឧ. សាស្រូវ សាខ្ទឹមស្លឹក ។
- សា (កិ.) ៖ មូរឡើងវិញ ត្រឡប់វិញ ធ្វើឡើងវិញ ...។ ឧ. សាកន្ទេល រៀនសាឡើងវិញ។

## ខ. ចម្លើយ

១. ប្រាសាទព្រះវិហារស្ថិតនៅយ៉ាងខ្ពស់ត្រដែត លើកំពូលភ្នំរាបស្មើ នៃជួរភ្នំដងរែក ក្នុងខេត្តព្រះវិហារ។ ប្រាសាទនេះបានសាងសង់ឡើងនៅចុងសតវត្សទី៩ ប្រកបដោយក្បូរក្បាច់រចនាល្អប្រណីត ។

២. ប្រាសាទព្រះវិហារ ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោកនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ ។

៣. យើងទាំងអស់គ្នាជាខ្មែរ ត្រូវសាមគ្គីគ្នាឱ្យស្អិតរមួត រួមកម្លាំងគ្នាប្ដេជ្ញាថែរក្សាការពារ បេតិកភណ្ឌ ពិភពលោកនេះឱ្យឋិតថេរចីរកាលជានិរន្តរ៍ ។

៤. គំនិតសំខាន់របស់អត្ថបទគឺការដាក់បញ្ចូលប្រាសាទព្រះវិហាររបស់ខ្មែរជាបេតិកភណ្ឌ ពិភពលោកនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ ២០០៨ ។

៥. ស្រង់ពាក្យជាសព្វនាមចង្អុលពីក្នុងអត្ថបទ ៖

- ប្រាសាទនេះបានសាងសង់ឡើង...។ ពាក្យ " នេះ " ជាសព្វនាមចង្អុល ។
- ក្នុងថ្ងៃដដែលនោះ គ្រប់ក្រសួង មន្ទីរ ...។ ពាក្យ " នោះ " ជាសព្វនាមចង្អុល ។


www.elibraryofcambodia.org

វិញ្ញាសាទី

# ៦ ផលិតផលនៅប្រទេសកម្ពុជា



ប្រជាជនកម្ពុជាមានស្នាដៃខ្ពស់ក្នុងការផលិតសម្ភារៈប្រើប្រាស់ និងគ្រឿងតុបតែងច្រើនប្រភេទ។ នៅខេត្តសៀមរាប មានអ្នកជំនាញខាងឆ្លាក់ ឬជាប់ឈើ ស្បែក ស្ពាន់ និងថ្មធ្វើជារូបផ្សេងៗដូចជា រូបប្រាសាទ រូបអប្សរា ផ្ដិល ផែក ចង្ក្រាន។ល។ ខេត្តកំពង់ឆ្នាំងសម្បូរផលិតផលធ្វើអំពីឫស្សី ផ្ដៅ រពាក់ និងដី ។ ខេត្តកំពង់ចាម កណ្ដាល ព្រៃវែង និងតាកែវ ប្រជាជនចូលចិត្តផលិតសម្ភារៈពីសរសៃសូត្រ អំបោះ និងកក់។ ពលរដ្ឋនៅទីនោះ ស្ទាត់ជំនាញក្នុងការត្បាញសារុងសូត្រ សំពត់ ផាមួង ហូល និងកន្ទេល។ នៅតំបន់ផ្សេងៗទៀតប្រជាជនផលិតនេសាទុបករណ៍លក្ខណៈគ្រួសារ ដូចជា ឈ្នាង មង អង្រុត អួន និងឧបករណ៍សម្រាប់ធ្វើស្រែចម្ការ ដូចជានង្គ័ល រនាស់ ផាល និងកណ្ដៀវ។ ជាទូទៅ នៅទីក្រុង ឬទីប្រជុំជន


www.elibraryofcambodia.org

គេច្រើនឃើញមានសិប្បកម្មស្លដែក ធ្វើគ្រឿងអលង្ការ ផ្តិលប្រាក់ ចានដែក និងរបស់របរជាច្រើនប្រភេទទៀត។

បច្ចុប្បន្ននេះ ប្រជាជនយើងខិតខំកែច្នៃគុណភាពផលិតផលទាំងនោះ ឱ្យកាន់តែប្រសើរជាបន្តបន្ទាប់ ដើម្បីបម្រើតម្រូវការរបស់អតិថិជនក្នុង និងក្រៅប្រទេស ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១)*

## សិក្សាលើវិញ្ញាសាទី ៩

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖
" មង ឈ្នាង អង្រុត អួន ផាល នេសាទុបករណ៍ សិប្បកម្ម " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖
" ប្រសើរ សម្បូរ ខិតខំ ស្ទាត់ជំនាញ »។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " គុបតែង "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " សូត្រ "។

### ខ. សំណួរ

១. តើប្រជាជនយើងនៅខេត្តសៀមរាប និងខេត្តកំពង់ឆ្នាំងមានជំនាញអ្វីខ្លះ ?

២. ចំណែកប្រជាជន ខេត្តកំពង់ចាម កណ្តាល ព្រៃវែង និងតាកែវមានជំនាញអ្វីខ្លះដែរ ?

៣. ចុះចំណែកប្រជាជននៅតំបន់ផ្សេងទៀត ?

៤. ចូរបង្ហាញពីគំនិតសំខាន់របស់អត្ថបទ ។

៥. តើពាក្យ " យើង " ក្នុងឈ្មោះចុងក្រោយនៃអត្ថបទនេះមានមុខងារជាអ្វី ?


www.elibraryofcambodia.org

## កំណែវិញ្ញាសាទី ៩

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- មង (ន.) ៖ ឈ្មោះប្រដាប់រកត្រីមានក្រឡាដូចសំណាញ់ តែមានកំសួល។
- ឈ្នាង (ន.) ៖ ឈ្មោះប្រដាប់រកត្រីកំពីសធ្វើអំពីបន្ទោះឫស្សីសម្រាប់ជួសឬជញ្ជាត់។
- អង្រុត (ន.) ៖ ឈ្មោះប្រដាប់រកត្រីធ្វើអំពីបន្ទោះឫស្សីសម្រាប់រុត ។
- អួន (ន.) ៖ ឈ្មោះប្រដាប់រកត្រីមានក្រឡាដូចសំណាញ់ មានខ្សែសម្រាប់អូស ។
- ផាល (ន.) ៖ ដែករាងជម រាងជាថាសមានមុខមុតសម្រាប់ភ្ជួរដី។
- នេសាទុបករណ៍ (ន.) ៖ ឧបករណ៍សម្រាប់នេសាទ។
- សិប្បកម្ម (ន.) ៖ ការងារផ្នែកជាង ខាងផលិត។

២. បដិសព្ទ

- ប្រសើរ ≠ អន់ថយ អាក្រក់
- សម្បុរ ≠ ឱ្យត់ខ្សោយ
- ខិតខំ ≠ ខ្ជិលច្រអូស
- ស្ទាត់ជំនាញ ≠ សើៗ ស្ទើរ មិនច្បាស់

៣. វេវចនសព្ទ

- គុបតែង តាក់តែង តែងលម្អ កែខៃ រចនា។

៤. សទិសសព្ទ

- ស្ទូត្រ (ន.) ៖ សរសៃធ្មារល្អិតស្រាវពីដង្កូវនាង។
  ន. សរសៃស្ទូត្រ ក្រមាស្ទូត្រ ។


www.elibraryofcambodia.org

- សូត្រ (កិ.) ៖ ថាតាមពាក្យដែលទន្ទេញចាំមាត់។
  ឧ. សូត្រមេសូត្រ សូត្រធម៌ ។
- សូទ្រ (ន.) ៖ ឈ្មោះក្រុមមនុស្សក្នុងវណ្ណៈទី៤ នៅប្រទេសឥណ្ឌាសម័យដើម ។

## ខ. ចម្លើយ

១. ប្រជាជននៅខេត្តសៀមរាប មានជំនាញខាងឆ្លាក់ឬជាប់ឈើ ស្បែក ស្ពាន់ និងថ្មធ្វើជារូបផ្សេងៗដូចជា រូបប្រាសាទ រូបអប្សរា ផ្តិល វែក ថូផ្កា។ល។ នៅខេត្តកំពង់ឆ្នាំងសម្បូរផលិតផលធ្វើអំពី ឫស្សី ត្នោត រពាក់ និងដី។

២. ប្រជាជននៅខេត្តកំពង់ចាម កណ្តាល ព្រៃវែង និងតាកែវ ចូលចិត្តផលិតសម្ភារៈពីសរសៃសូត្រ អំបោះ និងកក់។ ពលរដ្ឋនៅទីនោះស្ទាត់ជំនាញក្នុងការត្បាញ សារុងសូត្រ សែ្ប ផាមួង ហូល និងកន្ទេល ។

៣. ចំណែកនៅតំបន់ផ្សេងៗទៀត ប្រជាជនផលិត នេសាទុបករណ៍លក្ខណៈគ្រួសារដូចជា ឈ្នាង មង អង្រុត អួន និងឧបករណ៍សម្រាប់ធ្វើស្រែចម្ការដូចជា នង្គ័ល រនាស់ ផាល និងកណ្តៀវ។ ជាទូទៅ នៅទីក្រុង ឬទីប្រជុំជន គេច្រើនឃើញមានសិប្បកម្មស្ថូដែកធ្វើគ្រឿងអលង្ការ ផ្តិលប្រាក់ ចានដែក និងរបស់របរជាច្រើនប្រភេទទៀត។

៤. គំនិតសំខាន់របស់អត្ថបទគឺ ប្រជាជនកម្ពុជាមានស្នាដៃខ្ពស់ក្នុងការផលិតសម្ភារៈប្រើប្រាស់ និងគ្រឿងតុបតែងច្រើនប្រភេទ។

៥. ពាក្យ " យើង " ក្នុងល្បះចុងក្រោយនៃអត្ថបទនេះមានមុខងារជា " គុណនាមកម្មសិទ្ធិ " ។ " បច្ចុប្បន្ននេះ ប្រជាជនយើងខិតខំកែច្នៃគុណភាពផលិតផលទាំងនោះឱ្យកាន់តែប្រសើរជាបន្តបន្ទាប់ ដើម្បីបម្រើតម្រូវការរបស់អតិថិជនក្នុង និងក្រៅប្រទេស " ។


www.elibraryofcambodia.org

# ផលិតផលត្បូងខ្មែរ



រមណីយដ្ឋានផ្កោក ស្ថិតនៅក្នុងស្រុកគិរីវង្ស ខេត្តតាកែវ ជាតំបន់ទេសចរណ៍ដែលគួរឱ្យចាប់អារម្មណ៍ ដោយសារនៅទីនោះមានទឹកជ្រោះ និងជាពិសេសមានលក់សុទ្ធតែត្បូងរបស់ខ្មែរ ។

ក្រៅពីរបរធ្វើស្រែចម្ការ ប្រជាជនខ្មែរបានជីករុករកត្បូងនៅតំបន់នេះ អស់រយៈពេលពី៥ទៅ៦ឆ្នាំហើយ។ ឯការច្នៃត្បូងឱ្យចេញជាពន្លឺចិញ្ចាចចិញ្ចែងនោះ ក៏ជាស្នាដៃជំប៉ិនប្រសប់របស់ខ្មែរយើងដែរ។ នៅតាមតូបតូចៗ ដំបូលប្រក់ស្លឹក មានទូកញ្ចក់យ៉ាងស្អាត ដាក់តាំងលក់ត្បូងខ្មែរព្រោងព្រាត គ្រប់ម៉ូតចម្រុះពណ៌ ជះពន្លឺផ្លេកៗមិនចាញ់ត្បូងនាំចូលពីក្រៅប្រទេសឡើយ ឯតម្លៃទៀតសោតក៏ថោកសមរម្យ។


www.elibraryofcambodia.org

ភ្ញៀវដែលមកកម្សាន្តទីនេះ តែងនិយមគាំទ្រ និងកោតសរសើរពីគុណភាពនៃត្បាញ និងស្នាដៃត្បាញរបស់ប្រជាជនខ្មែរយើង ថាពិតជាល្អមែន ។

យើងជាខ្មែរត្រូវថែរក្សាសម្បត្តិធម្មជាតិដ៏មានតម្លៃនេះ ឱ្យបានឋិតថេរគង់វង្ស និងចេះទាញសម្បត្តិទាំងនេះដោយប្រុងប្រយ័ត្នខ្ពស់ និងមានការទទួលខុសត្រូវ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១)*

## សិក្សាលើវិញ្ញាសាទី ១០

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖ " រមណីយដ្ឋាន ទេសចរណ៍ ចិញ្ចាចចិញ្ចែង ផលិតផល ប៉ិនប្រសប់ " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖
" ប៉ិនប្រសប់ កោតសរសើរ សមរម្យ លើកតម្កើង "។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ចិញ្ចាចចិញ្ចែង "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " ចរ "។

### ខ .សំណួរ

១. តើរមណីយដ្ឋានផ្កាកស្ថិតនៅឯណា ?

២. ក្រៅពីរបរធ្វើស្រែចម្ការ តើប្រជាជននៅទីនោះធ្វើអ្វីខ្លះ ?

៣. តើគេឃើញមានអ្វីខ្លះនៅតាមតូបតូចៗ ?

៤. តើភ្ញៀវទេសចរមកកម្សាន្តនៅទីនោះ មានការយល់ឃើញដូចម្តេចខ្លះ ?

៥. ចូរស្រង់ពាក្យជាគុណនាមកម្មសិទ្ធិពីក្នុងអត្ថបទ ។


www.elibraryofcambodia.org

## អំណានទិញ្ញាសាទី ១០

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- រមណីយដ្ឋាន (ន.) ៖ កន្លែងកម្សាន្ត។
- ទេសចរណ៍ (ន.) ៖ ការធ្វើដំណើរកម្សាន្ត លម្ហែកាយ ចិត្ត។
- ចិញ្ចាចចិញ្ចែង (គុ.) ៖ ដែលភ្លឺផ្លុះរន្ទាល។
- ផលិតផល (ន.) ៖ ផលដែលធ្វើសម្រេចហើយ។
- ប៉ិនប្រសប់ (គុ.) ៖ ស្ទាត់ជំនាញ។

២. បដិសព្ទ

- ប៉ិនប្រសប់ ≠ ស្ទាក់ស្ទើរ មិនច្បាស់លាស់
- កោតសរសើរ ≠ បន្ទុះបង្អាប់
- សមរម្យ ≠ ទាស់ភ្នែក
- លើកតម្កើង ≠ បន្ទុះបង្អាប់ បង្ខូច

៣. វេវចនសព្ទ

- ចិញ្ចាចចិញ្ចែង ត្រចះត្រចង់ រន្ទាល ច្រាល ច្រាលឆ្អៅ។

៤. សទិសសព្ទ

- ចរ (កិ.) ៖ ដើរ ត្រាច់ ទៅ។
  *ឧ.* គាត់ត្រាច់ចរគ្រប់ច្រកល្ហក ។
- ច (ន.) ៖ ឈ្មោះឆ្នាំទី១១ របស់ខ្មែរយើង។
  *ឧ.* ធីតាកើតឆ្នាំច។
- ច (កិ.) ៖ ចាំង លកឈើដោយដឹង។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. រមណីយដ្ឋានផ្គោក ស្ថិតនៅក្នុងស្រុកគិរីវង្ស ខេត្តតាកែវ ជាតំបន់ទេសចរណ៍ដែលគួរឱ្យចាប់អារម្មណ៍ ដោយសារនៅទីនោះមានទឹកជ្រោះ និងជាពិសេសមានលក់សុទ្ធតែត្បូងរបស់ខ្មែរ ។

២. ក្រៅពីរបរធ្វើស្រែចម្ការ ប្រជាជនខ្មែរបានជីករុករកត្បូងនៅតំបន់នេះ អស់រយៈពេលពី៥ទៅ៦ឆ្នាំហើយ។ ឯការច្នៃត្បូងឱ្យចេញជាពន្លឺចិញ្ចាចចិញ្ចែងនោះ ក៏ជាស្នាដៃដ៏ប៉ិនប្រសប់របស់ខ្មែរយើងដែរ។

៣.នៅតាមតូបតូចៗ ជំបូលប្រក់ស្លឹកមានទូកញ្ចក់យ៉ាងស្អាត ដាក់តាំងលក់ត្បូងខ្មែរព្រោងព្រាត គ្រប់ម៉ូតចម្រុះពណ៌ ជះពន្លឺផ្លេកៗ មិនចាញ់ត្បូងនាំចូលពីក្រៅប្រទេសឡើយ ឯតម្លៃទៀតសោតក៏ថោកសមរម្យ។

៤. ភ្ញៀវដែលមកកម្សាន្តទីនេះ តែងនិយមគាំទ្រ និងកោតសរសើរពីគុណភាពនៃត្បូង និងស្នាដៃច្នៃត្បូងរបស់ប្រជាជនខ្មែរយើង ថាពិតជាល្អមែន ។

៥. ពាក្យជាគុណនាមកម្មសិទ្ធិក្នុងអត្ថបទគឺ " យើង " ៖ " ... ច្នៃត្បូងរបស់ប្រជាជនខ្មែរយើង ថាពិតជាល្អមែន "។


www.elibraryofcambodia.org

វិញ្ញាសាទី

# ១១ ផលប្រយោជន៍នៃការអានសៀវភៅ







នៅប្រទេសចម្រើនជឿនលឿននានា គេនិយមអានសៀវភៅណាស់។ ការអានសៀវភៅ ទស្សនាវដ្ដី កាសែត និងឯកសារផ្សេងៗ ជាការសំខាន់។ ការអាននាំឱ្យយើងទទួលបានព័ត៌មានថ្មីៗ និងមានចំណេះដឹងជ្រៅជ្រះ។

អ្នកចូលចិត្តអានសៀវភៅច្រើន ច្រើនតែមានប្រាជ្ញាឈ្លាសវៃ យល់ដឹងទូលំទូលាយ ហើយមានភាពទាន់សម័យទៀតផង។ សៀវភៅសិក្សា និងឯកសារល្អៗជាច្រើនទៀត មានប្រយោជន៍ណាស់សម្រាប់ការសិក្សារៀនសូត្ររបស់កូនៗប្រុសស្រីទាំងឡាយ។ បច្ចុប្បន្ននេះ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា កំពុងតែរីកចម្រើនជឿនលឿន។ ក្រៅពីសៀវភៅសិក្សា


www.elibraryofcambodia.org

និងឯកសារផ្សេងៗ យើងក៏អាចទទួលបានចំណេះដឹង និងព័ត៌មានជាច្រើនទៀត តាមរយៈទូរស័ព្ទដៃទំនើបៗ កុំព្យូទ័រផងដែរ។

អាស្រ័យហេតុនេះ ក្នុងការអានកូនត្រូវចេះជ្រើសរើសប្រភេទសៀវភៅ ឬឯកសារណាដែលមានខ្លឹមសារល្អសមស្រប និងមានប្រយោជន៍ ទាំងផ្នែកចំណេះដឹងមុខរបរ វិទ្យាសាស្ត្រ និងសីលធម៌ល្អ។ កូនៗត្រូវចៀសវាងការអានសៀវភៅ ឯកសារ ឬស្រាវជ្រាវមើលរឿងណាដែលមិនមានប្រយោជន៍ ភ្លើតភ្លើន គ្មានសីលធម៌ ព្រោះនាំឱ្យខាតពេលវេលា និងមានគ្រោះថ្នាក់។

ដូច្នេះ ចូរអ្នកខិតខំអានសៀវភៅល្អៗ និងមានប្រយោជន៍ឱ្យបានច្រើន ដើម្បីឱ្យក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ ឆ្នាំ ១៩៩៣)*

## សិក្ខាលំហាត់ទី ១១

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖

" បច្ចេកវិទ្យា វិទ្យាសាស្ត្រ ភ្លើតភ្លើន " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖

" ជ្រៅជ្រះ ឈ្លាសវៃ ទាន់សម័យ ជឿនលឿន "។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ឈ្លាសវៃ "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " វៃ "។


www.elibraryofcambodia.org

## ខ .សំណួរ

១. តើអ្នកអានសៀវភៅច្រើនជាមនុស្សដូចម្ដេច ?

២. តើយើងអាចទទួលចំណេះដឹង និងព័ត៌មានផ្សេងៗតាមរយៈអ្វីខ្លះ ?

៣. តើយើងត្រូវជ្រើសរើសសៀវភៅបែបណាសម្រាប់អាន ?

៤. តើយើងជាសិស្សត្រូវជៀសវាងអានសៀវភៅបែបណាខ្លះ ?

៥. ចូរជ្រើសរើសពាក្យជាសព្វនាមទៅបំពេញល្បះខាងក្រោម ឱ្យបានត្រឹមត្រូវ ៖

| | | | |
|---|---|---|---|
| ខ្ញុំ | គាត់ | ពួកគេ | វា |

- បុប្ផាទៅរៀនទៀងទាត់ពេលវេលាជារៀងរាល់ថ្ងៃ។ ........... មិនដែលគេចវេះសាលាឡើយ។
- ថ្ងៃនេះ ................ ទៅអានសៀវភៅនៅបណ្ណាល័យជាមួយមិត្តរបស់ខ្ញុំ។
- សំនិងមិត្តភក្ដិរបស់គេស្រឡាញ់គ្នាណាស់។ .............. មិនដែលឈ្លោះប្រកែកគ្នាឡើយ។
- ពូកែវជួយបង្រៀនកូនគាត់រាល់យប់។ .............. ចង់ឱ្យកូនគាត់រៀនពូកែ ។


www.elibraryofcambodia.org

# កំណែវិញ្ញាសាទី ១១

## ក. រៀនពាក្យ

### ១. ពន្យល់ពាក្យ

- បច្ចេកវិទ្យា (ន.) ៖ វិជ្ជា ចំណេះដឹងខាងជំនាញខាងគ្រឿងម៉ាស៊ីន ...។
- វិទ្យាសាស្ត្រ (ន.) ៖ វិជ្ជាដែលមានក្បួនខ្នាត វិជ្ជាមួយពួកដែលគេរកឃើញ ដោយការផ្សំធាតុតាមក្បួនបច្ចេកទេស។
- ឆ្អើតឆ្អើន (គុ.) ៖ ជ្រួលជ្រើម ព្រហើន ឆ្អើតឆ្អាច ...។

### ២. បដិសព្ទ

- ព្រៅព្រះ ≠ សើៗ ភក់កំផែល
- ឈ្លាសវៃ ≠ ស្ទក់ទម្រន់
- ទាន់សម័យ ≠ អន់ថយ
- ជឿនលឿន ≠ អន់ថយ ...

### ៣. វេវចនសព្ទ

- ឈ្លាសវៃ ភាងវៃ វៃឆ្លាត រវាសវៃ រហ័សរហួន ឆ្លាត។

### ៤. សទិសសព្ទ

- វៃ (គុ.) ៖ ឈ្លាស រហ័ស ភ្លាម ប៉ិន ...។ ឧ. ក្របៀកវៃ។
- វ័យ (ន.) ៖ អាយុ។ ឧ. ជីតាខ្ញុំមានវ័យចំណាស់ហើយ...។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. អ្នកចូលចិត្តអានសៀវភៅច្រើន គេច្រើនតែជាមនុស្សមានប្រាជ្ញាឈ្លាសវៃ យល់ដឹងទូលំទូលាយ ហើយមានភាពទាន់សម័យទៀតផង។

២. យើងអាចទទួលចំណេះដឹង និងព័ត៌មានផ្សេងៗតាមរយៈសៀវភៅសិក្សា និងឯកសារល្អៗជាច្រើនទៀត។ លើសពីនេះ យើងក៏អាចទទួលបានចំណេះដឹង និងព័ត៌មានជាច្រើនទៀត តាមរយៈទូរស័ព្ទដៃទំនើបៗ កុំព្យូទ័រ។ល។

៣. ក្នុងការអាន យើងត្រូវចេះជ្រើសរើសប្រភេទសៀវភៅ ឬឯកសារណាដែលមាន ខ្លឹមសារល្អ សមស្រប និងមានប្រយោជន៍ ទាំងផ្នែកចំណេះដឹង មុខរបរ វិទ្យាសាស្ត្រ និងសីលធម៌ល្អ។

៤. យើងជាសិស្សត្រូវជៀសវាងការអានសៀវភៅណា ឯកសារ ឬស្រាវជ្រាវមើលរឿងណាដែលមិនមានប្រយោជន៍ភ្លើតភ្លើន គ្មានសីលធម៌ ព្រោះនាំឱ្យខាតពេលវេលា និងមានគ្រោះថ្នាក់ ។

៥. ជ្រើសរើសពាក្យជាសព្វនាមទៅបំពេញឃ្លាខាងក្រោម ឱ្យបានត្រឹមត្រូវ៖

- បុប្ផាទៅរៀនទៀងទាត់ពេលវេលាជារៀងរាល់ថ្ងៃ។ វាមិនដែលគេចវេះសាលាឡើយ។
- ថ្ងៃនេះខ្ញុំទៅអានសៀវភៅនៅបណ្ណាល័យជាមួយមិត្តរបស់ខ្ញុំ។
- សំនិងមិត្តភក្ដិរបស់គេស្រឡាញ់គ្នាណាស់។ ពួកគេមិនដែលឈ្លោះប្រកែកគ្នាឡើយ។
- ពូកែវជួយបង្រៀនកូនគាត់រាល់យប់។ គាត់ចង់ឱ្យកូនគាត់រៀនពូកែ ។


www.elibraryofcambodia.org

វិញ្ញាសាទី
១២

# កូនល្អ





កូនល្អ គឺជាកូនដែលមានចំណេះវិជ្ជា និងមានសីលធម៌រស់នៅល្អផូរផង់។ នៅក្នុងគ្រួសារ កូនល្អចេះស្ដាប់ដំបូន្មានមាតាបិតា យាយតា បងប្អូន មិនដើរលេងផ្ដេសផ្ដាស និងមានឥរិយាបថល្អប្រពៃ។ នៅសាលារៀន កូនល្អជាអ្នកឧិហាត រៀនសូត្រ ក្រេបយកចំណេះដឹងគ្រប់បែបយ៉ាងពីលោកគ្រូ អ្នកគ្រូ ស្ដាប់ការទូន្មានរបស់គ្រូ គោរពវិន័យសាលា ចេះស្រឡាញ់គ្នា និងជួយយកអាសាមិត្តភក្តិ នៅពេលមានទុក្ខធុរៈ ។

កូនល្អបរិបូរដោយសុជីវធម៌និងចំណេះវិជ្ជា។ ពេលធ្វើកិច្ចការអ្វីមួយ គេមានការពិចារណា ប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ មានការទទួលខុសត្រូវហ៊ានទទួលកំហុស និងចេះភ្ញាក់រឭក។ កូនល្អតែងគោរពចាស់ព្រឹទ្ធាចារ្យ ឪពុកម្ដាយ លោកគ្រូ អ្នកគ្រូ និងគោរពច្បាប់ ។


www.elibraryofcambodia.org

កូនល្អនាំឱ្យខ្លួនឯង គ្រួសារ វង្សត្រកូល និងសង្គមមានកិត្តិយសខ្ពង់ខ្ពស់ ថ្លៃថ្នូរ ឧត្តុង្គឧត្តម ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ ឆ្នាំ ១៩៩៣)*

## សិក្សាលើវិញ្ញាសាទី ១២

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖

" សុជីវធម៌ វង្សត្រកូល ថ្នូរផង់ និបាត ឧត្តុង្គឧត្តម "។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖

" ផ្ដេសផ្ដាស ល្អប្រពៃ ប្រយ័ត្ន ថ្លៃថ្នូរ កិត្តិយស "។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ឧត្តុង្គឧត្តម "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " បត់ "។

### ខ. សំណួរ

១. តើកូនល្អ ជាកូនដូចម្ដេច ?

២. នៅក្នុងគ្រួសារ តើកូនល្អត្រូវប្រកាន់ឥរិយាបថបែបណាខ្លះ ?

៣. នៅសាលារៀន តើកូនល្អត្រូវប្រកាន់ឥរិយាបថបែបណាខ្លះដែរ ?

៤. ការធ្វើខ្លួនឱ្យក្លាយជាកូនល្អ មានប្រយោជន៍ដូចម្ដេចខ្លះ ?

៥. ចូរបំពេញអត្ថបទខាងក្រោម ឱ្យបានត្រឹមត្រូវ ៖

> កូនល្អបរិបូរដោយសុជីវធម៌ និង..........។ ពេលធ្វើកិច្ចការអ្វីមួយ គេមានការ ......... ប្រកបដោយ....... ខ្ពស់មានការទទួលខុសត្រូវ ហ៊ានទទួលកំហុស និងចេះ...............។ កូនល្អ តែងគោរពចាស់............ ឪពុកម្ដាយ លោកគ្រូ អ្នកគ្រូ និង.......... ។
>
> កូនល្អនាំឱ្យខ្លួនឯង គ្រួសារ.....................និងសង្គមមានកិត្តិយសខ្ពង់ខ្ពស់ ថ្លៃថ្នូរ ................។



www.elibraryofcambodia.org

# អំណានវិញ្ញាសាទី ១២

## ក. រៀនពាក្យ

### ១. ពន្យល់ពាក្យ

- សុជីវធម៌ (ន.) ៖ ការប្រព្រឹត្តិល្អប្រពៃ ឥរិយាបថល្អប្រសើរ ...។
- វង្សត្រកូល (ន.) ៖ ពូជអម្បូរ តំណាត្រកូល ... ។
- ផូរផង់ (គុ.) ៖ ល្អក្រៃលែង លើសលប់ ។
- និហាត (គុ.) ៖ ដែលសង្វាត ព្យាយាម ...។
- ឧត្តុង្គឧត្តម (គុ.) ៖ ខ្ពង់ខ្ពស់ ប្រសើរថ្លៃថ្លា។

### ២. បដិសព្ទ

- ផ្គេសផ្គាស ≠ ត្រឹមត្រូវ
- ល្អប្រពៃ ≠ អាក្រក់ថ្មជាតិ
- ប្រយ័ត្ន ≠ ធ្វេសប្រហែស
- ថ្លៃថ្នូរ ≠ ថោកទាប
- កិត្តិយស ≠ អាប់យស

### ៣. វេវចនសព្ទ

- ឧត្តុង្គឧត្តម ខ្ពង់ខ្ពស់ ប្រសើរ ថ្លៃថ្លា ។

### ៤. សទិសសព្ទ

- បត់ (កិ.) ៖ ត្រឡប់តាមទំនង ត្រឡប់ប្រសព្វមុខ។
  ឧ. បត់សំពត់ បត់ស្លឹកចេក ...។
- បត់ (គុ.) ៖ ដែលបត់ពង់ពេន វៀចពង់ពេន ...។
  ឧ. ផ្លូវបត់បែន ។



www.elibraryofcambodia.org

- បទ (ន.) ៖ ដំណើរទំនង លំនាំ។ ឧ.បទចម្រៀង
  បទភាគគតិ ...។
- បថ (ន.) ៖ បែបផែន វិន័យ គន្លង។
  ឧ. នាងមានឥរិយាបថល្អ ...។

## ខ. ចម្លើយ

១. កូនល្អ គឺជាកូនដែលមានចំណេះវិជ្ជា និងមានសីលធម៌រស់នៅល្អផូរផង់ ។

២. នៅក្នុងគ្រួសារ កូនល្អចេះស្ដាប់ដំបូន្មានមាតាបិតា យាយតា បងប្អូន មិនដើរលេងផ្ដេសផ្ដាស និងមានឥរិយាបថល្អប្រពៃ ។

៣. នៅសាលារៀន កូនល្អជាអ្នកឧិហាត រៀនសូត្រ ក្រេបយកចំណេះដឹងគ្រប់បែបយ៉ាងពីលោកគ្រូ អ្នកគ្រូ ស្ដាប់ការទូន្មានរបស់គ្រូ គោរពវិន័យសាលា ចេះស្រឡាញ់គ្នា និងជួយយកអាសាមិត្តភក្ដិនៅពេលមានទុក្ខធុរៈ ។

៤. ការធ្វើខ្លួនឱ្យក្លាយជាកូនល្អ នាំឱ្យខ្លួនឯង គ្រួសារ វង្សត្រកូល និងសង្គមមានកិត្តិយសខ្ពង់ខ្ពស់ ថ្លៃថ្នូរ ឧត្តុង្គឧត្តម ដូចអរិយប្រទេសនានាដែរ។

៥. ចូរបំពេញអត្ថបទខាងក្រោម ឱ្យបានត្រឹមត្រូវ ៖ កូនល្អបរិបូរដោយសុជីវធម៌ និងចំណេះវិជ្ជា។ ពេលធ្វើកិច្ចការអ្វីមួយ គេមានការពិចារណា ប្រកបដោយបម្រុងប្រយ័ត្នខ្ពស់ មានការទទួលខុសត្រូវ ហ៊ានទទួលកំហុស និងចេះភ្ញាក់រឭក។ កូនល្អ តែងគោរពចាស់ព្រឹទ្ធាចារ្យ ឪពុកម្ដាយ លោកគ្រូ អ្នកគ្រូ និងគោរពច្បាប់។ កូនល្អនាំឱ្យខ្លួនឯង គ្រួសារ វង្សត្រកូល និងសង្គមមានកិត្តិយសខ្ពង់ខ្ពស់ ថ្លៃថ្នូរ ឧត្តុង្គឧត្តម។


www.elibraryofcambodia.org

វិញ្ញាសាទី ១៣

# មាតុភូមិជាទីស្នេហា



កម្ពុជា ជាប្រទេសកំណើតរបស់ខ្ញុំ។ ទឹកដីនេះ ជាកេរតំណែលដ៏ពិសិដ្ឋរបស់ដូនតារបស់ខ្ញុំ។ ទីនេះជាកន្លែងផ្តល់កំណើត និងការរស់នៅយ៉ាងសុខសាន្តរបស់ខ្ញុំតាំងពីកុមារភាព។ មាតុភូមិកម្ពុជាសម្បូរដោយព្រៃឈើ ភ្នំ ត្រពាំងបឹងបួ ព្រែក ទន្លេ សមុទ្រ សត្វព្រៃ សត្វស្លាប ត្រី និងរ៉ែគ្រប់ប្រភេទ។ បឹងទន្លេសាបមានត្រីទឹកសាបច្រើនជាងគេលើសកលលោក។ វាលស្រែធំល្វឹងល្វើយដាច់កន្ទុយភ្នែក។ ភោគផលស្រូវអង្ករអាចចិញ្ចឹមជីវិតប្រជាជនយ៉ាងបរិបូរនិងអាចនាំយកទៅលក់នៅឯបរទេសបានយ៉ាងច្រើនទៀតផង។ បុព្វបុរសខ្មែរ បានបន្សល់ទុកនូវប្រាង្គប្រាសាទជាច្រើនឥតគណនាដូចជា ប្រាសាទបន្ទាយស្រី ព្រះវិហារ បាយ័ន នាគព័ន្ធ បាពួន បាគងជាដើម ជាពិសេសប្រាសាទអង្គរវត្ត ដែលជាប្រភពថវិកាជាតិយ៉ាងសំខាន់សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ។


www.elibraryofcambodia.org

ខ្ញុំស្រឡាញ់ទឹកដីខ្មែរណាស់ ព្រោះជាទឹកដីដ៏សម្បូរបែបទៅដោយសម្បត្តិធម្មជាតិ និងប្រាង្គប្រាសាទនានា ព្រមទាំងជាទីកន្លែងរស់នៅយ៉ាងសុខសាន្តរបស់គ្រួសារខ្ញុំ ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ ឆ្នាំ ១៩៩៣ )*

## សិក្សាលើមេរៀនទី ១៣

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖

"កេរដំណែល ភោគផល ពិសិដ្ឋ ច្រើនឥតគណនា ប្រាង្គប្រាសាទ" ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖

"ធំល្វឹងល្វើយ សុខសាន្ត បរិបូរ ច្រើនឥតគណនា" ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ "ពិសិដ្ឋ" ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ "វត្ត" ។

### ខ. សំណួរ

១. តើតួអង្គក្នុងអត្ថបទនិយាយដូចម្ដេចខ្លះពីប្រទេសកម្ពុជា ?

២. តើប្រទេសកម្ពុជាសម្បូរសម្បត្តិអ្វីខ្លះ ?

៣. តើបុព្វបុរសខ្មែរ បានបន្សល់ទុកនូវប្រាង្គប្រាសាទណាខ្លះ ?

៤. តើតួអង្គក្នុងអត្ថបទ ចាប់អារម្មណ៍ដូចម្ដេចខ្លះចំពោះទឹកដីខ្មែរ ?

៥. ចូរស្រង់ឈ្មោះ ពីក្នុងអត្ថបទដែលមានប្រើសព្ទនាមកម្មសិទ្ធិ។



www.elibraryofcambodia.org

## អំណានទី ១៣

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- កេរដំណែល (ន.) ៖ អ្វីៗដែលបន្សល់ទុកពីដូនតា ...។
- ភោគផល (ន.) ៖ ផលដែលទទួលបាន ទ្រព្យ ... ។
- ពិសិដ្ឋ (គុ.) ៖ ដែលខ្ពង់ខ្ពស់ ប្រសើរ។
- ច្រើនឥតគណនា (គុ.) ៖ ដែលច្រើនមិនអាចរាប់បាន។
- ប្រាង្គប្រាសាទ (ន.) ៖ ប្រាសាទដែលមានកំពូលខ្ពស់។

២. បដិសព្ទ

- ធំល្វឹងល្វើយ ≠ តូចចង្អៀត
- សុខសាន្ត ≠ ទុក្ខព្រួយ
- បរិបូរ ≠ ខ្សត់ខ្សោយ
- ច្រើនឥតគណនា ≠ តិចតួច

៣. វេវចនសព្ទ

- ពិសិដ្ឋ ខ្ពង់ខ្ពស់ ប្រសើរ ថ្លៃថ្លា ឧត្តុង្គឧត្តម ក្រៃលែង ។

៤. សទិសសព្ទ

- វត្ត (ន.គុ.) ៖ ទីអារាម កន្លែងធ្វើបុណ្យទាន។ ឧ. វត្តអង្គរន វត្តលង្កា ។
- វដ្ដ (ន.) ៖ ការវិលទៅមក ...។ ឧ. វដ្ដសង្សារ វិលកើត វិលស្លាប់ ។
- វាត់ (កិ.) ៖ វាលាស់ចុងឡើងលើ ...។ ឧ. វាត់សន្ទូច ។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. ឃ្លាអង្គក្នុងអត្ថបទនិយាយថា ៖ " កម្ពុជា ជាប្រទេសកំណើតរបស់ខ្ញុំ។ ទឹកដីនេះ ជាកេរតំណែលដ៏ពិសិដ្ឋ របស់ដូនតារបស់ខ្ញុំ។ ទីនេះ ជាកន្លែងផ្ដល់កំណើត និងការរស់នៅយ៉ាងសុខសាន្តរបស់ខ្ញុំតាំងពីកុមារភាព " ។

២. មាតុភូមិកម្ពុជាសម្បូរដោយ ព្រៃឈើ ភ្នំ ត្រពាំងបឹងបួ ព្រែក ទន្លេ សមុទ្រ សត្វព្រៃ ត្រី សត្វស្លាប និងរ៉ែគ្រប់ប្រភេទ។ បឹងទន្លេសាបមានត្រីទឹកសាបច្រើនជាងគេលើសកលលោក។ វាលស្រែធំល្វឹងល្វើយដាច់កន្ទុយភ្នែក។ គោតផលស្រូវអង្ករអាចចិញ្ចឹមជីវិតប្រជាជនយ៉ាងបរិបូរ និងអាចនាំយកទៅលក់នៅឯបរទេសបានយ៉ាងច្រើនទៀតផង។

៣. បុព្វបុរសខ្មែរ បានបន្សល់ទុកនូវប្រាង្គប្រាសាទជាច្រើនឥតគណនា ដូចជា ប្រាសាទបន្ទាយស្រី ព្រះវិហារ បាយ័ន នាគព័ន្ធ បាពួន បាគងជាដើម ជាពិសេសប្រាសាទអង្គរវត្ត ដែលជាប្រភពធនធានថវិកាជាតិ យ៉ាងសំខាន់សម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិ។

៤. ឃ្លាអង្គក្នុងអត្ថបទចាប់អារម្មណ៍ថា " ខ្ញុំស្រឡាញ់ទឹកដីខ្មែរណាស់ ព្រោះជាទឹកដីដ៏សម្បូរបែបទៅដោយសម្បត្តិធម្មជាតិ និងប្រាង្គប្រាសាទនានា ព្រមទាំងជាទីកន្លែងរស់នៅយ៉ាងសុខសាន្តរបស់គ្រួសារខ្ញុំ " ។

៥. សព្វនាមកម្មសិទ្ធិមានក្នុងអត្ថបទគឺ " ខ្ញុំ " ៖ " កម្ពុជាជាប្រទេសកំណើតរបស់ខ្ញុំ។ ... "


www.elibraryofcambodia.org

វិញ្ញាសាទី ១៤

# ចម្លាក់ប្រាសាទអង្គរវត្ត



ប្រាសាទអង្គរវត្តជាប្រាសាទស្អាតជាងគេរបស់ព្រះរាជាណាចក្រកម្ពុជា។ ប្រាសាទនេះមាន ចម្លាក់ប្រកបដោយក្បូរក្បាច់រចនាល្អវិសេស។

ចម្លាក់ទាំងនេះមានជាផ្កាភ្ញី វល្លិ៍ រូបមនុស្ស ម្រឹគីម្រឹគា បក្សាបក្សី យក្ស ទេព្ដា អប្សរា ។ល។ រូបចម្លាក់ទាំងនោះសុទ្ធតែសម្ផិតសម្ផាងឡើង ប្រកបដោយកាយវិការរស់រវើកផុសលេចចេញពីថ្ម ហាក់បីដូចជាមានជីវិតពិតៗ។ ចម្លាក់អប្សរាជាបវរកញ្ញាស្ងួតស្អាតលម្អដោយគ្រឿងអលង្ការល្អវិចិត្រ ឈរវេវាំល្ងួតល្ងន់ញញឹមពព្រាយ រូសរាយរាក់ទាក់ទៅរកភ្ញៀវទេសចរ។ ស្នាមញញឹមនេះ បង្ហាញពីភាពរុងរឿងក្សេមក្សាន្តរបស់ជាតិខ្មែរ។ សិល្បករខ្មែរ មានឧបនិស្ស័យ និងជំនាញខាងចម្លាក់ ។


www.elibraryofcambodia.org

ចំណោះវិជ្ជានេះ បានញ៉ាំងឱ្យខ្មែរកាន់តែមានគំនិតឆ្នៃប្រឌិត កម្រិតខ្ពស់ថែមទៀត។ វណ្ណកម្មជាងចម្លាក់របស់ខ្មែរលើផ្ទាំងសិលាប្រាសាទទាំងឡាយ បានធ្វើឱ្យកម្ពុជាយើងមានកិត្តិសព្ទល្បីខ្ចរខ្ចាយពេញក្នុងតំបន់ និងលើពិភពលោក ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ ឆ្នាំ ១៩៩៣ )*

## សិក្សាលើមេរៀនអានទី ១៤

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖

" ម្រឹគីម្រឹគា ស្ទូត សម្ផិតសម្ផាង ល្វតល្វន់ អលង្ការ សិលា ឧបនិស្ស័យ ខ្ចរខ្ចាយ វណ្ណកម្ម " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖

" រស់រវើក ល្វតល្វន់ រួសរាយ ល្បីខ្ចរខ្ចាយ " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ឆ្នៃប្រឌិត " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " សព្ទ " ។

៥. ចូរបំពេញអត្ថបទខាងក្រោមឱ្យបានត្រឹមត្រូវ ៖

### ខ. សំណួរ

ប្រាសាទ ............. ជាប្រាសាទស្អាតជាងគេរបស់ព្រះរាជាណាចក្រកម្ពុជា ។ ប្រាសាទនេះ មានចម្លាក់ប្រកបដោយ .............. ល្អវិសេស ។ ចម្លាក់ទាំងនេះមានជាផ្កាភ្ញី វល្លិ៍ រូបមនុស្ស .............. បក្សាបក្សី យក្ស ទេព្តា អប្សរា ។ល។ រូបចម្លាក់ទាំងនោះសុទ្ធតែ ............... ឡើងប្រកបដោយកាយវិការរស់រវើក ផុស ......... ពីថ្ម ហាក់បីដូចជាមានជីវិតពិតៗ។ ពិសេសចម្លាក់ ......... ជាបវរកញ្ញាស្ទូគ៌ា លម្អដោយគ្រឿង ......... ល្អវិចិត្រ ឈរវេវាំល្វតល្វន់ញញឹមពព្រាយ ............. ទៀវទេសចរ។ ស្នាមញញឹមនេះ បង្ហាញពីភាពរុងរឿង .................. របស់ជាតិខ្មែរ ។



www.elibraryofcambodia.org

## អំណានទី ១៤

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ម្រឹគីម្រឹគា (ន.) ៖ ពពួកសត្វព្រៃទាំងឡាយ។
- សួគ៌ា (ន.) ៖ ឋានសួគ៌ ឋានទេវតា។
- សម្អិតសម្អាង (គុ.) ៖ តាក់តែង តែងលម្អ។
- ល្វតល្វន់ (គុ.) ៖ ដែលទន់ភ្លន់ ...។
- អលង្ការ (ន.) ៖ គ្រឿងគុបតែងខ្លួន គ្រឿងលម្អខ្លួន។ *ឧ.* ខ្សែ ក។
- សិលា (ន.) ៖ ថ្ម។
- ឧបនិស្ស័យ (ន.) ៖ អ្វីៗដែលមានស្រាប់ពីមុនមក ជំនាញស្រាប់ ។
- ខ្វះខ្វាយ (គុ.) ៖ សុសសាយ ផ្សាយទៅ ...។
- វណ្ណកម្ម (ន.) ៖ ស្នាដៃ ...។

២.បដិសព្ទ

- រស់រវើក ≠ រីងស្ងួត
- ល្វតល្វន់ ≠ រឹងក្រញង់
- ស្រសាយ ≠ ឆ្មើងឆ្មៃ
- ល្បីខ្វះខ្វាយ ≠ ស្ងាត់ប្រងំ

៣.វេវចនសព្ទ

- ឆ្នៃប្រឌិត កែច្នៃ កែលម្អ កែខៃ ។

៤.សទិសសព្ទ

- សព្ទ (ន.) ៖ សូរសំឡេង។ *ឧ.* ផ្គរលាន់បញ្ចេញសូរស័ព្ទកងរំពង។
- សាប់ (កិ.) ៖ ចិញ្ច្រាំញាប់ស្រាលៗ ...។ *ឧ.* សាប់ផ្លែក្រសក់ ។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. ប្រាសាទអង្គរវត្ត ជាប្រាសាទស្អាតជាងគេរបស់ព្រះរាជាណាចក្រកម្ពុជា។ ប្រាសាទនេះមានចម្លាក់ប្រកបដោយក្បូរក្បាច់រចនាល្អវិសេស ។

២. ប្រាសាទអង្គរវត្តមានចម្លាក់ផ្កាភ្ញី វល្លិ រូបមនុស្ស ម្រឹគីម្រឹគា បក្សាបក្សី យក្ស ទេព្ដា អប្សរា។ល។

៣. រូបចម្លាក់ទាំងនោះសុទ្ធតែសម្អិតសម្អាងឡើង ប្រកបដោយកាយវិការរស់រវើក ផុសលេចចេញពីថ្ម ហាក់បីដូចជាមានជីវិតពិតៗ។ ចម្លាក់អប្សរា ជាបវរកញ្ញាសួគ៌ា លម្អដោយគ្រឿងអលង្ការល្អវិចិត្រ ឈររេរាំល្វតល្វន់ ញញឹមពព្រាយរួសរាយរាក់ទាក់ទៅរកភ្ញៀវទេសចរ ។

៤. ប្រាសាទអង្គរវត្តស្ថិតក្នុងខេត្តសៀមរាប ។

៥. បំពេញល្បះឱ្យបានត្រឹមត្រូវ ៖ ប្រាសាទអង្គរវត្ត ជាប្រាសាទស្អាតជាងគេរបស់ព្រះរាជាណាចក្រកម្ពុជា។ ប្រាសាទនេះ មានចម្លាក់ប្រកបដោយក្បូរក្បាច់រចនាល្អវិសេស។ ចម្លាក់ទាំងនេះមានជាផ្កាភ្ញី វល្លិ រូបមនុស្ស ម្រឹគីម្រឹគា បក្សាបក្សី យក្ស ទេព្ដា អប្សរា។ល។ រូបចម្លាក់ទាំងនោះសុទ្ធតែសម្អិតសម្អាងឡើង ប្រកបដោយកាយវិការរស់រវើក ផុសលេចចេញពីថ្ម ហាក់បីដូចជាមានជីវិតពិតៗ។ ចម្លាក់អប្សរា ជាបវរកញ្ញាសួគ៌ាលម្អដោយគ្រឿងអលង្ការល្អវិចិត្រ ឈររេរាំល្វតល្វន់ញញឹមពព្រាយ រួសរាយរាក់ទាក់ទៅរកភ្ញៀវទេសចរ។ ស្នាមញញឹមនេះ បង្ហាញពីភាពរុងរឿង ក្សេមក្សាន្តរបស់ជាតិខ្មែរ ។


www.elibraryofcambodia.org

វិញ្ញាសាទី ១៥

# សុភមង្គលរបស់ខ្ញុំ



រាល់ពេលខ្ញុំស្រមៃឃើញឪពុកម្តាយខ្ញុំ ខ្ញុំលួចញញឹមម្នាក់ឯង ខ្ញុំសែនរំភើប និងសប្បាយរីករាយក្នុងចិត្តក្រៃលែង ។

លោកទាំងពីរជាអ្នកផ្តល់កំណើត និងជាកសិណានៃជីវិតរបស់ខ្ញុំ។ ខ្ញុំនៅចាំច្បាស់អំពីការថែទាំយ៉ាងម៉ឺងម៉ាត់ ការរាំងស្កាត់ចំពោះអំពើអាក្រក់ទាំងឡាយដែលកើតមានឡើងចំពោះខ្ញុំ។ រស់នៅក្បែរលោក ខ្ញុំមានភាពកក់ក្តៅ និងសេចក្តីសុខសាន្តយ៉ាងពេញលេញ។ ខ្ញុំមានការទុកចិត្តទាំងស្រុងចំពោះលោក។ នឹកដល់ទំនុកចិត្តដ៏ពិសិដ្ឋនេះ ខ្ញុំមិនចង់ឃ្លាតពីពួកគាត់ឡើយ។ ខ្ញុំចង់តែនៅនែបនិត្យជិតម៉ែពុកខ្ញុំរាល់ពេលវេលា។

ខ្ញុំសប្បាយចិត្តណាស់ កាលណាអនុស្សាវរីយ៍នៃគ្រួសារបានមកសណ្ឋិតក្នុងប្រនិតញាណរបស់ខ្ញុំ ។


www.elibraryofcambodia.org

អ្វីដែលធ្វើឱ្យខ្ញុំនឹកមិនភ្លេចគឺផ្ទះ ភូមិឋាន ជីវិតកាលពីកុមារភាព និងបងប្អូនញាតិសន្តាន។ អ្វីៗទាំងអស់នេះហើយ ដែលផ្តល់សុភមង្គលដល់ខ្ញុំជាអលជ្ជី ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ ឆ្នាំ១៩៩៣ )*

## សិក្សាលើធិញ្ញាសាទី ១៥

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖

" កសិណ សណ្ឋិត ពិសិដ្ឋ ប្រនិតញាណ អនុស្សាវរីយ៍ អលជ្ជី សុភមង្គល " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖

" ពេញលេញ សុខសាន្ត ម៉ឺងម៉ាត់ សុភមង្គល " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ម៉ឺងម៉ាត់ " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " រាំង " ។

### ខ. សំណួរ

១. រាល់ពេលតួអង្គក្នុងអត្ថបទនឹកស្រមៃដល់ឪពុកម្តាយរបស់គេ តើគេមានអារម្មណ៍ដូចម្តេច ?

២. តើតួអង្គក្នុងអត្ថបទនេះ យល់យ៉ាងណាចំពោះឪពុកម្តាយរបស់គេ?

៣. ហេតុអ្វីបានជាយើងត្រូវស្រឡាញ់ និងគោរពឪពុកម្តាយ ?

៤. ចូរស្រង់ពាក្យជាសព្ទនាមពីក្នុងអត្ថបទឱ្យបាន៣ពាក្យ ។


www.elibraryofcambodia.org

៥. ចូរបំពេញកថាខណ្ឌខាងក្រោមឱ្យបានត្រឹមត្រូវ ៖

> លោកទាំងពីរជាអ្នកផ្តល់កំណើត និងជា ............ នៃជីវិតរបស់ខ្ញុំ។ ខ្ញុំនៅចាំច្បាស់អំពីការថែទាំយ៉ាង ............ ការការពារចំពោះអំពើអាក្រក់ទាំងឡាយ ដែលកើតមានឡើងចំពោះខ្ញុំ។ រស់នៅក្បែរលោក ខ្ញុំមាន ................ និងសេចក្តីសុខសាន្តយ៉ាងពេញលេញ។ ខ្ញុំមានសេចក្តី ...................... ទាំងស្រុងចំពោះលោក។ នឹកដល់ទំនុកចិត្តដ៏ ............... នេះ ខ្ញុំមិនចង់ឃ្លាតពីពួកគាត់ឡើយ។ ខ្ញុំចង់តែនៅ ............... ជិតម៉ែឪពុកខ្ញុំរាល់ពេលវេលា។

## អំណានវិញ្ញាសាទី ១៥

### ក. រៀនពាក្យ

#### ១. ពន្យល់ពាក្យ

- កសិណ (ន.) ៖ រូបតាងជាសម្គាល់ តឹកតាង ។
- សណ្ឋិត (កិ.) ៖ ឋិតនៅស៊ប់ តាំងស៊ប់ ។
- ពិសិដ្ឋ (គុ.) ៖ ដែលឧត្តមខ្ពង់ខ្ពស់ប្រសើរ ថ្លៃថ្លាផុតគេ។
- ប្រនិតញាណ (ន.) ៖ ការនឹកស្រមៃ ការប្រនិតក្នុងចិត្ត ។
- អនុស្សាវរីយ៍ (ន.) ៖ អ្វីៗដែលកន្លងហួស ។
- អលជ្ជី (គុ.) ៖ ជាប្រចាំ ជាប់ឥតដាច់ ។
- សុភមង្គល (ន.) ៖ សេចក្តីសុខទាំងផ្លូវកាយ ចិត្ត។



www.elibraryofcambodia.org

២. បដិសព្ទ

- ពេញលេញ ≠ ស្ទាក់ស្ទើរ
- សុខសាន្ត ≠ ទុក្ខព្រួយ
- មុឹងម៉ាត់ ≠ ធូររលុង
- សុភមង្គល ≠ អពមង្គល

៣. វេវចនសព្ទ

- មុឹងម៉ាត់ ហ្មត់ចត់ ច្បាស់លាស់ មធ្យ័ត ។

៤. សទិសសព្ទ

- រាំង (កិ.) ៖ បិទខ្ទប់ ឃាំង បាំងខ្ទប់។ ឧ. រាំងផ្លូវ រាំងទ្វារ ។
- រាំង (ន.) ៖ ឈ្មោះឈើមានច្រើនប្រភេទមានរាំងភ្នំ រាំងអន្លក់ ...។ ឧ. របោយត្រួយរាំង ។
- រាំង (គុ.) ៖ ដែលឥតទឹកភ្លៀង។ ឧ. ឆ្នាំនេះរាំងយូរខែណាស់។

## ខ. ចម្លើយ

១. រាល់ពេលតួអង្គក្នុងអត្ថបទនឹកស្រមៃដល់ឪពុកម្ដាយរបស់គេ គេតែងលួចញញឹមម្នាក់ឯង គេសែនរំភើប និងសប្បាយរីករាយក្នុងចិត្តក្រៃលែង ។

២. តួអង្គក្នុងអត្ថបទនេះ គេយល់ថាឪពុកម្ដាយរបស់គេ ជាអ្នកផ្ដល់កំណើតនិងជាកសិណនៃជីវិតរបស់គេ។ គេនៅចាំច្បាស់អំពីការថែទាំយ៉ាងមុឹងម៉ាត់ ការរាំងស្កាត់ចំពោះអំពើអាក្រក់ទាំងឡាយដែលកើតមានឡើងចំពោះរូបគេ។ រស់នៅក្បែរឪពុកម្ដាយរបស់គេ គេមានភាពកក់ក្ដៅ និងសេចក្ដីសុខសាន្តយ៉ាងពេញលេញ។ គេមានសេចក្ដីទុកចិត្ត ទាំងស្រុងចំពោះឪពុកម្ដាយរបស់គេ។


www.elibraryofcambodia.org

៣. បានជាយើងត្រូវស្រឡាញ់ និងគោរពឪពុកម្ដាយរបស់យើងព្រោះលោកជាអ្នកផ្ដល់កំណើតដល់យើង ជាអ្នកចិញ្ចឹមបីបាច់ថែរក្សាថ្នាក់ថ្នមបមបី ឱ្យយើងសិក្សារៀនសូត្រ អប់រំណែនាំឱ្យដើរផ្លូវល្អមានអនាគតបវររុងរឿង ។

៤. ស្រង់ពាក្យជាសព្វនាមពីក្នុងអត្ថបទ ៖ ខ្ញុំ លោក ពួកគាត់ ។

៥. បំពេញកថាខណ្ឌខាងក្រោមឱ្យបានត្រឹមត្រូវ ៖

លោកទាំងពីរជាអ្នកផ្ដល់កំណើត និងជាកសិណានៃជីវិតរបស់ខ្ញុំ។ ខ្ញុំនៅចាំច្បាស់អំពីការថែទាំយ៉ាងម៉ឺងម៉ាត់ ការរាំងស្កាត់ចំពោះអំពើអាក្រក់ទាំងឡាយដែលកើតមានឡើងចំពោះខ្ញុំ។រស់នៅក្បែរលោក ខ្ញុំមានភាពកក់ក្ដៅ និងសេចក្ដីសុខសាន្តយ៉ាងពេញលេញ។ ខ្ញុំមានសេចក្ដីទុកចិត្ត ទាំងស្រុងចំពោះលោក។ នឹកដល់ទំនុកចិត្តដ៏ពិសិដ្ឋនេះ ខ្ញុំមិនចង់ឃ្លាតពីពួកគាត់ឡើយ។ ខ្ញុំចង់តែនៅនែបនិត្យជិតម៉ែឪពុកខ្ញុំរាល់ពេលវេលា ។


www.elibraryofcambodia.org

វិញ្ញាសាទី

# ១៦ ល្វើយមុនស្រណុកក្រោយ



ពេលមុនភ្លៀង ធាតុអាកាសក្ដៅស្អុះស្អាប់ ។ ខ្យល់បក់បោកផង់ធូលី និងស្លឹកឈើហុយសំពោងធ្លាក់ពាសពេញដី។ ពពកខ្មៅរសាត់ខ្ទួលខ្ទាញ់។

ភ្លៀងចាប់ផ្ដើមធ្លាក់ ផ្លេកបន្ទោរ ផ្គរ រន្ទះសម្ដែងមហិទ្ធិឫទ្ធិលាន់សូរកញ្ច្រើតញ្រ័ចពី។ ព្យុះព្យោមា បញ្ចេញកំហឹងពុះពោរ។ សត្វនិករងាញ័រញាក់ភ័យទ្វេតំរូញខ្លួនកំព្រោន ។

ភ្លៀងរាំង មេឃស្រឡះ ព្រះសុរិយារះចិញ្ចែងចិញ្ចាច។ ធម្មជាតិស្រស់បំព្រង មនុស្សសត្វប្រកបការងារចិញ្ចឹមជីវិតជាថ្មី។

យ៉ាងណាមិញ ការសិក្សារៀនសូត្រក៏មានលំអានដូចនេះដែរ។ នៅពេលកំពុងរៀនសិស្សានុសិស្សមានការលំបាក ខ្វល់ខ្វាយ ត្រូវពុះពារជម្នះ


www.elibraryofcambodia.org

នបសគ្គនានា ដើម្បីស្វែងរកចំណេះដឹងសម្រាប់ប្រកបមុខរបរណាមួយសមស្របក្នុងអនាគតកាល។ មានចំណេះវិជ្ជា ជីវិតរស់នៅរបស់យើងក៏មានតម្លៃឧត្តុង្គឧត្តមប្រសើរក្រៃលែងដែរ ។

សុភាសិតបុរាណមួយបានពោលថា " នឿយមុន ស្រណុកក្រោយ " " ចង់ឆ្ងាញ់ឱ្យរកអន្លក់ ចង់ស្រណុកឱ្យនឿយពីក្មេង " ឬ " ក្រោយភ្លៀងមេឃស្រឡះ " ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ ឆ្នាំ១៩៩៣ )*

## សិក្សាលើវិញ្ញាសាទី ១៦

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖ " មហិទ្ធិឫទ្ធិ ករក្រើក ខ្នួលខ្នាញ់ ព្យុះព្យោមា ប្រឹថពី សត្តនិករ លំអាន "។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖
" ស្រស់បំព្រង ខ្វល់ខ្វាយ ស្អុះស្អាប់ ស្រឡះ " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " លំអាន " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " កំពុង " ។

### ខ. សំណួរ

១. តើអាកាសធាតុមុនភ្លៀងមានលក្ខណៈដូចម្តេច ?

២. នៅពេលភ្លៀងចាប់ផ្តើមធ្លាក់ អាកាសធាតុមានលក្ខណៈដូចម្តេច ?

៣. ក្រោយពេលភ្លៀងធ្លាក់ អាកាសធាតុមានលក្ខណៈដូចម្តេចដែរ ?

៤. តើគេប្រៀបធៀបការសិក្សាយ៉ាងដូចម្តេចដែរ ?

៥. ចូរអានសុភាសិតក្នុងអត្ថបទនេះឡើងវិញឱ្យបានបីចប់ ។


www.elibraryofcambodia.org

# អំណានទិញ្ញាសាទី ១៦

## ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- មហិទ្ធិឫទ្ធិ (ន.) ៖ អំណាច ចេស្ដា ឫទ្ធិ។
- កក្រើក (កិ.) ៖ រញ្ជួយ រំពើកឡើង។
- ខ្វល់ខ្វាយ (គុ.) ៖ ដេរដាស ពពាក់ពពូន។
- ព្យុះព្យាមា (ន.) ៖ ខ្យល់ព្យុះកំណាច។
- ប្រឹថពី (ន.) ៖ ផែនដី។
- សត្តនិករ (ន.) ៖ សត្វទាំងឡាយ។
- លំអាន (ន.) ៖ លំនាំ ផ្លូវ។

២. បដិសព្ទ

- ស្រស់បំព្រង ≠ ស្វិតស្រពោន
- ខ្វល់ខ្វាយ ≠ រីករាយ
- ស្អុះស្អាប់ ≠ រហើយរំភើយ
- ស្រឡះ ≠ ងងឹតស្លុប

៣. ផរិចនសព្ទ

- លំអាន ផ្លូវ មាគ៌ា លំនាំ ។

៤. សមិសសព្ទ

- កំពុង (កិ.) ៖ កាលដែលជាប់ក្នុងរវាង ជាប់រវល់។ ន. កំពុង ហូបបាយ ។


www.elibraryofcambodia.org

- កំពុង (គុ.) ៖ ដែលពេញកំពូកកណ្តាលមិនរាបស្មើទេ។
ឧ. អង្ករពេញកំពុងតៅ ។
- កំពង់ (ន.) ៖ ទីកន្លែងនៅមាត់ទឹកដែលមហាជនចុះឡើង ឬចំណតទូក។ ឧ. កំពង់ទូក ។

## ខ. ចម្លើយ

១. ពេលមុនភ្លៀង ធាតុអាកាសក្តៅស្អុះស្អាប់។ ខ្យល់បក់បោកផង់ធូលី និងស្លឹកឈើហុយសំពោងធ្លាក់ពាសពេញដី។ ពពកខ្មៅរសាត់ខ្វល់ខ្វាញ់ ។

២. នៅពេលភ្លៀងចាប់ផ្តើមធ្លាក់ ផ្លេកបន្ទោរ ផ្គរ រន្ទះសម្តែងមហិទ្ធិឫទ្ធិលាន់សូរក្រើកក្រើនថ្លី។ ព្យុះព្យោមា បញ្ចេញកំហឹងពុះពារ។ សត្វនិករងាញ័រញាក់ភ័យរន្ធត់រួញខ្លួនកំព្រោន ។

៣. នៅពេលភ្លៀងរាំង មេឃស្រឡះ ព្រះសូរិយារះចិញ្ចែងចិញ្ចាច។ ធម្មជាតិស្រស់បំព្រង មនុស្សសត្វប្រកបការងារចិញ្ចឹមជីវិតជាថ្មី។

៤. ការសិក្សារៀនសូត្រក៏មានលំអានដូចនេះដែរ។ នៅពេលកំពុងរៀនសិស្សានុសិស្សមានការលំបាក ខ្វល់ខ្វាយ ត្រូវពុះពារជម្នះឧបសគ្គនានា ដើម្បីស្វែងរកចំណេះដឹងសម្រាប់ប្រកបមុខរបរណាមួយសមស្របក្នុងអនាគតកាល។ មានចំណេះវិជ្ជា ជីវិតរស់នៅរបស់យើងក៏មានតម្លៃឧត្តុង្គឧត្តមប្រសើរក្រៃលែងដែរ ។

៥. សុភាសិតបុរាណមួយពោលថា " ឡើយមុន ស្រណុកក្រោយ " " ចង់ឆ្ងាញ់ឱ្យរកអន្លក់ ចង់ស្រណុកឱ្យនឿយពីក្មេង " ឬ " ក្រោយភ្លៀងមេឃស្រឡះ " ។


www.elibraryofcambodia.org

វិញ្ញាសាទី
១៧

# ព្រះពុទ្ធសាសនា



ព្រះពុទ្ធសាសនា ជាកេរមរតកនៃដូនតាយើងតាំងពីបុរាណកាលមក។ ព្រះសមណគោតមជាព្រះសម្មាសម្ពុទ្ធបរមគ្រូរបស់ពុទ្ធបរិស័ទ។ ព្រះអង្គជាកំណើតនៅរដ្ឋនេប៉ាល់ (ប្រទេសឥណ្ឌាបុរាណ)។

ព្រះពុទ្ធសាសនាជាសាសនាបម្រើផលប្រយោជន៍មនុស្សជាតិទូទៅដែលមានឧត្តមគតិផ្អែកលើមនុស្សធម៌ជាមូលដ្ឋាន។ ព្រះពុទ្ធសាសនាជាពាក្យប្រៀនប្រដៅប្រកបដោយមធុរស ដឹកនាំមនុស្សលោកឱ្យសម្រេចផលប្រយោជន៍ដ៏ឧត្ដុង្គឧត្ដម ឱ្យបានសុខក្សេមក្សាន្តចម្រើនរុងរឿងក្នុងបច្ចុប្បន្ន និងអនាគតផ្សារភ្ជាប់សាមគ្គីភាពរវាងមនុស្សជាតិនានា មិនបៀតបៀន ឈ្នានីសគ្នា។ ព្រះពុទ្ធោវាទញ៉ាំងអ្នកដែលជឿស៊ប់ ហើយប្រតិបត្តិបានត្រឹមត្រូវឱ្យឈានឡើងពីហីនភាពទៅកាន់ឧត្ដមភាព ពីពាលភាព ទៅ


www.elibraryofcambodia.org

កាន់បណ្ឌិតភាពរៀងរហូតដល់ផុតទុក្ខភ័យគ្រប់បែបយ៉ាង។ ធម៌ទេសនា គឺជាការណែនាំទូន្មានពន្យល់មនុស្សលោកឱ្យយល់ អំពីបញ្ហាជីវិតរបស់ខ្លួន ឱ្យស្គាល់មធ្យោបាយគ្រប់បែបយ៉ាង សម្រាប់កែច្នៃលំអានជីវភាព ឱ្យបានសុខស្រួល ចម្រើនរុងរឿងខ្ពង់ខ្ពស់។ ព្រះពុទ្ធសាសនា តម្រង់ទិសមនុស្សឱ្យរស់នៅក្នុងក្របខ័ណ្ឌ វិន័យក្រឹត្យក្រមសីលធម៌ មនុស្សធម៌ និងយុត្តិធម៌ ។

អាស្រ័យហេតុនេះ ពុទ្ធសាសនិកជនគួរផុសនាត់សតិបញ្ញាស្មារតីពិចារណាឱ្យបានជ្រួតជ្រាប ច្បាស់លាស់អំពីបំណងប្រាថ្នានៃព្រះពុទ្ធសាសនានេះ ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ ឆ្នាំ១៩៩៣)*

## សិក្សាឈើទិញ្ញាសាទី ១៧

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖ " បរមគ្រូ ពុទ្ធបរិស័ទ ហីនភាព ពុទ្ធោវាទ មធុរស ក្រឹត្យក្រម ពុទ្ធសាសនិកជន យុត្តិធម៌ មនុស្សធម៌ " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖
" ពាលភាព ហីនភាព ខ្ពង់ខ្ពស់ ច្បាស់លាស់ " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ឧត្តុង្គឧត្តម " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " រដ្ឋ " ។


www.elibraryofcambodia.org

## ខ. សំណួរ

១. តើព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ប្រកាន់យកសាសនាណាជាសាសនារបស់រដ្ឋ ?

២. តើព្រះពុទ្ធសាសនាបម្រើឱ្យផលប្រយោជន៍នរណាខ្លះ ?

៣. តើព្រះពុទ្ធសាសនា ប្រៀនប្រដៅមនុស្សឱ្យសម្រេចផលដូចម្ដេចខ្លះ ?

៤. តើព្រះធម៌ទេសនា ណែនាំអប់រំទូន្មានមនុស្សឱ្យយ៉ាងដូចម្ដេចខ្លះដែរ ?

៥. តើពុទ្ធសាសនិកជន ត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីឱ្យសមស្របតាមបំណងព្រះពុទ្ធសាសនា ?

# កំណែវិញ្ញាសាទី ១៧

## ក. រៀនពាក្យ

### ១. ពន្យល់ពាក្យ

- បរមគ្រូ (ន.) ៖ អ្នកបង្រៀនដ៏ឧត្ដមខ្ពង់ខ្ពស់ គ្រូដ៏ប្រសើរ។
- ពុទ្ធបរិស័ទ (ន.) ៖ ជនដែលជឿ និងគោរពតាមព្រះពុទ្ធ។
- ហីនភាព (គុ.) ៖ ភាពទន់ទាប ភាពថោកថយពុំប្រសើរ។
- ពុទ្ធោវាទ (ន.) ៖ ពាក្យទូន្មានរបស់ព្រះពុទ្ធ។


www.elibraryofcambodia.org

- មធុរស (គុ.) ៖ ទន់ភ្លន់ ផ្អែមល្ហែម។
- ក្រឹត្យក្រម (ន.) ៖ ក្បួនខ្នាត ច្បាប់។
- ពុទ្ធសាសនិកជន (ន.) ៖ ជនទាំងឡាយដែលគោរពព្រះពុទ្ធសាសនា។
- យុត្តិធម៌ (ន.) ៖ សេចក្ដីត្រឹមត្រូវ មិនលម្អៀង។
- មនុស្សធម៌ (ន.) ៖ អំពើល្អ អំពើបុណ្យ។

២.បដិសព្ទ

- ពាលភាព ≠ បណ្ឌិតភាព
- ហីនភាព ≠ វឌ្ឍនភាព
- ខ្ពង់ខ្ពស់ ≠ ថោកទាប
- ច្បាស់លាស់ ≠ ស្រពេចស្រពិល

៣.វេវចនសព្ទ

- ឧត្តុង្គឧត្តម ខ្ពង់ខ្ពស់ ប្រសើរ ថ្លៃថ្លា រុងរឿង ។

៤.សទិសសព្ទ

- រដ្ឋ (ន.) ៖ ប្រទេស នគរ។ *ឧ.* ប្រជាពលរដ្ឋ ។
- រត្នឬរតន៍ (ន.) ៖ ត្បូង ពេជ្រ កែវ។ *ឧ.* ថ្ងៃបុណ្យ នារីពាក់លម្អដោយត្បូងរត្ន ល្អឥតខ្ចោះ។
- រត់ (កិ.) ៖ ទាញកន្ត្រាក់ផ្ដាច់ដោយបង្ខំ។ *ឧ.* ទាញរ៉ាត់ផ្ដាច់ភ្លាមទៅ ។


www.elibraryofcambodia.org

## ខ. ចម្លើយ

១. ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ប្រកាន់យកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

២. ព្រះពុទ្ធសាសនា ជាសាសនាបម្រើផលប្រយោជន៍ឱ្យមនុស្សជាតិទូទៅដែលមានឧត្ដមគតិ ផ្អែកលើមនុស្សធម៌ជាមូលដ្ឋាន ។

៣. ព្រះពុទ្ធសាសនា ប្រៀនប្រដៅប្រកបដោយមធុរស ដឹកនាំមនុស្សលោកឱ្យសម្រេចផលប្រយោជន៍ដ៏ឧត្ដុង្គឧត្ដម ឱ្យបានសុខក្សេមក្សាន្ដចម្រើនរុងរឿងក្នុងបច្ចុប្បន្ន និងអនាគត ផ្សារភ្ជាប់សាមគ្គីភាពរវាងមនុស្សជាតិនានា មិនបៀតបៀន ឈ្នានីសន្ដា ឱ្យឈានឡើងពីហីនភាពទៅកាន់ឧត្ដមភាព ពីពាលភាពទៅកាន់បណ្ឌិតភាពរៀងរហូតដល់ផុតទុក្ខភ័យគ្រប់បែបយ៉ាង។

៤. ព្រះធម៌ទេសនា ណែនាំអប់រំទូន្មានមនុស្សលោកឱ្យយល់អំពីបញ្ហាជីវិតរបស់ខ្លួន ឱ្យស្គាល់មធ្យោបាយគ្រប់បែបយ៉ាង សម្រាប់កែច្នៃលំអានជីវភាពឱ្យបានសុខស្រួល ចម្រើនរុងរឿង ខ្ពង់ខ្ពស់។ ព្រះពុទ្ធសាសនា តម្រង់ទិសមនុស្សឱ្យរស់នៅក្នុងក្របខ័ណ្ឌ វិន័យក្រឹត្យក្រមសីលធម៌ មនុស្សធម៌ និងយុត្តិធម៌ ។

៥. ដើម្បីឱ្យសមស្របតាមបំណងព្រះពុទ្ធសាសនា ពុទ្ធសាសនិកជនគួរដុសខាត់សតិបញ្ញាស្មារតី ពិចារណាឱ្យបានជ្រួតជ្រាបច្បាស់លាស់អំពីបំណងប្រាថ្នានៃព្រះពុទ្ធសាសនានេះ ។


www.elibraryofcambodia.org

## វិញ្ញាសាទី ១៨ ពិធីហៅព្រលឹងស្រូវ



រៀងរាល់ឆ្នាំ នៅពេលដែលប្រមូលផលស្រូវដាក់ជង្រុក អ្នកស្រុកខ្ញុំតែងធ្វើពិធីហៅព្រលឹងស្រូវ។ គេធ្វើពិធីនេះ ដើម្បីអញ្ជើញស្រូវឱ្យចូលមកផ្ទះថ្មី(ជង្រុក)។ គេធ្វើពិធីនេះ រយៈពេលមួយថ្ងៃគឺ នៅថ្ងៃបីកើត ខែមាឃរៀងរាល់ឆ្នាំ។ នៅថ្ងៃធ្វើពិធី គេបិទផ្លូវចេញចូលក្នុងភូមិទាំងអស់ មិនឱ្យនរណាម្នាក់ចេញចូលឡើយ។ គេធ្វើនំចំណី អាហារផ្សេងៗសម្រាប់ជប់លៀងនៅថ្ងៃនេះដែរ។ ពិធីបុណ្យចាប់ផ្តើមឡើងដោយការអុជទៀនធូបរួចហៅស្រូវដោយពាក្យ “អញ្ជើញនាងអ្នកចូលជង្រុក ”។ នាង មានន័យថាស្រូវដំណើប ព្រោះស្រូវដំណើបទន់តាងភេទស្រី ឯអ្នកមានន័យថាស្រូវខ្សាយ ព្រោះស្រូវខ្សាយរឹងតាងភេទប្រុស។ ពេលស្រូវចូលជង្រុករួចគេត្រូវបិទជង្រុកឱ្យជិតអស់រយៈពេលបីខែ ទើបអាចបើកបាន។ នៅថ្ងៃធ្វើពិធីនេះ គេមានជំនឿថានឹងមានវត្ថុស័ក្តិសិទ្ធិបង្ហាញខ្លួន ហើយគេយកវត្ថុនោះទុកជាទីសក្ការៈ។


www.elibraryofcambodia.org

ពិធីនេះគឺជាទំនៀមទម្លាប់ ដែលមានតាំងពីយូរយារណាស់មកហើយ។ អ្នកស្រុកភូមិខ្ញុំនៅតែថែរក្សាទំនៀមទម្លាប់នេះរហូតមកដល់សព្វថ្ងៃ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ១៩៩៣)*

## សិក្សាលើវិញ្ញាសាទី ១៨

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖

" ជង្រុក ខែមាឃ ស័ក្តិសិទ្ធិ សក្ការៈ " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖

" យូរយារ ស័ក្តិសិទ្ធិ ថែរក្សា " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " ស័ក្តិសិទ្ធិ " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " បិទ " ។

### ខ. សំណួរ

១. តើជារៀងរាល់ឆ្នាំ គេធ្វើពិធីហៅព្រលឹងស្រូវនៅថ្ងៃណា ខែណា ? ដើម្បីអ្វី ?

២. នៅថ្ងៃធ្វើពិធីនេះ តើគេធ្វើអ្វីខ្លះនៅក្នុងភូមិ ?

៣. តើពាក្យ " នាង និងអ្នក " មានន័យដូចម្ដេចខ្លះ ?

៤. ពេលស្រូវចូលជង្រុករួច តើគេត្រូវទុករយៈពេលប៉ុន្មាន ?

៥. ចូរជ្រើសរើសពាក្យក្នុងប្រអប់យកទៅបំពេញក្នុងកថាខណ្ឌឱ្យបានត្រឹមត្រូវ ៖

| |
|---|
| អាហារ ភូមិ ទៀនធូប ស្រូវខ្សាយ ជង្រុក ដំណើប |


www.elibraryofcambodia.org

នៅថ្ងៃធ្វើពិធី គេបិទផ្លូវចេញចូលក្នុង ..........ទាំងអស់មិនឱ្យនរណាម្នាក់ចេញចូលឡើយ។ គេធ្វើនំចំណីនិង .......... ផ្សេងៗសម្រាប់ជប់លៀងនៅថ្ងៃនេះដែរ។ ពិធីបុណ្យចាប់ផ្ដើមឡើងដោយការអុជ ............ រួចហៅស្រូវដោយពាក្យ " អញ្ជើញ នាងអ្នកចូលជង្រុក " ។ នាងមានន័យថាស្រូវ .............. ព្រោះស្រូវដំណើបទន់តាងភេទស្រី ឯអ្នកមានន័យថា .......... ព្រោះស្រូវខ្សាយរឹងតាងភេទប្រុស។ ពេលស្រូវចូល ................ រួចគេត្រូវបិទជង្រុកឱ្យជិតអស់រយៈពេលបីខែ ទើបអាចបើកបាន ។

## អំណានវិជ្ជាសាទី ១៨

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ជង្រុក (ន.) ៖ ក្រង់សម្រាប់ដាក់ស្រូវ ។
- ខែមាឃ (ន.) ៖ ឈ្មោះខែទី៣ នៃចន្ទគតិ។
- ស័ក្តិសិទ្ធិ (គុ.) ៖ ឆុតឆាប់ រហ័សទាន់ចិត្ត ។
- សក្ការៈ (ន.) ៖ ការគោរពបូជា សេចក្ដីគោរព ។

២. បដិសព្ទ

- យូរយារ ≠ ថ្មីៗ ទើបតែ
- ស័ក្តិសិទ្ធិ ≠ ឥតប្រយោជន៍ សាបរលាប
- ថៃរក្សា ≠ បំផ្លិចបំផ្លាញ

៣. វេវចនសព្ទ

- ស័ក្តិសិទ្ធិ ឆុតឆាប់ ប្រសិទ្ធភាព មានប្រយោជន៍។

៤. សទិសសព្ទ

- បិទ (កិ.) ៖ ខ្ទប់ រាំង បង្រួម។ *ឧ.* បិទទ្វារផ្ទះ បិទទឹក ។
- បិត (កិ.) ៖ សម្រួចដោយកាំបិត។ *ឧ.* បិតបន្ទោះឲ្យ បិតឈើស្រួច ។
- បិត (កិ.) ៖ ចំហុយយកញើសឱ្យស្រក់ចុះឬបន្សុទ្ធ។ *ឧ.* បិតស្រា។

## ខ. ចម្លើយ

១. ជារៀងរាល់ឆ្នាំគេធ្វើពិធីហៅព្រលឹងស្រូវ នៅថ្ងៃបីកើត ខែមាឃ ។ គេធ្វើពិធីនេះ ដើម្បីអញ្ជើញស្រូវឱ្យចូលមកផ្ទះថ្មី (ជង្រុក) ។

២. នៅថ្ងៃធ្វើពិធី គេបិទផ្លូវចេញចូលក្នុងភូមិទាំងអស់ មិនឱ្យនរណាម្នាក់ចេញចូលឡើយ។ គេធ្វើនំចំណី អាហារផ្សេងៗសម្រាប់ជប់លៀងនៅថ្ងៃនេះដែរ។ ពិធីបុណ្យចាប់ផ្តើមឡើងដោយការអុជទៀនធូប រួចហៅស្រូវដោយពាក្យ " អញ្ជើញ នាងអ្នកចូលជង្រុក " ។

៣. តាមរយៈអត្ថបទនេះ នាងមានន័យថាស្រូវដំណើប ព្រោះស្រូវដំណើបទន់តាងភេទស្រី ឯអ្នកមានន័យថាស្រូវខ្សាយ ព្រោះស្រូវខ្សាយរឹងតាងភេទប្រុស ។

៤. ពេលស្រូវចូលជង្រុករួច គេត្រូវបិទជង្រុកឱ្យជិតអស់រយៈពេលបីខែទើបអាចបើកបាន។ នៅថ្ងៃធ្វើពិធីនេះ គេមានជំនឿថានឹងមានវត្ថុស័ក្តិសិទ្ធិបង្ហាញខ្លួនហើយគេយកវត្ថុនោះទុកជាទីសក្ការៈ។

៥. បំពេញពាក្យក្នុងកថាខណ្ឌ ៖

នៅថ្ងៃធ្វើពិធី គេបិទផ្លូវចេញចូលក្នុងភូមិទាំងអស់ មិនឱ្យនរណាម្នាក់ចេញចូលឡើយ។ គេធ្វើនំចំណី អាហារផ្សេងៗសម្រាប់ជប់លៀងនៅថ្ងៃនេះដែរ។ ពិធីបុណ្យចាប់ផ្តើមឡើងដោយការអុជទៀនធូប រួចហៅស្រូវដោយពាក្យ " អញ្ជើញ នាងអ្នកចូលជង្រុក " ។ នាងមានន័យថាស្រូវដំណើប ព្រោះស្រូវដំណើបទន់តាងភេទស្រី ឯអ្នកមានន័យថាស្រូវខ្សាយ ព្រោះស្រូវខ្សាយរឹងតាងភេទប្រុស ។ ពេលស្រូវចូលជង្រុករួច គេត្រូវបិទជង្រុកឱ្យជិតអស់រយៈពេលបីខែទើបអាចបើកបាន ។


www.elibraryofcambodia.org

វិញ្ញាសាទី ១៩

# មរតកបញ្ញា



ជីតាខ្ញុំចេះចាំរឿងបុរាណច្រើនណាស់។ រឿងបុរាណភាគច្រើននិយាយអំពីទំនាស់រវាងមនុស្ស និងយក្ស។ រឿងខ្លះនិយាយពីយក្សចេះហោះ ហើរជ្រែកទឹក ជ្រែកដី និងកាឡាខ្លួនជាមនុស្ស ហើយច្បាំងជាមួយមនុស្សរហូតតាំងពីដើមដល់ចប់។ ប៉ុន្តែយក្សពុំដែលធ្វើសង្គ្រាមឈ្នះមនុស្សទេដូចជា រឿងព្រះជិនវង្ស ពុទ្ធិសែន សង្ខសិល្បជ័យ ទិព្វសង្វារ រាមកេរ្តិ៍ ។ល។

ចំណែកជីដូនខ្ញុំពូកែខាងចោទប្រស្នាឬពាក្យបណ្ដៅ។ ខ្ញុំត្រូវជីដូនខ្ញុំលក់ជាញយៗដោយសារខ្ញុំរកពុំឃើញ។ ប៉ុន្តែខ្ញុំសប្បាយណាស់ ព្រោះខ្ញុំចូលចិត្តស្ដាប់ពាក្យបណ្ដៅ។ ពាក្យបណ្ដៅនីមួយៗមានឃ្លាល្បះចួនគ្នាពីរោះស្ដាប់គួរឱ្យចាប់អារម្មណ៍ដូចជា កំប៉េងកំប៉ោះ កំប៉េងអត់ដោះ


www.elibraryofcambodia.org

ចិញ្ចឹមកូនរស់ ឬនាមខ្ញុំជារុក្ខា ទោះខ្ពស់យ៉ាងណាក៏គេមិនថាខ្ពស់។ ខ្ញុំចូលចិត្តយកពាក្យបណ្ដៅ ដែលជីដូនខ្ញុំសួរទៅសួរមិត្តភក្តិខ្ញុំបន្តទៀត ទើបខ្ញុំចាំពាក្យបណ្ដៅទាំងនោះបានយ៉ាងច្បាស់ ។

ខ្ញុំព្រួយបារម្ភណាស់ចំពោះបញ្ហាបាត់បង់មរតកបញ្ញា ដែលបុព្វបុរសយើងបានបន្សល់ទុកឱ្យយើងគ្រប់គ្នាថែរក្សា។ ប៉ុន្តែអ្នកខ្លះហាក់ដូចជាមិនសូវនិយមលើកតម្កើងមរតកវប្បធម៌របស់ខ្លួនទេ តែបែរទៅជានិយមលើកតម្កើងអ្វីដែលមិនមែនជារបស់ខ្លួនទៅវិញ ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១ )*

## សិក្សាស្ដីពីវិញ្ញាសាទី ១៩

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖

" កាឡា ប្រស្នា ពាក្យបណ្ដៅ មរតក បុព្វបុរស លក់ " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖

" ព្រួយបារម្ភ ញយៗ លើកតម្កើង បាត់បង់ " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " មិត្តភក្តិ "។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " បង់ "។

### ខ. សំណួរ

១. តើរឿងបុរាណ មានលក្ខណៈដូចម្ដេច ?

២. តើតួអង្គក្នុងអត្ថបទ គេចូលចិត្តស្ដាប់អ្វី ?

៣. ចូររកចម្លើយរបស់ពាក្យបណ្ដៅ " កំប៉េងកំប៉ោះ កំប៉េងអត់ដោះ ចិញ្ចឹមកូនរស់ " ។


www.elibraryofcambodia.org

៤. ចូររកចម្លើយរបស់ពាក្យបណ្ដៅ " នាមខ្ញុំជារុក្ខា ទោះខ្ពស់យ៉ាងណា កំគេមិនថាខ្ពស់ " ។

៥. តើតួអង្គក្នុងអត្ថបទ គេចាប់អារម្មណ៍ដូចម្ដេចខ្លះ ?

## កំណែវិជ្ជាសាលាទី ១៩

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- កាឡា (គុ.) ៖ ប្រែកាយ ប្រែរូបផ្សេងពីរូបដើម។
- ប្រស្នា (ន.) ៖ ចំណោទ។
- ពាក្យបណ្ដៅ (ន.) ៖ ពាក្យឬគន្លឹះសម្រាប់ចោទ ដើម្បីឱ្យរកចម្លើយ។
- មរតក (ន.) ៖ ដំណែលដែលបន្សល់ទុក។
- បុព្វបុរស (ន.) ៖ ដូនតា អ្នកជំនាន់មុនៗ។
- លក់ (កិ.) ៖ បញ្ជូនតាមរយៈពាក្យសម្ដីឱ្យទៅទីកន្លែងផ្សេងៗ មានលក្ខណៈដូចក្នុងពាក្យបណ្ដៅដែរ។

២. បដិសព្ទ

- ព្រួយបារម្ភ ≠ រីករាយ
- ញយៗ ≠ ម្ដងម្កាល
- លើកតម្កើង ≠ បន្ទុះបង្អាប់
- បាត់បង់ ≠ គង់វង្ស

៣. ផវចនសព្ទ

- មិត្តភក្តិ សម្លាញ់ ភ្លើ ម្រាក់ ពួកម៉ាក បនរៀន។


www.elibraryofcambodia.org

៤. សមិសសព្ទ

- បង់ (កិ.) ៖ ចេញប្រាក់ ដាក់ប្រាក់តាមកំណត់។ ឧ. បង់ពន្ធម៉ូតូ ។
- បង់ (កិ.) ៖ ទម្លាក់ចុះ ដាក់ចុះ។ ឧ. បង់គ្រឿងសម្ល បង់អំបិល។
- បង់ (កិ.) ៖ គ្រវែងចេញពីដៃ។ ឧ. បង់សំណាញ់។
- បង់ (គុ.) ៖ ខាត វិនាស សិយសុីនឥតប្រយោជន៍។ ឧ. បង់ចិត្តតំនិត ។
- បង់ (កិ.) ៖ ចុះលេខក្នុងបញ្ជី។ ឧ. បង់លេខរៀងសិន ។

## ខ. ចម្លើយ

១. រឿងបុរាណភាគច្រើននិយាយអំពីទំនាស់រវាងមនុស្សនិងយក្ស។ រឿងខ្លះនិយាយពីយក្សចេះហោះហើរ ប្រែកទឹក ប្រែកដី និងកាឡាខ្លួនជាមនុស្ស ហើយច្បាំងជាមួយមនុស្សរហូតតាំងពីដើមដល់ចប់។

២. តួអង្គក្នុងអត្ថបទចូលចិត្តស្តាប់ពាក្យបណ្តៅ។ ចំណែកជីដូនរបស់គេពូកែខាងចោទប្រស្នា ឬពាក្យបណ្តៅ។ គេត្រូវជីដូនលក់ជាញយៗដោយសារគេរកពុំឃើញ។

៣. សត្វមាន់ ទា ។

៤. ដើមទៀប ។

៥. តួអង្គក្នុងអត្ថបទចាប់អារម្មណ៍ថា គេព្រួយបារម្ភណាស់ចំពោះបញ្ហាបាត់បង់មរតកបញ្ញា ដែលបុព្វបុរសយើងបានបន្សល់ទុកឱ្យយើងគ្រប់គ្នាថែរក្សា។ ប៉ុន្តែអ្នកខ្លះហាក់ដូចជាមិនសូវនិយមលើកតម្កើងមរតកវប្បធម៌របស់ខ្លួនទេ តែបែរទៅជានិយមលើកតម្កើងអ្វីដែលមិនមែនជារបស់ខ្លួនទៅវិញ។


www.elibraryofcambodia.org

វិញ្ញាសាទី ២០

# របាំឆៃយ៉ាំ



ខ្មែរយើងមានរបាំប្រជាប្រិយច្រើនណាស់ ប៉ុន្តែក្នុងចំណោមនោះ របាំឆៃយ៉ាំបានត្រូវគេចាប់អារម្មណ៍ជាងគេ។ កាលណានិយាយពីឆៃយ៉ាំ គេនឹកឃើញដល់ទិដ្ឋភាពនៃការរាំរបាំនេះភ្លាម។

គេនិយមលេងរបាំនេះក្នុងពិធីផ្សេងៗដូចជា បុណ្យផ្កា បុណ្យកឋិន បំបួសនាគ ដើម្បីឱ្យមានភាពនិទ្យារិក។ របាំឆៃយ៉ាំបានក្លាយជារបាំប្រជាប្រិយ តាំងពីយូរណាស់មកហើយ ព្រោះប្រជាជនខ្មែរភាគច្រើនស្រឡាញ់ចូលចិត្តរបាំនេះគ្រប់ទីកន្លែង។


www.elibraryofcambodia.org

បច្ចុប្បន្ននេះ របាំនៃយាំត្រូវគេស្គាល់សុសសាយគ្មានចន្លោះ សូម្បីតែក្មេងៗក៏ចាប់អារម្មណ៍ខ្លាំងណាស់ដែរ។ ហេតុដែលនាំឱ្យរបាំនេះមានប្រជាប្រិយភាព គឺចង្វាក់ភ្លេងនៃរបាំនេះមានសន្ទុះហ៊ឹកហ៊ាក់ស្របតាមកាយវិការលោតចុះ លោតឡើង ញាក់មុខ ញាក់ខ្លួន ក្រមិចក្រមើម គួរឱ្យអ្នកមើលរីករាយក្នុងចិត្តយ៉ាងខ្លាំង។ ទោះបីយើងកំពុងមានទុក្ខកង្វល់ ឬស្មុគស្មាញក្នុងចិត្តក៏ដោយ កាលបើបានឃើញរបាំនេះភ្លាម យើងហាក់ដូចជាភ្លេចទុក្ខមួយគ្រាដែរ។

របាំនេះមានឧបករណ៍តិចល្មម និងងាយស្រួលលេងណាស់។ ជូនកាលអ្នកលេងរបាំនេះ ពុំសូវបានគិតគូរធ្វើតទ្វង់ឱ្យបានត្រឹមត្រូវតាមតម្រាដើមទេ ដូចជាពុំសូវគិតពីសម្លៀកបំពាក់ និងក្បួនច្បាប់ចាក់ត្លុកឡើយ។ ប្រការសំខាន់អ្នកលេងគ្រាន់តែចាក់ត្លុកលោត ញាក់តាមភ្លេងយ៉ាងណាឱ្យតែកើតបរិយាកាសរីករាយតែប៉ុណ្ណោះ។

អាស្រ័យដោយរបាំនៃយាំមានលក្ខណៈប្លែកនិងពិសេស ទើបរបាំនេះបានត្រូវប្រជាជនខ្មែរខិតខំថែរក្សារហូតមកដល់សព្វថ្ងៃ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ១៩៩៨ )*

## សិក្សាលើមេរៀនទី ២០

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖
"ប្រជាប្រិយ បំបួសនាគ ហ៊ឹកហ៊ាក់ ក្រមិចក្រមើម ចាក់ត្លុក" ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖
"និទ្បារិក ស្មុគស្មាញ សុសសាយ ហ៊ឹកហ៊ាក់" ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ "ហ៊ឹកហ៊ាក់" ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ "ចាក់" ។


www.elibraryofcambodia.org

## ខ. សំណួរ

១. តើប្រជាជនខ្មែរយើងនិយមលេងរបាំឆៃយ៉ាំក្នុងពិធីអ្វីខ្លះ ?
២. ហេតុអ្វីបានជាធ្វើឱ្យរបាំឆៃយ៉ាំ មានប្រជាប្រិយភាពខ្លាំង ?
៣. តើការសម្ដែងរបាំនេះមានលក្ខណៈដូចម្ដេចខ្លះ ?
៤. តើអ្នកស្គាល់របាំប្រជាប្រិយខ្មែរអ្វីខ្លះ ?
៥. ចូរជ្រើសរើសពាក្យក្នុងប្រអប់ យកទៅបំពេញក្នុងកថាខណ្ឌឱ្យបានត្រឹមត្រូវ ៖

| | | |
|---|---|---|
| ប្រជាប្រិយភាព | ក្រមិចក្រមើម | សុសសាយ |
| កាយវិការ | ស្មុគស្មាញ | |

បច្ចុប្បន្ននេះ របាំឆៃយ៉ាំត្រូវគេស្គាល់ ...................... គ្មានចន្លោះសូម្បីតែក្មេងៗក៏ចាប់អារម្មណ៍ខ្លាំងណាស់ដែរ។ ហេតុដែលនាំឱ្យរបាំនេះមាន ..................... គឺចង្វាក់ភ្លេងនៃរបាំនេះមានសន្ទុះហ៊ឹកហ៊ាក់ស្របតាម ................ លោតចុះ លោតឡើង ញាក់មុខ ញាក់ខ្លួន ............... គួរឱ្យអ្នកមើលរីករាយក្នុងចិត្តយ៉ាងខ្លាំង។ ទោះបីយើងកំពុងមានទុក្ខកង្វល់ ឬ ...................... ក្នុងចិត្តក៏ដោយ កាលបើបានឃើញរបាំនេះភ្លាម យើងហាក់ដូចជាភ្លេចទុក្ខមួយគ្រាដែរ ។

# អំណានទី ២០

## ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ប្រជាប្រិយ (គុ.) ៖ ដែលប្រជាជននិយមចូលចិត្ត។
- បំបួសនាគ (ន.) ៖ ឈ្មោះពិធីបំបួសកូនប្រុសឱ្យក្លាយជាសង្ឃ។


www.elibraryofcambodia.org

- ហ៊ឹកហ៊ាក់ (គុ.) ៖ ដែលអ៊ូអរ អធិកអធម។
- ក្រមិចក្រមើម (គុ.) ៖ របុិលរប៉ូច ឡេមឡើម។
- ចាក់ត្អុក (កិ.) ៖ ចាក់ក្បាច់ របុិលរប៉ូច ឡេមឡើម។

២.បដិសព្ទ

- និឡារិក ≠ ស្ងាត់ជ្រងំ
- ស្មុគស្មាញ ≠ ងាយស្រួល
- សុសសាយ ≠ ស្ងាត់ស្ងៀម
- ហ៊ឹកហ៊ាក់ ≠ ស្ងាត់ជ្រងំ ស្ងាត់ជ្រៀប

៣.វេវចនសព្ទ

- ហ៊ឹកហ៊ាក់ អធិកអធម និឡារិក រនឹ្ង អឹងកង កងរំពង។

៤.សទិសសព្ទ

- ចាក់ (កិ.) ៖ បុះដោយអាវុធមុខស្រួច ។ *ឧ.* ចាក់កង្កែប។
- ចាក់ (កិ.) ៖ រុកប្រឡែងលេងកន្លែងរសើប។*ឧ.*ចាក់ក្រឡេក។
- ចាក់ (កិ.) ៖ រលាក់អ្វីចេញ ចាក់ចេញ។ *ឧ.* ចាក់សំរាម ចាក់ទឹកតែ ។
- ចាក់ (កិ.) ៖ ផ្ដិះផ្ដៀល និយាយអាក្រក់បង្កជម្លោះ។ *ឧ.* កុំជឿតាមគេចាក់។
- ចក្រ (ន.) ៖ កង់ កង់មានកាំ រង្វង់មូល។ *ឧ.* រោងចក្រ។

## ខ. ចម្លើយ

១. ប្រជាជនខ្មែរ និយមលេងរបាំនេះក្នុងពិធីផ្សេងៗដូចជា បុណ្យផ្កា បុណ្យកឋិន បំបួសនាគ ដើម្បីឱ្យមានភាពនិឡារិក។ របាំឆៃយ៉ាំបានក្លាយជារបាំប្រជាប្រិយតាំងពីយូរណាស់មកហើយ ព្រោះប្រជាជនខ្មែរភាគច្រើនស្រឡាញ់ចូលចិត្តរបាំនេះគ្រប់ទីកន្លែង។



www.elibraryofcambodia.org

២. ហេតុដែលនាំឱ្យរបាំនេះមានប្រជាប្រិយភាព គឺចង្វាក់ភ្លេងនៃរបាំនេះមានសន្ទុះហ៊ឹកហ៊ាក់ស្របតាមកាយវិការលោតចុះ លោតឡើង ញាក់មុខ ញាក់ខ្លួន ក្រមិចក្រមើម គួរឱ្យអ្នកមើលរីករាយក្នុងចិត្តយ៉ាងខ្លាំង។ ទោះបីយើងកំពុងមានទុក្ខកង្វល់ ឬស្មុគស្មាញក្នុងចិត្តក៏ដោយ កាលបើបានឃើញរបាំនេះភ្លាម យើងហាក់ដូចជាភ្លេចទុក្ខមួយគ្រាដែរ។

៣. ការសម្ដែងរបាំនេះ ងាយស្រួលលេងណាស់ ព្រោះរបាំនេះមានឧបករណ៍តិចល្មម។ ជួនកាលអ្នកលេងរបាំនេះពុំសូវបានគិតគូរផ្ចិតផ្ចង់ឱ្យបានត្រឹមត្រូវតាមតម្រាដើមទេ ដូចជាពុំសូវគិតពីសម្លៀកបំពាក់ និងក្បួនច្បាប់ចាក់គ្លុកឡើយ។ ប្រការសំខាន់អ្នកលេងគ្រាន់តែចាក់គ្លុកលោតញាក់ តាមភ្លេងយ៉ាងណា ឱ្យតែកើតបរិយាកាសរីករាយតែប៉ុណ្ណោះ។

៤. របាំប្រជាប្រិយខ្មែរមានច្រើនដូចជា របាំឆៃយ៉ាំ របាំគោះអង្រែ របាំក្ងោក របាំត្រុដិ របាំតែន របាំគោះត្រឡោក ។ល។

៥. បច្ចុប្បន្ននេះ របាំឆៃយ៉ាំត្រូវគេស្គាល់សុសសាយគ្មានចន្លោះ សូម្បីតែក្មេងៗក៏ចាប់អារម្មណ៍ខ្លាំងណាស់ដែរ។ ហេតុដែលនាំឱ្យរបាំនេះមានប្រជាប្រិយភាព គឺចង្វាក់ភ្លេងនៃរបាំនេះមានសន្ទុះហ៊ឹកហ៊ាក់ស្របតាមកាយវិការលោតចុះ លោតឡើង ញាក់មុខ ញាក់ខ្លួន ក្រមិចក្រមើមគួរឱ្យអ្នកមើលរីករាយក្នុងចិត្តយ៉ាងខ្លាំង។ ទោះបីយើងកំពុងមានទុក្ខកង្វល់ ឬស្មុគស្មាញក្នុងចិត្តក៏ដោយ កាលបើបានឃើញរបាំនេះភ្លាម យើងហាក់ដូចជាភ្លេចទុក្ខមួយគ្រាដែរ។


www.elibraryofcambodia.org

វិញ្ញាសាទី

# ២១ ផលប្រយោជន៍នៃវិទ្យាសាស្ត្រ



វិទ្យុជាមធ្យោបាយផ្សព្វផ្សាយ និងទទួលព័ត៌មានផ្សេងៗតាមរលកធាតុអាកាស។ ដំណឹងតាមវិទ្យុមានលក្ខណៈជាកម្មវិធីច្បាស់លាស់ដែលត្រូវផ្សព្វផ្សាយជាសាធារណៈ តាមស្ថានីយវិទ្យុដល់មនុស្សម្នាទូទៅ។ អ្នកស្តាប់អាចលំហែកំសាន្ត តាមការស្តាប់រឿងល្ខោន យីកេ ចម្រៀង តន្ត្រី ហើយនឹងដឹងព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ដឹងពីព្រឹត្តិការណ៍ជាតិ អន្តរជាតិ ឬសុន្ទរកថារបស់មនុស្សសំខាន់ៗ។ លើសពីនេះ គេអាចស្តាប់ដំណឹងផ្សេងៗ មានដំណឹងសួររកបងប្អូន ដំណឹងពីកម្មវិធីបុណ្យទាននានា ឬការអប់រំប្រជាករឱ្យយល់ពីគ្រោះថ្នាក់នៃគ្រាប់មីន សិទ្ធិមនុស្ស បរិស្ថាន ការបង្ការជំងឺផ្សេងៗ ។ល។


www.elibraryofcambodia.org

ក្រៅពីការផ្សព្វផ្សាយតាមរយៈរលកសំឡេង វិទ្យាសាស្ត្របានបង្កើតឧបករណ៍ផ្សព្វផ្សាយ និងទទួលព័ត៌មានមួយបែបទៀត នោះគឺទូរទស្សន៍។ ទូរទស្សន៍ជាគ្រឿងអេឡិចត្រូនិចដែលអាចបង្ហាញសកម្មភាពតាមផ្ទាំងកញ្ចក់ និងផ្តល់សំឡេងទៀតផង។ គេប្រើទូរទស្សន៍នៅទីកន្លែងណា ដែលមានប្រភពអគ្គិសនីឬអាចប្រើដោយកម្លាំងអាគុយក៏បាន។ ទូរទស្សន៍អាចផ្សព្វផ្សាយរូបភាពពិតៗ តាមរយៈការផ្សព្វផ្សាយបន្តផ្ទាល់ ពីតំបន់ជាច្រើននៃពិភពលោក។ ទូរទស្សន៍មានកម្លាំងធំបែបនេះ អាចផ្សព្វផ្សាយតាមបណ្តាញខ្សែកាប និងផ្កាយរណប។ ក្រៅពីវិទ្យុ និងទូរទស្សន៍ តើមានឧបករណ៍អ្វីទៀតសម្រាប់ជាជំនួយក្នុងការទាក់ទងគ្នាដែរឬទេ ?

ទូរស័ព្ទជួយមនុស្សក្នុងទំនាក់ទំនងគ្នា តាមរយៈសម្តីផ្ទាល់ទោះនៅជិតក្តីឆ្ងាយក្តី។ ទូរស័ព្ទខ្លះដាក់នៅមួយកន្លែងដែលតភ្ជាប់នឹងខ្សែបណ្តាញរបស់ទូរស័ព្ទ តែទូរស័ព្ទម្យ៉ាងទៀតគ្មានខ្សែទេ។ គេអាចយកវាទៅតាមខ្លួនបាន។ ទូរស័ព្ទបែបនេះហៅថាទូរស័ព្ទចល័ត។ វាបញ្ជូន ឬទទួលព័ត៌មានបានរហ័សទាន់ចិត្ត។

ចាប់តាំងពីវិទ្យាសាស្ត្របានបង្កើតវិទ្យុ ទូរទស្សន៍ និងទូរស័ព្ទមកមនុស្សអាចស្តាប់គ្នា និយាយគ្នា មើលឃើញអ្វីៗដែលនៅឆ្ងាយ ឬទាក់ទងគ្នាបានគ្រប់ពេលវេលា ទោះបីឆ្លងប្រទេសឬឆ្លងទ្វីបក៏ដោយ ។

*(ដកស្រង់ និងកែសម្រួលពីសៀវភៅ ភាសាខ្មែរ ថ្នាក់ទី៥ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១១ )*


www.elibraryofcambodia.org

## សិក្សាលើវិញ្ញាសាទី ២១

### ក. រៀនពាក្យ

១. ចូរពន្យល់ពាក្យខាងក្រោមនេះ ៖ " ស្ថានីយ យីកេ ព្រឹត្តិការណ៍ ប្រជាករ សុន្ទរកថា ផ្កាយរណប ទូរស័ព្ទចល័ត " ។

២. ចូររកបដិសព្ទនឹងពាក្យខាងក្រោមនេះ ៖
" សាធារណៈ ទូទៅ ទូរស័ព្ទចល័ត រហ័សទាន់ចិត្ត " ។

៣. ចូររកវេវចនសព្ទនឹងពាក្យ ៖ " បង្ការ " ។

៤. ចូររកសទិសសព្ទនឹងពាក្យ ៖ " សាស្ត្រ " ។

### ខ. សំណួរ

១. ដូចម្តេច ហៅថាវិទ្យុ ?

២. តើអ្នកស្តាប់វិទ្យុ មានប្រយោជន៍អ្វីខ្លះ ?

៣. ក្រៅពីវិទ្យុ តើវិទ្យាសាស្ត្របានបង្កើតអ្វីទៀត ?

៤. ក្រៅពីវិទ្យុ និងទូរទស្សន៍ តើវិទ្យាសាស្ត្របានបង្កើតអ្វីទៀត ?

៥. តើវិទ្យាសាស្ត្របានបង្កើតវិទ្យុ ទូរទស្សន៍ និងទូរស័ព្ទ មានប្រយោជន៍អ្វីខ្លះ ?

## កំណែវិញ្ញាសាទី ២១

### ក. រៀនពាក្យ

១. ពន្យល់ពាក្យ

- ស្ថានីយ (ន.) ៖ ទីកន្លែងសមគួរ វិទ្យុ (កន្លែងផ្សាយ) ។
- យីកេ (ន.) ៖ ល្បែងសម្រាប់កម្សាន្តមួយប្រភេទដូចល្ខោនដែរ ។
- ព្រឹត្តិការណ៍ (ន.) ៖ រឿងរ៉ាវ ហេតុការណ៍ ។
- ប្រជាករ (ន.) ៖ ប្រជាជនទូទៅ ។


www.elibraryofcambodia.org

- សុន្ទរកថា (ន.) ៖ ពាក្យសម្ដីដែលមានប្រយោជន៍គួរឱ្យស្ដាប់ ។
- ផ្ទាយរណប (ន.) ៖ គ្រឿងសម្រាប់ទទួល និងបញ្ជូន ។
- ទូរស័ព្ទចល័ត (ន.) ៖ ទូរស័ព្ទដែលអាចយកដាក់តាមខ្លួនបាន ។

២.បដិសព្ទ

- សាធារណៈ ≠ ឯកជន
- ទូទៅ ≠ ផ្ទាល់ខ្លួន
- ទូរស័ព្ទចល័ត ≠ ទូរស័ព្ទមានខ្សែ
- រហ័សទាន់ចិត្ត ≠ យឺតយ៉ាវ

៣.ពាក្យវេចនសព្ទ

- បង្ការ ការពារ រាំង ឃាំងឃាំង។

៤.សទិសសព្ទ

- សាស្ត្រ (ន.) ៖ ក្បួនច្បាប់។ ឧ. ពូខ្ញុំទៅរៀនយុទ្ធសាស្ត្រចម្បាំង។
- សាសន៍ (ន.) ៖ ជនជាតិ ពូជ សញ្ជាតិ។ ឧ. គាត់ជាសាសន៍ឥណ្ឌា។
- សះ (គុ.) ៖ ដែលជាពីជំងឺ។ ឧ. គាត់បានជាសះស្បើយហើយ ។

## ខ. ចម្លើយ

១. វិទ្យុជាមធ្យោបាយផ្សព្វផ្សាយ និងទទួលព័ត៌មានផ្សេងៗតាមរលកធាតុអាកាស។ ដំណឹងតាមវិទ្យុមានលក្ខណៈជាកម្មវិធីច្បាស់លាស់ដែលត្រូវផ្សព្វផ្សាយជាសាធារណៈតាមស្ថានីយវិទ្យុដល់មនុស្សម្នាទូទៅ។


www.elibraryofcambodia.org

២. អ្នកស្តាប់អាចលម្ហែកំសាន្តតាមការស្តាប់រឿងល្ខោន យីកេ ចម្រៀង តន្ត្រី ហើយនឹងដឹងព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ដឹងពីព្រឹត្តិការណ៍ជាតិ អន្តរជាតិ ឬសុន្ទរកថារបស់មនុស្សសំខាន់ៗ។ លើសពីនេះគេអាចស្តាប់ជំណឹងផ្សេងៗ មានដំណឹងសួររកបងប្អូន ដំណឹងពីកម្មវិធីបុណ្យទាននានា ឬការអប់រំប្រជាករឱ្យយល់ពីគ្រោះថ្នាក់នៃគ្រាប់មីន សិទ្ធិមនុស្ស បរិស្ថាន ការបង្ការជំងឺផ្សេងៗ ។ល។

៣. ក្រៅពីការ ផ្សព្វផ្សាយតាមរយៈរលកសំឡេង វិទ្យាសាស្ត្របានបង្កើតឧបករណ៍ផ្សព្វផ្សាយ និងទទួលព័ត៌មានមួយបែបទៀត នោះគឺទូរទស្សន៍។ ទូរទស្សន៍ជាគ្រឿងអេឡិចត្រូនិច ដែលអាចបង្ហាញសកម្មភាពតាមផ្ទាំងកញ្ចក់ និងផ្តល់សំឡេងទៀតផង។ គេប្រើទូរទស្សន៍នៅទីកន្លែងណា ដែលមានប្រភពអគ្គិសនី ឬអាចប្រើដោយកម្លាំងអាគុយក៏បាន។ ទូរទស្សន៍អាចផ្សព្វផ្សាយរូបភាពពិតៗ តាមរយៈការផ្សព្វផ្សាយបន្តផ្ទាល់ ពីតំបន់ជាច្រើននៃពិភពលោក។

៤. ក្រៅពីវិទ្យុ និងទូរទស្សន៍វិទ្យាសាស្ត្របានបង្កើត ទូរស័ព្ទជួយមនុស្សក្នុងទំនាក់ទំនងគ្នាតាមរយៈសម្តីផ្ទាល់ ទោះនៅជិតក្តី ឆ្ងាយក្តី។ ទូរស័ព្ទខ្លះដាក់នៅមួយកន្លែង ដែលតភ្ជាប់នឹងខ្សែបណ្តាញរបស់ទូរស័ព្ទ តែទូរស័ព្ទម្យ៉ាងទៀតគ្មានខ្សែទេ។ គេអាចយកវាទៅតាមខ្លួនបាន។ ទូរស័ព្ទបែបនេះហៅថាទូរស័ព្ទចល័ត។ វាបញ្ជូនឬទទួលព័ត៌មានបានរហ័សទាន់ចិត្ត។

៥. ចាប់តាំងពីវិទ្យាសាស្ត្របានបង្កើតវិទ្យុ ទូរទស្សន៍ និងទូរស័ព្ទមក មនុស្សអាចស្តាប់គ្នានិយាយគ្នា មើលឃើញអ្វីៗដែលនៅឆ្ងាយ ឬទាក់ទងគ្នាបានគ្រប់ពេលវេលា ទោះបីឆ្លងប្រទេស ឬឆ្លងទ្វីបជុំវិញពិភពលោក ។


www.elibraryofcambodia.org

វិញ្ញាសាទី ១

# តែងសេចក្ដីបែបពិពណ៌នា អំពីមនុស្ស

## ក.គម្រោងតែង

### ១.សេចក្ដីផ្ដើម

បង្ហាញពីមនុស្សនោះដោយប្រាប់ ៖

- ឈ្មោះ ... ភេទ ...
- អាយុ ...
- ទីលំនៅ ( ផ្ទះលេខ ផ្លូវ ក្រុម ភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ក្រុង/រាជធានី/ខេត្ត )
- មុខរបរ ...។

### ២.តួសេចក្ដី

- រូបសម្បត្តិ

  រូបរាង ៖

  - មាឌ ( តូច ធំ ស្គម ធាត់ ...)
  - កម្ពស់ ( ទាប ខ្ពស់ ... )
  - សម្បុរ ( ស ខ្មៅ ស្រអែម ... )
  - មុខមាត់ ( ភ្នែក ច្រមុះ មាត់ ត្រចៀក សក់ ទឹកមុខ ... )
  - ជើង ដៃ ( មាំមួន សមនឹងដងខ្លួន វែងខ្លី ... )
  - អាកប្បកិរិយា ៖ សកម្មភាពផ្សេងៗ ការស្លៀកពាក់ ការនិយាយស្ដី ការធ្វើការងារ។ល។


www.elibraryofcambodia.org

ចរិយាសម្បត្តិ

គុណសម្បត្តិ ៖

- ឧស្សាហ៍ព្យាយាម យកចិត្តទុកដាក់លើការសិក្សា ឬធ្វើការងារ
- មានសណ្ដាប់ធ្នាប់ គោរពវិន័យ គោរពច្បាប់ ផ្ចិតផ្ចង់ ...
- ឆ្លាតវាងវៃ ឆាប់យល់ ចេះចាំ ...
- ក្លាហាន ហ៊ានទទួលខុសត្រូវ ...
- ចិត្តទូលាយ ជួយទុក្ខធុរៈអ្នកដទៃ មិត្តភក្តិ ...
- ស្លូតត្រង់ ស្រឡាញ់យុត្តិធម៌ សុចរិត ...។

គុណវិបត្តិ ៖ តើមានចំណុចអសកម្មត្រង់ណាខ្លះ ?

ឧ. លេងសើចច្រើន មករៀនយឺត ...។

### ៣.សេចក្ដីបញ្ចប់

- វាយតម្លៃ ៖ គេជាមនុស្សល្អ ចេះជួយគ្នាក្នុងគ្រាក្រ ...។
- ចំណាប់អារម្មណ៍ ៖ បង្ហាញមនោសញ្ចេតនាចំពោះមិត្ត គោរពគួរយកតម្រាប់តាម ...។

## ខ.ការអនុវត្ត

*ប្រធាន ៖* សព្វថ្ងៃអ្នករៀនជាមួយអ្នកគ្រូម្នាក់។ ចូរអ្នកពិពណ៌នាពីអ្នកគ្រូរបស់អ្នកឱ្យបានក្បោះក្បាយ។


www.elibraryofcambodia.org

# សេចក្ដីអធិប្បាយ

ខ្ញុំជាសិស្សថ្នាក់ទី ៥ក₁។ អ្នកគ្រូខ្ញុំ ជាគ្រូដ៏ល្អម្នាក់ឈ្មោះអ្នកគ្រូចាន់នាង។ គាត់ជាគ្រូប្រចាំថ្នាក់របស់ខ្ញុំ។ អ្នកគ្រូរបស់ខ្ញុំមានអាយុប្រហែល៤៤ឆ្នាំ ។

អ្នកគ្រូចាន់នាងមានមានធំល្មម រាងខ្ពស់ស្រឡះ សម្បុរស្បែកថ្លា មិនខ្មៅមិនស គឺសម្បុរសណ្ដែកបាយ ឯទឹកមុខគាត់ស្រស់ស្រាយជានិច្ច។ គាត់មានសក់ស្លួត ភ្នែកធំល្មម ច្រមុះស្រួច មុខរាងពងក្រពើ បបូរមាត់មិនក្រាស់ពេក ហើយមានដៃជើងស្រឡូនសមសួន។ ពេលគាត់មកបង្រៀន គាត់តែងពាក់អាវស សំពត់ខៀវ ឬខ្មៅ ។ គាត់មិនដែលតែងខ្លួនឆើតឆាយហួសហេតុនោះទេ។

អ្នកគ្រូខ្ញុំស្លូតបូតសុភាពរាបសាសម្ដីទន់ភ្លន់ ចិត្តធ្ងន់មិនឆេវឆាវ។ គាត់ព្យាយាមណាស់ នៅពេលបង្រៀនពេលមានសិស្សមិនទាន់យល់ខ្លឹមសារមេរៀន គាត់តែងពន្យល់សាឡើងវិញរហូតដល់សិស្សយល់មេរៀនបានទាំងអស់គ្នា។ គាត់ប្រកាន់សេចក្ដីយុត្តិធម៌ជានិច្ច។ ពេលកែកិច្ចការរបស់សិស្ស គាត់តែងដាក់ពិន្ទុឱ្យសុចរិត មិនលម្អៀង ឬប្រកាន់ បក្សពួកឡើយ។ អ្នកគ្រូមានចិត្តសន្ដោសប្រណី យោគយល់អធ្យាស្រ័យ ចំពោះសិស្សដែលមានកំហុស ហើយចេះកែកំហុសឆ្គងទាំងនោះ។ អ្នកគ្រូជាមនុស្សប្រកបដោយព្រហ្មវិហារធម៌ គាត់ជាឪពុកម្ដាយទីពីររបស់ខ្ញុំ។

ខ្ញុំគោរពស្រឡាញ់គាត់ណាស់ ព្រោះគាត់ជាអ្នកផ្ដល់ចំណេះដឹងដល់សិស្សានុសិស្សគ្រប់ៗគ្នា ដូច្នេះខ្ញុំត្រូវខិតខំសិក្សារៀនសូត្រ ស្ដាប់ដំបូន្មានរបស់គាត់ គោរពវិន័យសាលាមិនឱ្យអ្នកគ្រូ និងឪពុកម្ដាយខកចិត្តឡើយ។


www.elibraryofcambodia.org

វិញ្ញាសាទី ២

# តែងសេចក្តីបែបពិពណ៌នាអំពីសត្វ

## គម្រោងតែង

១. សេចក្តីផ្តើម

បង្ហាញពីសត្វនោះដោយប្រាប់ ៖

- ឈ្មោះសត្វ ... ភេទ ...
- អាយុ
- ទីលំនៅ ...។

២. តួសេចក្តី

- រូបរាង
  - មាឌ ៖ តូច ធំ ស្គម ធាត់ ...
  - កម្ពស់ ៖ ទាប ខ្ពស់ ...
  - សម្បុរ ៖ ស ខ្មៅ ក្រហម ឡោត ...
  - ខ្លួន ៖ ជើង ក ភ្នែក ច្រមុះ មាត់ ត្រចៀក ស្បែង រោម ...
- គុណសម្បត្តិ
  - ចរិតលក្ខណៈ ៖ ស្លូត ឧស្សាហ៍ ...
  - ការប្រើប្រាស់ ៖ ភ្ជួរ រាស់ អូសរទេះ ចាំផ្ទះ ...
  - ការថែទាំ ៖ លាងទឹក ឱ្យស៊ីស្មៅ ផឹកទឹក ចាក់ថ្នាំបង្ការ...
  - ផលប្រយោជន៍។
- គុណវិបត្តិ
  - កាច សកម្មភាពបង្កការលំបាក ដេកទ្រមក់ ...
  - បំផ្លិចបំផ្លាញ ...។

៣. សេចក្តីបញ្ចប់

- ចំណាប់អារម្មណ៍ ៖ បង្ហាញមនោសញ្ចេតនាចំពោះសត្វនោះ...។


www.elibraryofcambodia.org

វិញ្ញាសាទី ៣

# តែងសេចក្តីបែបពិពណ៌នា អំពីទីកន្លែង

## ក. គម្រោងតែង

### ១. សេចក្តីផ្តើម

- ពេលវេលា ( ទៅទីនោះ ... )
- ទីកន្លែង ( ឈ្មោះទីកន្លែង ... ទីកន្លែងនោះស្ថិតនៅ ភូមិ ... ឃុំ ... ស្រុក ... ខេត្ត ... )

### ២. តួសេចក្តី

- ទិដ្ឋភាពខាងក្រៅ ឬមើលពីចម្ងាយ
  - ទិដ្ឋភាពមើលពីចម្ងាយ(ទីតាំងនោះមានទ្រង់ទ្រាយដូចម្តេច ? ប្រៀបដូចអ្វី ? ( ទំហំ រាង  ពណ៌ ... )
  - ទិដ្ឋភាពពេលចូលទៅដល់ ( ទីតាំងនោះមានទ្រង់ទ្រាយដូចម្តេច ? ឃើញអ្វីខ្លះនៅទីនោះ ... )
- ទិដ្ឋភាពពេលចូលទៅជិត ឬខាងក្នុង
  - រូបរាង ឬទ្រង់ទ្រាយ ហេដ្ឋារចនាសម្ព័ន្ធខាងក្នុង ( មានរូបរាងទ្រង់ទ្រាយដូចម្តេច ? ... )
  - មានអ្វីខ្លះ ដូចជាចំនួនផ្ទះ របៀបផែនសំណង់ជុំវិញផ្ទះមានអ្វី ? ក្រោមផ្ទះមានអ្វី ? ទីតាំង អណ្តូងទឹក ឬស្រះទឹក សាលារៀន មន្ទីរពេទ្យ វត្ត  សាលាឃុំ ... ។


www.elibraryofcambodia.org

- វត្ថុ ឬសម្ភារៈ ( មានវត្ថុ ឬសម្ភារៈអ្វីខ្លះនៅទីនោះ ? ... )
- សកម្មភាពអ្នកធ្វើការ ឬអ្នករស់នៅទីនោះ ...
- ទឹកចិត្តអ្នកធ្វើការ ឬអ្នករស់នៅទីនោះ ...
- សកម្មភាពអ្នករស់នៅទីនោះ ៖
  + ជីវភាព និងមុខរបរ។
  + ជំនឿសាសនា។
  + ទំនៀមទម្លាប់ប្រពៃណី។
  + ចិត្តគំនិត។
- សារៈសំខាន់ និងផលប្រយោជន៍ ៖
  + ទីនោះមានសារៈសំខាន់និងផលប្រយោជន៍ដូចម្តេច ? ...

### ៣.សេចក្តីបញ្ចប់

- វាយតម្លៃទីកន្លែងនោះ ...
- បង្ហាញពីចំណាប់អារម្មណ៍របស់អ្នក ឬមនុស្សទូទៅចំពោះទីកន្លែងនោះ។

## ខ.ការអនុវត្ត

| | |
|---|---|
| *ប្រធាន ៖* | ចូរអ្នកពិពណ៌នាពីផ្ទះដែលអ្នករស់នៅសព្វថ្ងៃឱ្យបានក្បោះក្បាយ ។ |


www.elibraryofcambodia.org

## សេចក្ដីអធិប្បាយ

សព្វថ្ងៃផ្ទះខ្ញុំ ស្ថិតនៅភូមិកន្ទោកខាងជើងសង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជាប់នឹងផ្លូវជាតិលេខ៤។

ប្រសិនបើយើងធ្វើដំណើរពីភ្នំពេញតាមផ្លូវជាតិលេខ៤ ហួសផ្សារជម្ពូវ័នប្រហែល១គីឡូម៉ែត្រ យើងឃើញផ្ទះថ្មទើបសាងសង់ថ្មីអមសងខាងផ្លូវជាច្រើន។ ប្រសិនបើយើងក្រឡេកមើលមកខាងឆ្វេងដៃ យើងនឹងឃើញផ្ទះថ្មជាច្រើនខ្ពស់ៗដែលមានផ្លូវចូលធំទូលាយ។ ផ្ទះខ្ញុំស្ថិតនៅក្នុងចំណោមផ្ទះថ្មទាំងនោះ។ ផ្ទះខ្ញុំសង់អំពីថ្មពីរជាន់នៅផ្នែកខាងមុខផ្ទះមានកន្លែងចតរថយន្ត និងមានផើងផ្កាជាច្រើនដាក់តាំងលម្អ។ ផ្ទះរបស់ខ្ញុំមានបួនបន្ទប់ មានបន្ទប់ទទួលភ្ញៀវ បន្ទប់បាយ និងបន្ទប់ដេកពីរ។ ក្នុងបន្ទប់ទទួលភ្ញៀវមានតាំងរូបតំនូវ មានទូតាំងដាក់ទូរទស្សន៍ មានសាឡុង មានកូនតុនិងកៅអីទទួលភ្ញៀវដែលបានរៀបចំយ៉ាងស្អាតគួរឱ្យទាក់ទាញ។ ក្នុងបន្ទប់បាយមានទូទឹកកក ទូចាន និងតុកៅអីសម្រាប់ហូបបាយទុកយ៉ាងមានរបៀបបានស្អាតល្អ។ ក្នុងបន្ទប់ដេកមានគ្រែ មានខ្នើយ ពូក ទូដាក់ខោអាវ និងទូដាក់ទូរទស្សន៍សម្រាប់មើលផ្ទាល់ខ្លួន តុបតែងបានស្អាតមានរបៀបរៀបរយប្រកបដោយផាសុខភាព និងមានសុភមង្គល ។

ខ្ញុំស្រឡាញ់ផ្ទះខ្ញុំណាស់ ព្រោះវាជាជម្រកដ៏ត្រជាក់ត្រជុំសម្រាប់ក្រុមគ្រួសាររបស់ខ្ញុំ។ ដូច្នេះខ្ញុំត្រូវខិតខំថែរក្សាបោសសម្អាតឱ្យបានល្អ ជាពិសេស កុំឱ្យមានអគ្គិភ័យកើតឡើង ។


www.elibraryofcambodia.org

វិញ្ញាសាទី ៤

# តែងសេចក្តីបែបពិពណ៌នា អំពីគ្រោះធម្មជាតិ

## ក.គម្រោងតែង

១.សេចក្តីផ្តើម

- ពេលវេលា
- ទីកន្លែង
- ឈ្មោះបាតុភូតធម្មជាតិ

២.តួសេចក្តី

- មុនពេលកើតហេតុ
  - ទិដ្ឋភាពទូទៅនៃធម្មជាតិ
  - សញ្ញានៃបាតុភូតធម្មជាតិ
  - សកម្មភាពមនុស្សមុនពេលបាតុភូតធម្មជាតិមកដល់ ... ។
- ពេលកើតហេតុ
  - ទិដ្ឋភាពបាតុភូតធម្មជាតិពេលចាប់ផ្តើមមកដល់
  - សកម្មភាពមនុស្ស សត្វ ពេលបាតុភូតធម្មជាតិផ្តើមមកដល់
  - ទិដ្ឋភាពពេលបាតុភូតធម្មជាតិកំពុងកើតឡើង
  - សកម្មភាពមនុស្ស សត្វ ពេលបាតុភូតធម្មជាតិកំពុងកើតឡើង
  - ទិដ្ឋភាពចុងបញ្ចប់នៃបាតុភូតធម្មជាតិ
  - សកម្មភាពអ្នកស្រុកនៅចុងបញ្ចប់នៃបាតុភូតធម្មជាតិ ... ។
- ក្រោយពេលកើតហេតុ
  - ទិដ្ឋភាពនៃការខូចខាត
  - សកម្មភាពអ្នកស្រុកក្រោយពេលកើតហេតុ



www.elibraryofcambodia.org

- សកម្មភាពផ្ទាភិបាល
- សកម្មភាពអង្គការមនុស្សធម៌ ... ។

៣.សេចក្ដីបញ្ចប់

- ចំណាប់អារម្មណ៍ ៖ បង្ហាញពីចំណាប់អារម្មណ៍ចំពោះបាតុភូតធម្មជាតិ ។

## ខ.ការអនុវត្ត

*ប្រធាន ៖* នៅរសៀលថ្ងៃមួយមានភ្លៀងធ្លាក់យ៉ាងខ្លាំង ព្រមទាំងមានរន្ទះបាញ់ផង ។ ចូរអ្នកតែងពិពណ៌នាពីហេតុការណ៍នោះឱ្យបានក្បោះក្បាយ ។

### សេចក្ដីអធិប្បាយ

នាវេលាប្រហែលជាម៉ោងបួនរសៀល មានភ្លៀងមួយមេយ៉ាងខ្លាំងព្រមទាំងមានរន្ទះបាញ់ផង។

នាវេលារសៀលនោះពេលសិស្សានុសិស្សកំពុងរៀន មេឃចាប់ផ្ដើមខ្មៅមានពពករសាត់ជាផ្ទាំងៗ អាកាសធាតុក្ដៅស្អុះស្អាប់ខុសពីធម្មតា។ មេឃកាន់តែងងឹតសត្វគោ ក្របី ជ្រូក មាន់ ទា រត់រកជម្រករៀងៗខ្លួន។ ចំណែកមនុស្សម្នាទាំងឡាយ ដែលអ្នកខ្លះកំពុងធ្វើដំណើរ ក៏រូតដំណើរយ៉ាងប្រញាប់ប្រញាល់ទៅកាន់គោលដៅ ឬកន្លែងជ្រករៀងៗខ្លួន តាមមធ្យោបាយ ផ្សេងៗមាន កង់ ម៉ូតូ រថយន្តជាដើម។ ចំណែកសិស្សក្នុងថ្នាក់លោកគ្រូ អ្នកគ្រូមិនឱ្យចេញក្រៅផ្ដេសផ្ដាសឡើយ។ មិនយូរប៉ុន្មានភ្លៀងក៏ចាប់ផ្ដើមធ្លាក់យ៉ាងខ្លាំង លាយឡំនឹងខ្យល់បោកបក់អង្រួនស្លឹកឈើញ័ររញ្ជួយ មានមែកឈើខ្លះបាក់ឮសូរប្រាវៗ គួរឱ្យខ្លាចនៅក្នុង


www.elibraryofcambodia.org

បរិវេណសាលារៀន។ សំឡេងផ្គររន្ទះលាន់ឮកងរំពងធ្វើឱ្យមនុស្សម្នាភ័យ
រន្ធត់។ ភ្លៀងនៅតែបន្តធ្លាក់មកយ៉ាងខ្លាំង ពេលនោះយើងឃើញមានរន្ទះ
បាញ់ អមនឹងសំឡេងផ្គររន្ទះញ័ររណ្ដំយកក្រើកអស់ផែនពសុធាធ្វើឱ្យដើម
អម្ពិលទឹកពីរដើមត្រូវឆេះ។ ដើមស្វាយនៅជិតនោះខ្លោចស្លឹក។ ឆ្កែមួយ
ក្បាលត្រូវស្លាប់ដោយរោលខ្លួនខ្មៅញ៉ង។ ក្រោយពេលរន្ទះបាញ់រួច មួយ
សន្ទុះក្រោយមក ភ្លៀងចាប់ផ្ដើមបន្ថយកម្លាំង ខ្យល់បន្ថយល្បឿនសំឡេង
ផ្គររន្ទះក៏បានថយចុះ ផ្ទៃមេឃប្រែមកជាភ្លឺស្រឡះ ចំណែកឯអាកាសធាតុ
ក៏ប្រែមកដូចធម្មតាវិញ ស្នូរជួងក៏បានបន្លឺឡើង គ្រូក៏អនុញ្ញាតឱ្យសិស្ស
ចេញមកផ្ទះ។ នៅជុំវិញសាលារៀនគេឃើញមានមែកឈើ និងស្លឹកឈើ
ធ្លាក់រាយប៉ាយពេញដី។ លោកគ្រូ អ្នកគ្រូមានទឹកមុខស្រស់ស្រាយ រីក
រាយដោយសារភ្លៀងរាំង តែមានការសោកស្ដាយដោយសារការខូចខាត
យ៉ាងដំណំ។ ចំណែកអ្នកដំណើរតាមផ្លូវនានាបានធ្វើដំណើរបន្តទៅកាន់
គោលដៅរៀងៗខ្លួន។ បក្សាបក្សីចេញរកស៊ីសាជាថ្មី។ លោកនាយក និង
លោកគ្រូអ្នកគ្រូនៅក្នុងសាលារៀនខ្លះទៅមើលសត្វរងគ្រោះ ខ្លះទៅមើល
ដើមឈើដំណាំដែលត្រូវឆេះខូចខាត អ្នកខ្លះទៀតដើររើសប្រមូលរបស់
របរដែលហើររបាត់របាយ ។

តាមការបកស្រាយខាងលើនេះ ខ្ញុំឃើញថារន្ទះបាញ់អាចបណ្ដាល
ឱ្យវិនាសអន្តរាយដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិព្រមទាំងធ្វើឱ្យខូច
ខាតរបស់របរដែលមានតម្លៃជាច្រើន។ ដូច្នេះយើងត្រូវមានបម្រុងប្រយ័ត្ន
ពេលមានភ្លៀង ដូចជាមិនត្រូវជ្រកក្រោមដើមឈើ មិនត្រូវប្រើប្រាស់វត្ថុ
ដែលមានជាតិលោហៈ ជាពិសេសគឺទូរស័ព្ទដៃ។ ត្រូវជ្រកក្នុងផ្ទះ ឬទី
កន្លែងដែលមានសុវត្ថិភាព។


www.elibraryofcambodia.org

វិញ្ញាសាទី ៥

# តែងសេចក្តីរៀបរាប់ពិពណ៌នា អំពីសកម្មភាព

## ក.គំរោងតែង

### ១.សេចក្តីផ្តើម

- ពណ៌នាទូទៅទាក់ទងនឹងសកម្មភាព
- ពេលវេលា
- ទីកន្លែង
- អ្នកចូលរួម ... ។

### ២.តួសេចក្តី

- មុនពេលធ្វើសកម្មភាព
  - ការរៀបចំសម្ភារៈសម្រាប់ធ្វើសម្មភាព
  - ស្ថានភាពទីកន្លែង
  - បរិយាកាសទូទៅ ...។
- ពេលធ្វើសកម្មភាព
  - ការចាប់ផ្តើមសកម្មភាព
  - ការប្រើកម្លាំង និងបច្ចេកទេស
  - ភាពមមាញឹកក្នុងការងារតាមផ្នែកនីមួយៗ
  - សកម្មភាពផ្សេងៗទៀត
  - ភាពរីករាយក្នុងពេលធ្វើសកម្មភាព ... ។


www.elibraryofcambodia.org

- ក្រោយពេលធ្វើសកម្មភាព
  - បង្ហាញពីលទ្ធផលការងារ
  - បរិយាកាសទូទៅនៅទីកន្លែងការងារ ... ។

៣.សេចក្ដីបញ្ចប់

- បង្ហាញពីចំណាប់អារម្មណ៍របស់អ្នកចំពោះសកម្មភាព
- បង្ហាញពីសារប្រយោជន៍នៃការធ្វើសកម្មភាព។

## ខ.ការអនុវត្ត

| | |
|---|---|
| *ប្រធាន* ៖ | នៅថ្ងៃព្រហស្បតិ៍មួយសាលារៀនរបស់អ្នកបានធ្វើពលកម្មមួយ។ ចូរអ្នកសរសេរតែងសេចក្ដីពណ៌នាពីសកម្មភាពធ្វើពលកម្មនោះ តាមគម្រោងខាងលើឱ្យបានក្បោះក្បាយ។ |

### សេចក្ដីអធិប្បាយ

កាលពីថ្ងៃព្រហស្បតិ៍សប្ដាហ៍មុន នៅសាលារៀនរបស់ខ្ញុំបានធ្វើពលកម្មសម្អាតបរិស្ថាន សាលារៀនទាំងអស់គ្នា ដោយមានការចូលរួមពីលោកនាយកសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ ដោយមានសម្ភារៈគ្រប់គ្នា ។

បន្ទាប់ពីគោរពទង់ជាតិរួច នៅម៉ោងប្រាំពីរនិងដប់នាទី លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សបានបំបែកជួរទៅតាមថ្នាក់នីមួយៗ រួចអ្នកគ្រូ លោកគ្រូ បានដឹកនាំសិស្សយកសម្ភារៈ ដូចជាចបកាប់ បង្គី អម្បោស ធុងទឹក កំណាត់ កាំបិត ទៅតាមមុខសញ្ញាដែលលោកនាយកបានចែករួចហើយ។


www.elibraryofcambodia.org

នៅពេលនោះ សិស្សានុសិស្សបានចាប់ផ្ដើមបំពេញការងាររៀងៗខ្លួន។ សិស្សខ្លះយកចបកាប់ទៅចូកស្មៅនៅក្នុងសួនច្បារ។ សិស្សខ្លះបោសសម្អាតទីធ្លាសាលា សិស្សខ្លះយកបង្គីកើបសំរាមយកទៅដុតចោលនៅក្រោយអគារ។ សិស្សខ្លះយកកាំបិតទៅកាប់ឆ្ការស្មៅនៅតាមរបងសាលា។ សិស្សខ្លះទៀតយកកំណាត់ ធុងទឹក ទៅជូតតុនៅក្នុងបន្ទប់រៀន និងអ្នកខ្លះទៀតដងទឹកស្រោចផ្កា។

ចំណែកលោកគ្រូ អ្នកគ្រូដឹកនាំសិស្សឱ្យធ្វើការងារតាមតួនាទីរៀងៗខ្លួន។ សកម្មភាពធ្វើពលកម្មសម្អាតបរិស្ថានសាលារៀននេះប្រព្រឹត្តទៅយ៉ាងសកម្មរស់រវើក ហើយស្ថិតក្នុងបរិយាកាស រីករាយក្រៃលែង។

ខ្ញុំពេញចិត្តនឹងការធ្វើពលកម្មនេះណាស់ ពីព្រោះការធ្វើពលកម្មនាំឱ្យយើងមានសុខភាពល្អ ធ្វើឱ្យសាលារៀនមានបរិស្ថានល្អ ជៀសវាងការកើតជំងឺផ្សេងៗ និងធ្វើឱ្យយើងរៀនសូត្របានពូកែទៀតផង។


www.elibraryofcambodia.org

វិញ្ញាសាទី ៦

# តែងសេចក្តីបែបពិពណ៌នា អំពីពិធីបុណ្យផ្សេងៗ

## ក. គម្រោងតែង

### ១. សេចក្តីផ្តើម

- ពិធីបុណ្យជាទំនៀមទម្លាប់ ប្រពៃណីខ្មែរ
- ពេលវេលា
- ទីកន្លែង
- ឈ្មោះពិធីបុណ្យ
- គោលបំណងនៃពិធីបុណ្យ ។

### ២. តួសេចក្តី

- មុនប្រារព្ធពិធីបុណ្យ
  - ការអញ្ជើញភ្ញៀវ
  - រៀបចំបោសសម្អាតផ្ទះ
  - រៀបចំតុបតែងផ្ទះ
  - ការសង់រោង
  - ត្រៀមរៀបចំម្ហូបចំណី គ្រឿងសក្ការបូជា។
- ពេលប្រារព្ធពិធីបុណ្យ

  រសៀល និងយប់ថ្ងៃទី១
  - ការជួបជុំគ្នា
  - ការទទួលភ្ញៀវ
  - ការចូលបុណ្យ


www.elibraryofcambodia.org

- ការពិសាភោជនាហារ
- ការសូត្រមន្តចម្រើនព្រះបរិត្ត
- ការសម្តែងធម្មទេសនា
- ការសម្តែងសិល្បៈ ឬសកម្មភាពកម្សាន្តផ្សេងៗ

**ព្រឹកថ្ងៃទី២**

- ការវេរចង្ហាន់ប្រគេនព្រះសង្ឃ
- ការបង្សុកូលឧទ្ទិសកុសល

• ក្រោយពេលប្រារព្ធពិធីបុណ្យ
- ការថ្លែងអំណរគុណចំពោះអ្នកបានចូលរួម
- ការត្រឡប់ទៅវិញរបស់ភ្ញៀវ
- ការរុះរោង
- ការរៀបចំផ្សេងៗ។

**៣.សេចក្តីបញ្ចប់**

• បង្ហាញពីចំណាប់អារម្មណ៍ និងមនោសញ្ចេតនារបស់អ្នកតែងចំពោះពិធីបុណ្យនេះ។

## ខ.ការអនុវត្ត

**ប្រធាន ៖** នៅក្នុងសហគមន៍អ្នកតែងរៀបចំប្រារព្ធធ្វើពិធីបុណ្យផ្សេងៗ។ ចូរអ្នកសរសេរតែងសេចក្តីពណ៌នាពីពិធីបុណ្យអ្វីមួយតាមគម្រោងខាងលើឱ្យបានត្រឹមត្រូវ។


www.elibraryofcambodia.org

## សេចក្ដីអធិប្បាយ

ជារៀងរាល់ឆ្នាំ ប្រជាជនយើងតែងប្រារព្ធពិធីបុណ្យចូលឆ្នាំយ៉ាងអធិកអធម។ បុណ្យនេះ មានរយៈពេលបីថ្ងៃដែលត្រូវធ្វើឡើងក្នុងខែចេត្រ ហើយធ្វើដំបូងត្រូវនឹងថ្ងៃទី ១៣ ឬ ១៤ ខែមេសា។ ពិធីបុណ្យនេះគេច្រើនប្រារព្ធនៅផ្ទះក្នុងភូមិ និងតាមវត្តអារាមនានា។

មុនថ្ងៃបុណ្យ ប្រជាជនបានបោសសម្អាតតុបតែងលម្អគេហដ្ឋាន អគារ ក្រសួងមន្ទីរ វត្តអារាម និងទីសាធារណៈនានា។ តាមលំនៅឋាននីមួយៗសុទ្ធតែលម្អដោយគោមរណែងរណោងព្រោងព្រាត គួរឱ្យចាប់អារម្មណ៍ក្រៃលែង។ តាំងពីដើមរៀងមក នៅពេលចូលឆ្នាំថ្មីនេះ ប្រជាជនយើងតែងផ្អាកការងារទាំងអស់ ដើម្បីចូលរួមធ្វើពិធីនេះយ៉ាងសប្បាយរីករាយ។

ថ្ងៃដំបូងប្រជាជនយើងធ្វើម្ហូបអាហារ នំចំណីទៅប្រគេនព្រះសង្ឃ ឬជូនជីដូនជីតា ម្ដាយឪពុក និងចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិដើម្បីសម្ដែងការគោរពស្ញប់ស្ញែង នៅឯវត្តឧបាសក ឧបាសិការួបរួមទៀនធូបបុប្ផាផ្កាភ្ញីដើម្បីរំឭកគុណព្រះរតនត្រ័យ និងឧទ្ទិសកុសលជូនញាតិសន្តានដែលបានចែកឋានទៅហើយ។ កុមារកុមារី យុវជនយុវតីតុបតែងកាយស្អាតបាតសមរម្យនាំគ្នាលេងល្បែងប្រជាប្រិយដូចជា ឈូង អង្គញ់ ទាញព្រ័ត្រជាដើម។ គេនាំគ្នាដើរកាត់ពីភូមិមួយទៅភូមិមួយទៀត ដើម្បីរាំច្រៀងកម្សាន្តតាមសិល្បៈប្រពៃណីជាតិក្នុងបរិយាកាសសប្បាយជាទីបំផុត។

ថ្ងៃបុណ្យចូលឆ្នាំ គឺជាបុណ្យមួយយ៉ាងសំខាន់របស់ជាតិសាសន៍នីមួយៗ។ គឺជាថ្ងៃជោគជ័យសិរីមង្គល និងជាថ្ងៃដែលយើងទទួលសព្ទសាធុការពរពីជីដូនជីតា ម្ដាយឪពុក និងបងប្អូនញាតិមិត្តជិតឆ្ងាយ។ យើងបានរៀបចំខ្លួនប្រាណ និងចិត្តគំនិតសតិអារម្មណ៍ឱ្យល្អដើម្បីបំពេញភារកិច្ចថ្មីឱ្យបានជោគជ័យ។


www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

យើងខ្ញុំជាកូន ខ្មៅ យ៉ាត់ណេ, ខ្មៅ សុផល, ខ្មៅ វិសាល, ខ្មៅ វ៉ាមុន, ខ្មៅ ភាពជា, ខ្មៅ ចំរើន និង ខ្មៅ ភក្តី
បានឧបត្ថមការផ្សាយសៀវភៅនេះជា eBook

ដើម្បីឧទ្ទិសកុសលផលវិញ្ញាណក្ខន្ធ ឧបាសក ខ្មៅ ពេញ និង ឧបាសិកា ឈុន យឿន

(ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប)

ស្កេនជា eBook ដោយ សៀង ស៊ីវ៉ាន់
ខែមិនា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព «កម្មសិទ្ធ» របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រការណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្មៅ ឃុនសាំង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org

## យើងបម្រើសេវាកម្ម :

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

## WE SERVE :

- book and teaching-aid developmen
- printing
- distribution to schools

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ (គ.ប.ច)
PUBLISHING AND DISTRIBUTION HOUSE ( PDH )

# បណ្ណាគារ គ.ប.ច
# PDH BOOKSHOP

## មានលក់ :

សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ
សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម និង
សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

## SELLING :

textbooks , teacher's manuals ,
workbooks , supplementary readers
teaching-aids and stationary !

9789995002176

www.elibraryofcambodia.org